# ប្រទេសកម្ពុជាឆ្នាំ១៩៩៩_២០០០:

## ការផ្តោតលើ បញ្ហាដីធ្លី កំលាំងពលកម្ម

## និងការចិញ្ចឹមជីវិតនៅជនបទ

ឯកសារពិភាក្សាលេខ ២១


Bhargavi Ramamurthy ស៊ិក ប៊ូរ័ក្ស

Per Ronnås និង សុក ហាច



វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ភ្នំពេញ ខែមីនា ឆ្នាំ២០០២

© រក្សាសិទ្ធិឆ្នាំ២០០២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃឯកសារបោះពុម្ពផ្សាយនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា: អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៏អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISSN 1560 9812

**ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ —**
**ឯកសារពិភាក្សាលេខ ២១**
**ខែមីនា ឆ្នាំ២០០២**

Bhargavi Ramamurthy **ស៊ិក បូរ៉ក្ស** Per Ronnås **និង សុក ហាច**

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។*
*ទស្សនៈទាំងនេះមិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះ បណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣/៨៨០-៧៣៤/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤
អ៊ីមែល: cdri@camnet.com.kh / website: http://www.cdri.org.kh

បកប្រែដោយ: ច័ន្ទ សុផល និង សូ សុវណ្ណារិទ្ធិ
កែសម្រួល និងរចនាដោយ: អែម សូរ៉ានី

# មាតិកា


បុព្វកថា.....i

សម្រង់អត្ថបទ.....iii

បញ្ជីអក្សរកាត់.....v

**ជំពូក មួយៈ ការពិនិត្យមើលជាទូទៅលើការអនុវត្តន៍សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ១៩៩៨-៩៩** ..... ១

១.១ ទិន្នន័យប្រជាជន និង កំលាំងពលកម្ម..... ២

១.២ ការអភិវឌ្ឍន៍វិស័យផលិត ..... ៤

១.៣ ថ្លៃ និងអត្រាប្តូរប្រាក់ ..... ៩

១.៤ ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និង រូបិយវត្ថុ..... ១១

១.៥ ហិរញ្ញវត្ថុសាធារណៈ ..... ១៣

១.៦ ពាណិជ្ជកម្មក្រៅប្រទេស..... ១៦

១.៧ តួនាទីនៃជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) នៅក្នុងសេដ្ឋកិច្ចកម្ពុជា..... ១៨

**ជំពូក ពីរៈ ជីវភាពនៅជនបទ និង ការទទួលនិងប្រើប្រាស់ដី**..... ២១

២.១ ដី កំលាំងពលកម្ម និងជីវភាពកសិកម្ម..... ២១

២.២ ការទទួលបានដីធ្លី ..... ២៥

២.៣ លទ្ធកម្មដីធ្លី ..... ៣៣

២.៤ ការកាន់កាប់ដីធ្លី ..... ៣៤

២.៥ ការបែងចែកដីធ្លី និងភាពគ្មានដីធ្លី..... ៣៧

២.៦ ការជួលដីធ្លី ..... ៤៤

២.៧ ធនធានទ្រព្យរួម ..... ៤៥

២.៨ ការលក់ដីធ្លី ..... ៤៧

**ជំពូក បីៈ លក្ខណៈនៃគ្រួសារគ្មានដី និង គ្រួសារមានដីតូច** ..... ៤៩

៣.១ លក្ខណៈប្រជាសាស្ត្រតាមគ្រួសារ ..... ៤៩

៣.២ ការអប់រំ និង អក្ខរកម្ម..... ៥០

៣.៣ ប្រាក់ចំណូលគ្រួសារ ..... ៥១

៣.៤ លក្ខណៈសាងសង់ផ្ទះ និង កម្មសិទ្ធិទ្រព្យមានតំលៃ ..... ៥២
៣.៥ ការកាន់កាប់សត្វពាហនៈ ..... ៥៤
៣.៦ ឥណទាន ..... ៥៥
៣.៧ មូលហេតុនៃភាពគ្មានដី ..... ៥៨

**ឧបសម្ព័ន្ធ** ..... ៦១
**ឯកសារពិភាក្សាបោះពុម្ពផ្សាយដោយ វិបសអ** ..... ៦៥

# បុព្វកថា

ឯកសារពិភាក្សានេះកើតចេញមកពីគំរោងស្រាវជ្រាវរួមធ្វើឡើងរវាងវិទ្យាស្ថាន Nordic សិក្សាពីអាស៊ី (NIAS) នៅទីក្រុងកូហ៊ិនហៃប្រទេសដាណឺម៉ាក និងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI) នៅទីក្រុងភ្នំពេញប្រទេសកម្ពុជា ក្នុងឆ្នាំ២០០០ ក្រោមការឧបត្ថម្ភថវិកាពីភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិស៊ុយអែត (Sida)។ ច្បាប់ដើមនៃឯកសារពិភាក្សានេះត្រូវបានបោះផ្សាយដោយ Sida នៅដើមឆ្នាំ ២០០១ ដែលមានចំណងជើងថា របាយការណ៏សេដ្ឋកិច្ចប្រចាំប្រទេសនៅឆ្នំា ២០០១ ។ ការបោះផ្សាយដោយ CDRI គឺជាឯកសារពិភាក្សាលេខ ២១ សំរាប់ចែកផ្សាយនៅ អាស៊ី និងអាមេរិក ។

ឯកសារនេះត្រូវបានសរសេរជាបីជំពូកផ្សេងគ្នាដែលពីរជំពូកចុងក្រោយមិនសូវជាជាប់ទាក់ទិនទៅនឹងជំពូកទីមួយទេ។ ជំពូកទីមួយ បង្ហាញពីការវាយតំលៃនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ។ ជំពូកនេះត្រូវគេផ្តល់ឱ្យអ្នកអាននូវទំរង់ច្បាស់លាស់ពីលក្ខណផ្សេងគ្នានៃសេដ្ឋកិច្ច ។ ជំពូកនេះនឹងបំរើឱ្យអ្នកអានបានច្រើននាក់ ដោយសារ វាមានខ្លឹមសារជាទូទៅ ។ ចំណែកឯពីរជំពូកចុងក្រោយថែងពីបញ្ហាសំខាន់មួយចំនួនសំរាប់អ្នកថែងគោលនយោបាយ និងភាគីផ្សេងទៀតដែលចាប់អារម្មណ៏នឹងសេដ្ឋកិច្ចកម្ពុជា ។ ជំពូកទីពីរ វិភាគលើកបញ្ហាកម្មសិទ្ធិដីធ្លី លទ្ធភាពប្រើប្រាស់ដីធ្លី ភាពមិនស្មើគ្នានៃការបែងចែកដីធ្លី និងការបាត់បង់ដីធ្លី ។ ចំណុច នីមួយៗទាំងនេះ ពិតជាមានសារៈសំខាន់ចំពោះប្រទេសកម្ពុជា ដោយហេតុថា ប្រជាជនកម្ពុជាប្រមាណ ៣ភាគ៤ ពឹងផ្អែកលើដីធ្លី និងការធ្វើកសិកម្មសំរាប់ចិញ្ចឹមជីវិត ។ ជំពូកទីបី ពិនិត្យលើការកាន់កាប់ និងការចុះបញ្ជីដីនៃគ្រួសារគ្មានដី និងគ្រួសារមានដីតូច។ ជំពូកទាំងពីរខាងក្រោយនេះផ្តល់ពត៌មានលំអិតសំរាប់ការថែងគោលនយោបាយលើកសិកម្ម និងការទប់ស្កាត់កក្តាដែលនាំឱ្យមាន ភាពក្រីក្រ ។

ឯកសារនេះជារបាយការណ៏មួយដែលស្តីពីសេដ្ឋកិច្ច ដូច្នេះវាមិនមានបែបទចងក្រងដូចធម្មតាទេ ។ គេសង្ឃឹមថាឆ្នាំបន្តបន្ទាប់ទៀត CDRI នឹងបោះផ្សាយឯកសាររបៀបនេះជាប្រចាំឆ្នាំ ដែលមានទាំងចំណុចខ្លីៗលើលក្ខណៈនៃសេដ្ឋកិច្ចរួមជាមួយការបកស្រាយយ៉ាងច្បាស់ ។

*Bhargavi Ramamurthy ស៊ិក បូរ័ក្ស*

*Per Ronnås និង សុក ហាច*

# សម្រង់អត្ថបទ

ស្ថិរភាពនយោបាយមានភាពប្រសើរឡើងយ៉ាងច្រើននៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីបានបង្កើតរដ្ឋាភិបាល ដោយការបោះឆ្នោតនៅខែវិច្ឆិកា ឆ្នាំ ១៩៩៨មក ។ ចំណុចនេះបានឆ្លុះឱ្យឃើញពីការលូតលាស់សេដ្ឋកិច្ចបន្ត និងសន្ទស្សន៍ម៉ាក្រូសេដ្ឋកិច្ចក៏ត្រូវបានកែលំអឱ្យប្រសើឡើងទូទាំងប្រទេសដែរ ។ លក្ខខណ្ឌនៃការកែទំរង់ស្ថាប័ន និងសាមគ្គីភាពដែលត្រូវការបំផុតសំរាប់ធ្វើសេដ្ឋកិច្ច និងការអភិវឌ្ឍន៏សង្គមឱ្យមានចីរភាព ក៏ហាក់ដូចជាត្រូវបានកែលំអដែរ ។

ផលិតផលក្នុងស្រុកសរុប (ផសស) កើនបាន ៤,៥% ក្នុងឆ្នាំ ១៩៩៩ និងបន្ទាប់ពីរយៈពេលពីរឆ្នាំនៃកំណើនសូន្យ ។ ការ លូតលាស់យ៉ាងសំរុកនៃឧស្សាហកម្មកាត់ដេរ គឺជាកត្តាសំខាន់មួយដែលស្ថិតនៅពីក្រោយការលូតលាស់នេះ។ ប៉ុន្តែផលិតកម្មកសិកម្ម ក៏បានកែលំអផងដែរ ។ អត្រាអតិផរណាក៏ធ្លាក់ចុះ ពី ១៥% នៅក្នុងឆ្នាំ ១៩៩៨ មកត្រឹម ៤% នៅឆ្នាំ១៩៩៩ ។ ពាណិជ្ជកម្មក្រៅ ប្រទេសកើនខ្ពស់នៅក្នុងឆ្នាំ ១៩៩៩ ប៉ុន្តែ ឱនភាពដ៏ធំនៃតុល្យភាពគណនីចរន្ត និងពាណិជ្ជកម្មនៅតែមាន ។ ជាងពាក់កណ្តាល នៃចំណូលនាំចេញ គឺជាចំណែករបស់ឧស្សាហកម្មកាត់ដេរ ។ ឆ្នាំ ១៩៩៩ ក៏ជាឆ្នាំដែលត្រូវការការកែលំអយ៉ាងខ្លាំងលើមូលដ្ឋានសារពើរពន្ធ ។ ចំណូលរដ្ឋកើនពីជាង ៣% ទៅ ១១,២% នៃ ផសស ។ ចំណាយសាធារណៈស្ថិតនៅជាមួយខ្ទង់ចំណូល និង ឱនភាពថវិកាមានយ៉ាងច្រើន ៥,២% នៃផសស ។ ចំណាយផ្នែកសង្គមកើនទាំងបរិមាណ និង លក្ខខណ្ឌ (ពី ២២% ទៅ ២៨% នៃចំណាយចំណាយចរន្ត) ប៉ុន្តែ វានៅតែមិនគ្រប់គ្រាន់ដដែល ។ ចំណាយការពារជាតិកំពុងធ្លាក់ចុះជាបណ្តើរៗ ប៉ុន្តែ បរិមាណសរុបនៃ ចំណាយនេះនៅតែខ្ពស់ជាង ៤0% នៃចំណាយសាធារណៈសរុបដដែល ។

បន្ទាប់ពីការធ្លាក់ចុះយ៉ាងគំហុកនៅឆ្នាំ១៩៩៧ ជំនួយបរទេសបានកើនឡើងជាថ្មី ប៉ុន្តែមិនទាន់ឈានដល់ ចំណុចកំពូលនៅមុនវិបត្តិដែលមានបរិមាណជាង ៥00លានដុល្លារ ឡើយ ។ កម្ពុជានៅតែរពឹងយ៉ាងខ្លាំងលើជំនួយខាងក្រៅដើម្បីទូទាត់លើឱនភាពយ៉ាងធំក្នុងគណនេយ្យក្រៅប្រទេស និងក្នុងថវិការដ្ឋ ។ ម្ចាស់ជំនួយក៏បានទាមទាឱ្យវិស័យសាធារណៈប្រឹងប្រែងផ្តល់សេវា និងវិនិយោគទៅលើផ្នែកហេដ្ឋារចនាសម្ពន្ធ័ ។ នៅក្នុងឆ្នាំ ១៩៩៨ ជំនួយពីក្រៅប្រទេសមានបរិមាណស្មើនឹង ១៤% នៃផសស, ត្រូវជា ៧0% នៃការនាំ ចេញក្នុងស្រុកនឹងត្រូវជា ១៦៧% នៃចំណូលរបស់រដ្ឋ ។ ជាងពាក់កណ្តាលនៃជំនួយទាំងនេះជាជំនួយទ្វេភាគី, ៣0% គឺជាជំនួយពហុភាគី និងក្រៅពីនេះជាជំនួយក្រោមរូបភាពជាអង្គការក្រៅរដ្ឋាភិបាល ។ ជំនួយពីក្រៅដែលមានបរិមាណប្រហែល ៤ភាគ៥ គឺជាជំនួយក្រោមរូបភាពឥតចំណង ។

តាមលទ្ធផលនៃក្រាហ្វិកអាយុ កម្ពុជាមានប្រជាជនក្មេងៗច្រើនណាស់ ។ ប្រមាណ ៥៥% នៃបរិមាណប្រជាជនសរុបមានអាយុក្រោម ២0ឆ្នាំ ហើយប្រជាជនដែលមានអាយុលើសពី ៥0ឆ្នាំ មានបរិមាណយ៉ាងតិចទៅវិញ ។ ហេតុនេះ កំលាំងពលកម្មកើនឡើងយ៉ាងលឿន ។ អត្រាកំណើនយ៉ាងខ្ពស់នេះនឹងបន្តកើនឡើងយ៉ាងខ្ពស់ជាងទសវត្សរ៏នេះ ។ នៅក្នុងដំណាក់កាល

១៩៩៨-២០០៣ កំលាំងពលកម្មត្រូវគេស្មានថានឹងកើនដល់មួយលាននាក់ ឬ ២០% ។ នៅក្នុងពេលជាមួយគ្នានេះដែរ អត្រាក្នុងបន្ទុកក៏ធ្លាក់ចុះ ខណៈដែលក្រុមអាយុដែលមានសកម្មភាពសេដ្ឋកិច្ចបន្ថែមកំណើននៅក្នុងបរិមាណប្រជាជនសរុប ។ លទ្ធភាពសេដ្ឋកិច្ចដែលអាចបង្កើត ការងារមានផលិតភាពសំរាប់អ្នកដែលចូលក្នុងកំលាំងពលកម្មថ្មី គឺជាបញ្ហានៃការអភិវឌ្ឍន៍ដ៏អស្ចារ្យកំពុងប្រឈមនឹងកម្ពុជាសព្វថ្ងៃ ។ ការអភិវឌ្ឍន៍ដ៏សកម្មនៃវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ គឺជាភារៈដ៏សំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវឱកាសការងារសំរាប់ប្រជាជនប្រមាណ ៨៤% រស់នៅជនបទ, ៧៧% ជាកំលាំងកសិកម្មក្នុងផ្នែកកសិកម្ម និងច្រើនជាង ៦៣% ជាកំលាំងលកម្មនៅក្នុង ការដាំដុះតាមរបៀបជីវព្រឹត្ត ។ ផលិតផលកសិកម្មនៅទាបជាងប្រទេសជិតខាងយ៉ាងច្រើន ។ កសិកម្មនៅកម្ពុជាមានរដូវប្រមូលផលតែមួយ ហើយទិន្នផលទាបទៀតផង ។ ការកែប្រែកសិកម្មតំរូវឱ្យមានការរួមសំបាច់គ្នាដោយមានការប្តូរពីការដាំដុះរបៀបជីវព្រឹត្ត ទៅជាការដាំដុះសំរាប់តំរូវតាមទីផ្សារ ។ អន្តរកាលប្តូរនេះតំរូវឱ្យមានសុវត្ថិភាពលើសិទ្ធិជាម្ចាស់ទ្រព្យសម្បត្តិធ្វើឱ្យកាន់តែប្រសើរនូវហេដ្ឋារចនាសម្ពន្ធ័ និងលទ្ធភាពប្រើប្រាស់ទីផ្សារ និងទុនផលិត, ការអភិវឌ្ឍន៍តំណាលគ្នានូវសេដ្ឋកិច្ចមិនមែនការដាំដុះនៅជនបទ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវចំណងតភ្ជាប់ពីជនបទមកទីក្រុង ។ ផលិតកម្មកសិកម្មទទួលបានកាន់តែប្រសើរឡើងនៅក្នុងឆ្នាំថ្មីៗនេះ ។ ផលិតកម្មស្រូវទើបតែកើនខ្ពស់ក្នុងរយៈពេល ៥ ឆ្នាំនេះ បន្ទាប់ពីរយៈពេលបីទសវត្សរ៍នៃភាពរីកវរកន្លងមក ។ កំណើននេះទទួលបានដោយសារការពង្រីកផ្ទៃដីដាំដុះដែលជាលទ្ធផលនៃការបញ្ចប់ជំលោះ ។ វាក៏ជាលទ្ធផលនៃកំណើនទិន្នផល និងការដំណាំទ្វេមុខ ដែលបញ្ជាក់ថាការពង្រីកផ្នែកដាំដុះមាន នៅភាគខ្លះនៃផ្ទៃប្រទេស ។ ទោះបីជាយ៉ាងនេះក្តី វាមិនទាន់មានពត៌មានគ្រប់គ្រាន់នៅឡើយ អំពីទំហំ, ចរិក និងចីរភាព នៃការអភិវឌ្ឍន៍នេះ ។

វាមានឧបសគ្គជាច្រើនចំពោះការអភិវឌ្ឍន៍ដ៏មានចីរភាពនៃសេដ្ឋកិច្ចជនបទ ដោយមិនគិតពីលទ្ធផលនៃការអភិវឌ្ឍន៍ជាវិជ្ជមាននៅពេលបច្ចុប្បនេះឡើយ ។ កំរិតនៃការអប់រំស្ថិតនៅទាប ។ ប្រមាណ ៣០% នៃមេគ្រួសារនៅជនបទ និងប្រហែលពាក់កណ្តាលនៃសហពន្ធរបស់គេ គឺជាអនក្ខរជនដែលបញ្ជាក់ថា ពួកគេនឹងជួបឧបសគ្គយ៉ាងធ្ងន់ធ្ងរប្រសិនបើគេចូលរួមនៅក្នុងប្រព័ន្ធដាំដុះតាមបែបពាណិជ្ជកម្ម ឬសកម្មភាពសេដ្ឋកិច្ចមិនមែនការដាំដុះ ។ កំរិតស្តង់ដាសុខភាពនៅជនបទកបង្កឱ្យមានមូលហេតុគួរឱ្យព្រួយបារម្ភណ៍ដែរ ។

ការកើននូវចំនួនអ្នកគ្មានដី និងអ្នកមានដីតូច ក៏ទប់ស្កាត់នូវការអភិវឌ្ឍន៍ជនបទឱ្យសកម្មផងដែរ ។ វាមានភាពលំបាកជាខ្លាំងក្នុងការពិនិត្យមើលឱ្យច្បាស់ពីរចនាសម្ព័ន្ធនៃការកាន់កាប់ដីធ្លី ដោយហេតុថា វាខ្វះស្ថិតិលំអិតទូទាំងប្រទេស ។ ទោះបីជាយ៉ាងនេះក្តី ភស្តុតាងដែលមានមួយចំនួនបញ្ជាក់យ៉ាងច្បាស់ថា វាមានភាពខុសគ្នាជាខ្លាំងលើលទ្ធភាពប្រើប្រាស់ដី ចាប់តាំងពីការបំបាត់សហករណ៍នៅចុងទសវត្សរ៍ ១៩៨០ មក ។ ប្រជាជនប្រមាណ ១២-១៥% គឺជាអ្នកគ្មានដី ហើយគេជឿថាពួកអ្នកទាំងនេះមិនមានប្រភពចំណូល ដ៏ធំដុំពីកសិកម្មឡើយ ។ ពួកគេបង្កើតជាក្រុមផ្សេងៗគ្នា ។ គ្រួសារខ្លះមានជីវភាពរុងរឿង ហើយខ្លះទៀតក៏មានជីវភាពតោកយ៉ាកជាខ្លាំង ។ ប្រការដែលព្រួយបារម្ភថែមទៀតនោះ គឺឧប្បត្តិហេតុនៃការជិតក្លាយទៅជាអ្នកគ្មានដីធ្លី ។ ប្រជាជនប្រមាណជិត ៤០% មានដីកសិកម្មត្រឹមតែ ០.៥ហត ។ ប្រការនេះវាតិចតួចណាស់ដើម្បីកសិកម្មជីវព្រឹត្តិ ទោះបីជាពួកគេភាគច្រើនរំពឹងលើកសិកម្មសំរាប់ចិញ្ចឹមជីវិតក៏ដោយ ។ កត្តាសំខាន់ៗដែលស្ថិតនៅពីក្រោយដែនកំណត់សេដ្ឋកិច្ចរបស់ប្រជាជនដ៏ច្រើនទាំងនេះ គឺកំណើនប្រជាជនដ៏ឆាប់រហ័ស, កង្វះការងារមិនមែនការដាំដុះ និងលក្ខខណ្ឌសេដ្ឋកិច្ចធ្លាក់ចុះ ។ ការអភិវឌ្ឍន៍នេះនឹងជួយបំភ្លឺខ្លះៗដល់បញ្ហាប្រឈមនៃការបង្កើតការងារក្នុងទ្រង់ទ្រាយដ៏ធំមួយ ។

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៏អាស៊ី (Asian Development Bank) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៏ (Association of Southeast Asian Nations) |
| CASD | សកម្មភាពសហគមន៏សំរាប់អភិវឌ្ឍន៏សង្គម (Community Action for Social Development) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា (Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (Cambodia Development Resource Institute) |
| EIU | Economist Intelligence Unit |
| ESAF | Enhanced Structural Adjustment Facility |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (Food and Agricultural Organisation) |
| CPR | ធនធានទ្រព្យរួម (Commom Property Resources) |
| FDI | វិនិយោគទុនផ្ទាល់ពីបរទេស (Foreign Direct Investment) |
| LADIT | ភាពគ្មានដីធ្លី និងការអភិវឌ្ឍន៏ (Landlessness and Development Information Tool) |
| MRC | គណកម្មាការទន្លេមេគង្គ (Mekong River Commission) |
| NBC | ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia) |
| NIS | វិជ្ជាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| SOC | រដ្ឋកម្ពុជា (State of Cambodia) |
| UNICEF | មូលនិធិសំរាប់កុមារនៃអង្គការសហប្រជាជាតិ (United Nations Children's Fund) |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក (World Food Programme) |
| អង្កេត Baseline | អង្កេតមូលដ្ឋានឆ្នាំ១៩៩៨ នៃគំរោង CASD និងតំបន់មុខសញ្ញារបស់ WFP (Cambodian 1998 Baseline Survey of CASD Project and WFP Target Areas) |
| អង្កេត MRC | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចចំពោះគ្រួសារនៅក្នុងសហគមន៏នេសាទដោយ MRC 1995-96 (Household Socio-economic Survey in Fishing Communities, MRC 1995-96) |
| អង្កេត PET | អង្កេតមុខសញ្ញាសង្គ្រោះបន្ទាន់រយៈពេលយូរ (Protracted Emergency Target Survey) |
| អង្កេត SES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៧ (Cambodia Socio-economic Survey 1997) |

## ជំពូក មួយ

# ការពិនិត្យមើលជាទូទៅលើការអនុវត្តន៍សេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ ១៩៩៨-៩៩[១]

ប្រទេសកម្ពុជាមានស្ថិរភាពគ្រាន់បើជាងមុននៅក្នុងបរិស្ថាននយោបាយ និងសេដ្ឋកិច្ច ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ១៩៩៨មក គឺនៅពេលដែលរដ្ឋាភិបាលចំរុះថ្មីមួយ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ីនប៉ិចបានឡើងកាន់អំណាច ។ បន្ទាប់ពីជួបប្រទះនឹងការធ្លាក់ចុះដោយសារវិបត្តិធំៗពីរនៅឆ្នាំ១៩៩៧ (វិបត្តិនយោបាយក្នុងប្រទេសនៅខែកក្កដា ឆ្នាំ១៩៩៧ និងវិបត្តិហិរញ្ញវត្ថុអាស៊ី) សេដ្ឋកិច្ចកម្ពុជាបានកើនឡើងនៅក្នុងឆ្នាំ ១៩៩៩ ដោយសារស្ថិរភាពនយោបាយនេះ ។

ចាប់តាំងពីឡើងកាន់អំណាចមក រដ្ឋាភិបាលបានចាប់ផ្តើមកំណែទំរង់សេដ្ឋកិច្ចមួយចំនួន ។ ការបង្កើតឡើងនូវពន្ធតំលៃបន្ថែម (VATនៅក្នុងខែមករា ១៩៩៩) គឺជាវិធានការដំបូងបំផុតមួយដើម្បីពង្រឹងហិរញ្ញវត្ថុសាធារណៈ ។ រដ្ឋាភិបាលបានធ្វើផែនការកាត់បន្ថយពន្ធនាំចូលឱ្យបានមុនឆ្នាំ២០១០ ចំពោះទំនិញនាំចូលភាគច្រើនឱ្យមកនៅត្រឹមកំរិតក្រោម ៥% ដើម្បីឱ្យសមស្របនឹងនយោបាយសារពើពន្ធរបស់ប្រទេសអាស៊ានដទៃទៀត[២] ។ កម្ពុជាក៏បានទទួលកៅអីរបស់ខ្លួននៅក្នុងអង្គការសហប្រជាជាតិវិញដែរ កាលពីខែធ្នូ ១៩៩៨ ។ សហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិបន្តផ្តល់ជំនួយរូបិយវត្ថុលើគ្រប់វិស័យ[៣] ដោយផ្អែកលើការធានាថានឹងមានកំណែទំរង់ និងស្ថិរភាពជាបន្ត ហើយកំចីប្រាក់យេនរបស់ជប៉ុន ក៏បានដំណើរការដែរ ។ កំណើនសេដ្ឋកិច្ចដ៏ខ្លាំងនៅក្នុងតំបន់បានចូលរួមវិភាគទានដល់ការបង្កើនតំរូវការទេសចរណ៍នៅកម្ពុជា ទោះបីជាការរើបឡើងវិញពីវិបត្តិហិរញ្ញវត្ថុអាស៊ីក្នុងតំបន់នេះមានឥទ្ធិពលតិចតួចទៅលើតំរូវការទំនិញពីកម្ពុជា ដោយសារមានទំនាក់ទំនងតិចតួចរវាងកម្ពុជា និងប្រទេស ជាតិទាំងនេះ ។ ប្រាក់រៀលដែលមានស្ថិរភាព និងមានអតិផរណាតិចតួច និងគោលនយោបាយបន្តឹងថវិកាក៏បានចូលរួមចំណែក ក្នុងការរើបឡើងវិញនៃសេដ្ឋកិច្ចនៅឆ្នាំ១៩៩៩ ផងដែរ ។

---

១ អ្នកនិពន្ធសូមថ្លែងអំណរគុណជាអនេកចំពោះលោក សុក ហាច ដែលបានផ្តល់ពត៌មានស្ថិតិជាច្រើនដែលជាមូលដ្ឋានសំរាប់ជំពូកនេះ ហើយជាពិសេស លោក បានជួយយើងក្នុងការវាយតំលៃ និងវិភាគពត៌មានទាំងនេះ ។

២ កម្ពុជា បានចូលអាស៊ាន ក្នុងខែមេសា ឆ្នាំ១៩៩៩ ។

៣ Enhanced Structural Adjustment Facility (ESAF) របស់ IMF ត្រូវបានអនុម័តនៅក្នុងខែតុលា ឆ្នាំ១៩៩៩ ដើម្បីគាំទ្រការកែទំរង់វិស័យសាធារណៈ (World Bank, 2000) ។

## ១.១ ទិន្នន័យប្រជាជន និង កំលាំងពលកម្ម

ជំរឿនឆ្នាំ១៩៩៨ ផ្តល់នូវតួលេខសរុបមុនគេបំផុតអំពីប្រជាសាសន៍របស់កម្ពុជាបច្ចុប្បន្ន និងធ្វើជាឧបករណ៏ដ៏មានប្រយោជន៏មួយសំរាប់ការយល់ដឹងអំពីរចនាសម្ព័ន្ធនៃកំលាំងពលកម្មជាតិ ។ បើយោងតាមជំរឿន ចំនួនប្រជាជនសរុបនៅក្នុងឆ្នាំ ១៩៩៨ គឺ ១១,៤ លាននាក់ ដែលក្នុងនោះមានប្រហែល ៥២% ជាស្ត្រី (ក្រាហ្វិក ១.១) និង ៨៤% រស់នៅក្នុងតំបន់ជនបទ។ របាយអាយុបង្ហាញឱ្យឃើញថា ៥៤,៦% នៃប្រជាជនក្នុងឆ្នាំ១៩៩៨ មានអាយុក្រោម ២០ឆ្នាំ ។

តារាង ១.១ បង្ហាញនូវរបាយកំលាំងពលកម្មតាមភេទ និងតាមតំបន់ ។ តួលេខនៅក្នុងរង្វង់ក្រចកបង្ហាញពីភាគរយនៃប្រជាជនដែលមានការងារធ្វើ (អត្រាចូលរួមរបស់កំលាំងពលកម្ម) នៅក្នុងក្រុមអាយុនិមួយៗ ។ តារាង ១.១ បង្ហាញថា អត្រាចូលរួមកំលាំងពលកម្មរបស់បុរសមានកំរិតខ្ពស់ជាង (លើកលែងតែក្នុងអាយុ ១៥-១៩ឆ្នាំ) និងមានកំរិតខ្ពស់ផងដែរនៅក្នុងចំណោមប្រជាជនជនបទ ។ មូលហេតុមួយដែលបណ្តាលឱ្យមានការខុសគ្នារវាងតំបន់ទីក្រុង និងជនបទខាងលើអាចបណ្តាលមកពីនៅក្នុងតំបន់ទីក្រុង អត្រាចូលរួមក្នុងការងារកសិកម្មមានកំរិតតិចជាង និងមានភាគរយចូលរៀនខ្ពស់ជាងតំបន់ជនបទ[៤] ។ ចំនួនមនុស្សដែលគ្មានការងារធ្វើគឺ ២៧៣.១៨៣នាក់ ក្នុងនេះ ៣/៤ នៅតំបន់ជនបទ ។ ក៏ប៉ុន្តែ បើគិតជាភាគរយវិញ អត្រាគ្មានការងារនៅតំបន់ទីក្រុង (៣,៧%) មានកំរិតប្រហាក់ប្រហែលនឹងអត្រានៅទីជនបទដែរ (២,១%) ។

**តារាង ១.១. រចនាសម្ព័ន្ធអាយុ នៃកំលាំងពលកម្ម គិតតាមភេទ និងតាមតំបន់ (គិតជា ពាន់នាក់)**

| ក្រុមអាយុ (ឆ្នាំ) | សរុប | បុរស | ស្ត្រី | ទីក្រុង | ជនបទ |
|---|---|---|---|---|---|
| 15–19 | 552.2 (41.1) | 226.5 (34.1) | 325.8 (47.9) | 60.5 (25.9) | 491.8 (44.3) |
| 20–24 | 561.9 (75.4) | 275.7 (77.8) | 286.2 (73.1) | 75.3 (58.8) | 486.6 (78.9) |
| 25–29 | 749.5 (84.3) | 391.4 (91.7) | 358.1 (77.6) | 111.7 (70.8) | 637.8 (82.3) |
| 30–34 | 682.9 (87.2) | 353.8 (95.6) | 329.1 (79.8) | 104.7 (76.3) | 578.2 (89.6) |
| 35–39 | 616.7 (88.6) | 314.3 (96.6) | 302.4 (81.6) | 96.9 (78.6) | 519.8 (90.8) |
| 40–44 | 438.8 (88.3) | 193.8 (97.0) | 244.9 (82.4) | 71.9 (77.8) | 366.8 (90.7) |
| 45–49 | 368.5 (88.6) | 169.8 (97.0) | 198.7 (82.5) | 56.7 (78.0) | 311.8 (90.8) |
| 50–54 | 269.6 (86.3) | 127.1 (96.0) | 142.4 (79.1) | 37.1 (73.4) | 232.6 (88.8) |
| 55–59 | 210.4 (81.9) | 102.7 (93.2) | 107.7 (73.4) | 24.1 (64.7) | 186.3 (84.8) |
| 60–64 | 144.0 (70.3) | 74.4 (85.9) | 69.6 (58.8) | 13.8 (48.6) | 130.2 (73.8) |
| សរុប | 4,594.5 | 2,229.5 | 2,365.1 | 652.7 | 3,941.9 |

*សំគាល់: (១) តួលេខនិយាយតែអំពីកំលាំងពលកម្មដែលមានការងារធ្វើប៉ុណ្ណោះ ។ (២) តួលេខនៅក្នុងរង្វង់ក្រចក គឺជាភាគរយនៃចំនួនប្រជាជនក្នុងផ្នែកនិមួយៗ ។ ប្រភព: ជំរឿន ឆ្នាំ១៩៩៨ ។*

របាយកំលាំងពលកម្ម (សំរាប់ក្រុមអាយុទាំងអស់) គិតតាមតំបន់ និងប្រភេទការងារមានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងតារាង ២.១ ។ តារាងនេះបង្ហាញនូវកំរិតនៃការពឹងពាក់លើវិស័យកសិកម្ម ដោយមានប្រជាជនសរុបចំនួន ៧៧% ធ្វើការក្នុងវិស័យកសិកម្ម ដែលក្នុងនោះមានដល់ទៅ ៦៣% បានត្រឹមតែរស់រានដោយសារការធ្វើកសិកម្ម ។ ១/៣ នៃប្រជាជនក្នុងតំបន់ទីក្រុងក៏បានពឹងពាក់លើវិស័យកសិកម្មផងដែរសំរាប់ជីវភាពរបស់ពួកគេ ។ ដូចនេះ មានតំរូវការជាបន្ទាន់មួយក្នុងការបង្កើនមូលដ្ឋានការងារក្រៅពីកសិដ្ឋាន ក៏ដូចជាការកាត់បន្ថយការពឹងពាក់ខ្លាំងទៅលើកសិកម្មដើម្បីគ្រាន់តែរស់ ។

តារាង ១.៣ បង្ហាញនូវចំនួនកំលាំងពលកម្មដែលគេបានប៉ាន់ស្មានដោយផ្អែកលើរបាយអាយុបច្ចុប្បន្ន អត្រាមរណភាព និង អត្រាចូលរួមពលកម្មក្នុងឆ្នាំ១៩៩៣ និង ២០០៣ (ការប៉ាន់ស្មានលំអិត មានបង្ហាញច្បាស់លាស់នៅក្នុងតារាង ២.២) ។

៤ ជំរឿន (1998), P.20.

តួលេខទាំងនេះបង្ហាញនូវការកើនឡើង ២០% តាមការប៉ាន់ស្មានក្នុងកំលាំងពីឆ្នាំ១៩៩៨ ដល់ ២០០៣ ដែលជាការកើនឡើង ៤% ក្នុងមួយឆ្នាំគិតជាមធ្យម ។ ដោយសារមានបន្ទុកលើសចំណុះរួចស្រាប់ហើយទៅលើវិស័យកសិកម្ម ការណ៍នេះគឺដាក់សម្ពាធយ៉ាងធំធេងទៅលើការប្រឹងប្រែងបង្កើតការងារ ជាពិសេសនៅក្នុងវិស័យក្រៅពីកសិដ្ឋាន ។

**ក្រាហ្វិក ១.១. របាយអាយុ នៃប្រជាជនកម្ពុជា គិតតាមភេទ ឆ្នាំ១៩៩៨**




*ប្រភព: ជំរឿន ឆ្នាំ ១៩៩៨*

**តារាង ១.២. ចំនួនការងារ គិតតាមតំបន់ និង ប្រភេទការងារ សំរាប់ក្រុមអាយុទាំងអស់ នៅឆ្នាំ១៩៩៨**

| | ទីក្រុង | ជនបទ | សរុប |
|---|---|---|---|
| កសិកម្ម | 227,201 | 3,518,116 | 3,745,317 |
| អ្នកធ្វើកសិកម្មសំរាប់តែរស់ , អ្នកនេសាទ និងអ្នកធ្វើការងារពាក់ព័ន្ធ | 180,216 | 2,849,480 | 3,029,696 |
| ឧស្សាហកម្ម * | 49,814 | 100,395 | 150,209 |
| ផ្សេងៗទៀត * | 396,597 | 553,639 | 950,236 |
| សរុប | 673,612 | 4,172,150 | 4,845,762 |
| | | **ភាគរយនៃចំនួនសរុប** | |
| កសិកម្ម | 33.7 | 84.3 | 77.3 |
| អ្នកធ្វើកសិកម្មសំរាប់តែរស់ , អ្នកនេសាទ និងអ្នកធ្វើការងារពាក់ព័ន្ធ | 26.8 | 68.3 | 62.5 |
| ឧស្សាហកម្ម | 7.4 | 2.4 | 3.1 |
| ផ្សេងៗទៀត | 58.8 | 13.3 | 19.6 |
| សរុប | 100.0 | 100.0 | 100.0 |

* *ការឱ្យនិយមន័យពាក្យ វិស័យ នៅក្នុងជំរឿន ១៩៩៨ ខុសពីនិយមន័យនៅក្នុងគណនីជាតិ ។ ជំរឿនដាក់សកម្មភាពសាងសង់នៅក្នុងវិស័យសេវាកម្ម ( នៅត្រង់ផ្សេងៗ) រីឯគណនីជាតិដាក់ការសាងសង់ចូលទៅក្នុងវិស័សឧស្សាហកម្ម ។ សំរាប់គោលបំណងនៃរបាយការណ៍នេះ យើងធ្វើការវិភាគតាមគណនីជាតិ រីឯតារាងខាងលើដាក់សកម្មភាពសាងសង់តាមនិយមន័យជំរឿន ។ ប្រភព: គណនាពីជំរឿន ឆ្នាំ១៩៩៨ ។*

ការប៉ាន់ស្មានដំបូងស្តីពីកំលាំងពលកម្ម និងផលិតភាពពលកម្មពឹងផ្អែកលើការអង្កេតសង្គមកិច្ចសេដ្ឋកិច្ច ការអង្កេតកំលាំង ពលកម្ម និងការអង្កេតវិទ្យាសាស្ត្រដែលបានមកពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក៏ដូចជាការប៉ាន់ស្មាន ផសស របស់ ក្រសួងហិរញ្ញវត្ថុ ។ ការប៉ាន់ស្មានទាំងនេះ គ្រាន់តែផ្តល់ជាគំនិតព្រាលៗប៉ុណ្ណោះ អំពីស្ថានការណ៍ ពីព្រោះគ្មានតួលេខណាដែល គេទទួលស្គាល់ជាទូទៅឡើយ ។ ជំរឿនឆ្នាំ១៩៩៨

ឥឡូវនេះផ្តល់ឱ្យយើងនូវតួលេខច្បាស់លាស់តែមួយគត់អំពីប្រជាជន និង លក្ខណៈនៃកំលាំងពលកម្ម ។ ក៏ប៉ុន្តែនៅពេលគ្មានស្ថិតិស្រដៀងគ្នានេះអំពី ផសស និងសន្ទស្សន៍ផ្សេងទៀត យើងមិនប៉ុនប៉ងធ្វើ ការវិភាគលើផលិតភាព និងចលនារវាងផ្នែកផ្សេងៗនៃពលកម្មទេ នៅក្នុងរបាយការណ៍នេះ ។

**តារាង ១.៣. សង្ខេបការប៉ាន់ស្មានកំលាំងពលកម្ម ពីឆ្នាំ១៩៩៣ ដល់ ២០០៣ (គិតជាពាន់នាក់)**

| ក្រុមអាយុ (ឆ្នាំ) | ចំនួនកំលាំងពលកម្មកែតំរូវវិញ ឆ្នាំ១៩៩៣ | កំលាំងពលកម្ម ឆ្នាំ១៩៩៨ | ចំនួនកំលាំងពលកម្មកែតំរូវវិញ ឆ្នាំ២០០៣ |
|---|---|---|---|
| 10–14 | 61.5 | 74.9 | 79.0 |
| 15–19 | 366.0 | 652.7 | 796.3 |
| 20–24 | 744.9 | 615.9 | 1,093.6 |
| 25–29 | 702.9 | 785.4 | 648.5 |
| 30–34 | 643.6 | 704.2 | 777.0 |
| 35–39 | 461.7 | 631.9 | 694.4 |
| 40–44 | 381.7 | 448.2 | 616.2 |
| 45–49 | 292.3 | 376.4 | 434.5 |
| 50–54 | 235.4 | 275.7 | 351.8 |
| 55–59 | 178.6 | 215.6 | 252.3 |
| 60–64 | 130.2 | 148.5 | 171.8 |
| 65–69 | 35.9 | 48.7 | 54.1 |
| Total | 4,235.2 | 4,979.9 | 5,969.7 |

*ប្រភព: គណនាពីជំរឿន ឆ្នាំ១៩៩៨*

## ១.២ ការអភិវឌ្ឍន៍វិស័យផលិត

ការអនុវត្តន៍ម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា សំរេចបានល្អក្នុងឆ្នាំ១៩៩៩ ។ ទោះបីជា ផសស ពិត បានកើន ១.០% នៅក្នុងឆ្នាំ១៩៩៨ គឺដូចគ្នានឹងឆ្នាំ១៩៩៧ ក៏ដោយ ក៏សកម្មភាពសេដ្ឋកិច្ចដែលគ្រាន់បើជាងមុនបានបង្កើនកំណើនដែលគេប៉ាន់ស្មានដល់ ៤.៥% ក្នុងឆ្នាំ១៩៩៩ (តារាង ១.៤) ។ ទោះបីជាតារាង ១.៤ បង្ហាញនូវអគ្រាថយចុះក្នុងកសិកម្មក៏ដោយ ក៏តួលេខទាំងនេះមិនស៊ីគ្នានឹងស្ថិតិផលិតកម្មកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលបង្ហាញនូវកំនើនគួរឱ្យកត់សំគាល់ទាំងក្នុងផ្ទៃដីដាំក្នុងទាំងទិន្នផលនៃដំណាំសំខាន់ ៗក្នុងឆ្នាំ១៩៩៩ (តារាង ១.៥)។ ការរើបឡើងវិញនៅក្នុងវិស័យឧស្សាហកម្ម ជាចំបងបណ្តាលមកពីលទ្ធផលនៃការរីកដុះដាលនៃឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដែលមានការនាំចេញបានចំនួន ៩៩៨លានដុល្លារ (ទោះបីជាសហរដ្ឋអាមេរិកកំណត់កូតាក៏ដោយ) និងបណ្តាលមកពីកំណើននៅក្នុងសកម្មភាពសាងសង់ដែលមានហិរញ្ញប្បទានជាចំបងពីជំនួយអន្តរជាតិទ្វេភាគី និងពហុភាគី ។ ការអភិវឌ្ឍន៍នៅក្នុងវិស័យសេវាកម្ម ជាចំបងបានមកពីកំណើនសកម្មភាពទេសចរណ៍ ដែលបណ្តាលមកពីស្ថេរភាពនយោបាយ និងសន្តិសុខល្អជាងមុន ។ ជាលទ្ធផលនៃការអភិវឌ្ឍន៍ទាំងនេះ ផសស ក្នុងមនុស្សម្នាក់បានកើនឡើងដល់ ២៦២ដុល្លារក្នុងមួយឆ្នាំ កាលពីឆ្នាំ១៩៩៩ ក្រោយពីធ្លាក់ចុះដល់ ២៥១ដុល្លារក្នុងឆ្នាំ១៩៩៨ ។

ក្រោយពីបានកើនឡើងដល់ពីរខ្ទង់ នៅឆ្នាំ១៩៩៨ បណ្តាលមកពីបញ្ហាក្នុងពីរឆ្នាំមុន អតិផរណាបានធ្លាក់ចុះដល់ ៤% ជាការឆ្លុះបញ្ចាំងឱ្យឃើញនូវការប្រមូលផលស្រូវបានល្អក្នុងតំបន់នៅឆ្នាំ១៩៩៨-១៩៩៩ ។ ការណ៍នេះបានកាត់បន្ថយថ្លៃស្បៀង ។ ក្នុងអំឡុងឆ្នាំ១៩៩៩ ប្រាក់រៀលបានចុះថ្លៃបន្តិចប៉ុណ្ណោះ (តិចជាង ១%) ធៀបទៅនឹងកំរិតអតិផរណា ១៣% ក្នុងឆ្នាំ១៩៩៨ ។ សន្ទស្សន៍នេះក៏បង្ហាញពីស្ថិរភាពខាងរូបិយវត្ថុដែរ ។

រដ្ឋាភិបាលបន្តដំណើរការលើឱនភាពគណនីមូលធន និងចរន្ត ថ្វីបើឱនភាពទូទៅបានធ្លាក់ចុះក្នុងឆ្នាំ១៩៩៩ ក៏ដោយ (តារាង ១.៤) ។ ថ្វីបើការនាំចូលបានកើនក្នុងឆ្នាំ១៩៩៩ អាចនាំទៅដល់ការកាត់បន្ថយឱនភាពពាណិជ្ជកម្មក៏ដោយ ក៏កំណើនទាំងនេះត្រូវបានកាត់បន្ថយវិញដោយកំនើនវិនិយោគផ្ទាល់ពីបរទេស កំនើននាំចេញសំលៀកបំពាក់ និងកំនើនទេសចរណ៍ ។ បំណុលបរទេសនៅតែបន្តកើនឡើងក្នុងឆ្នាំ១៩៩៨ និង ១៩៩៩ ក៏ប៉ុន្តែអត្រាសងបំណុលរបស់កម្ពុជានៅមានកំរិតទាបនៅឡើយ និងមិនក្លាយជាបញ្ហាធំដុំទេ ល្គិកណាសកម្មភាព សេដ្ឋកិច្ចនៅតែបន្តកើនឡើងជាប់រហូតក្នុងរយៈពេលខ្លី ។

**តារាង ១.៤. អាំងឌីកាទ័រម៉ាក្រូសេដ្ឋកិច្ចជាមូលដ្ឋាននៅកម្ពុជា**

| | 1995 | 1996 | 1997 | 1998 | 1999E |
|---|---|---|---|---|---|
| អត្រាកំណើន ផសស ពិត | 7.6 | 7.0 | 1.0 | 1.0 | 4.5 |
| កសិកម្ម | 10.5 | 0.8 | 1.4 | -0.1 | 1.4 |
| ឧស្សាហកម្ម | 6.8 | 17.9 | 2.4 | 6.1 | 10.6 |
| សេវាកម្ម | 4.5 | 10.7 | -10.0 | 0.3 | 5.5 |
| ផសស ក្នុងមនុស្សម្នាក់ ($) | 284 | 292 | 276 | 251 | 262 |
| សញ្ចយដុលក្នុងស្រុក (% នៃ ផសស) | 3.3 | 3.8 | 3.5 | 2.7 | 2.4 |
| វិនិយោគដុលក្នុងស្រុក (% នៃ ផសស) | 8.5 | 9.7 | 6.9 | 5.7 | 5.3 |
| អត្រាកំណើននៃ CPI (មធ្យមប្រចាំឆ្នាំ) | 7.8 | 7.1 | 8.1 | 14.7 | 4.0 |
| អត្រាកំណើន នៃ money supply (M2) | 44.4 | 40.3 | 16.6 | 15.7 | 17.2 |
| អត្រាប្តូរប្រាក់ (riels/dollar មធ្យមប្រចាំឆ្នាំ) | 2,462 | 2,641 | 3,000 | 3,800 | 3,820 |
| **ប្រតិបត្តិការរដ្ឋាភិបាល (គិតជា % នៃ ផសស)** | | | | | |
| ចំណាយ | 16.7 | 17.5 | 13.8 | 14.2 | 16.4 |
| ចំណូល | 8.9 | 9.1 | 9.7 | 8.6 | 11.2 |
| អតិរេក ឬ ឱនភាពថវិកា សរុបរួមគ្នា | -7.7 | -8.4 | -4.2 | -5.6 | -5.2 |
| សមតុល្យជញ្ជីងទូទាត់ **(Balance of payments)** | | | | | |
| អត្រាកំណើននាំចេញទំនិញ (%) | 75.5 | -17.5 | 5.7 | -0.1 | 31.2 |
| អត្រាកំណើននាំចូលទំនិញ (%) | 57.4 | -2.3 | -9.1 | -1.3 | 27.6 |
| សមតុល្យពាណិជ្ជកម្ម (គិតជាលានដុល្លារ) | -377 | -499 | -349 | -335 | -401 |
| សមតុល្យគណនីចរន្ត (គិតជាលានដុល្លារ) | -403 | -487 | -312 | -314 | -359 |
| សមតុល្យគណនីចរន្ត (គិតជា % នៃ ផសស) | 13.8 | 15.6 | 10.3 | 11.0 | 11.6 |
| វិនិយោគបរទេសផ្ទាល់ (គិតជាលានដុល្លារ) | 151 | 240 | 150 | 120 | 150 |
| **បំណុលបរទេស** | | | | | |
| បំណុលបរទេសដែលនៅជំពាក់ (គិតជាលានដុល្លារ) | 131 | 222 | 259 | 308 | 351 |
| អត្រាសងបំណុល (ចំនួនសងគិតជា % នៃចំណូលនាំចេញ) | 0.45 | 2.7 | - | 0.13 | 0.13 |

*E- ប៉ាន់ស្មានដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ: Sok (2000)*

## *១.២.១ កសិកម្ម*

កសិកម្ម គឺជាចំណែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចកម្ពុជា ។ ក្រៅពីការផ្តល់ការងារដល់ប្រជាជនចំនួន ៧៧% កសិកម្មមានចំណែក ៣៥% នៃ ផសស ក្នុងឆ្នាំ១៩៩៩ ។ តារាង ១.៥ បង្ហាញនូវផ្ទៃដីដាំដុះ និងផលិតផលនៃដំណាំសំខាន់ៗជាងគេ ។ ស្រូវមានកំរិតខ្ពស់ជាងគេបំផុតក្នុងតារាង ដោយមានផ្ទៃដីដាំដុះ ជាង២លានហិកតា និងទិន្នផលជាមធ្យម ជិត២តោនក្នុងមួយហិកតា (តារាង ១.៥ និង ១.៦) ។ តារាង ១.៥ បង្ហាញឱ្យឃើញផងដែរ នូវផ្ទៃដីដាំដុះ និងផលិតផលដំណាំផ្សេងៗទៀតដែលបានធ្លាក់ចុះក្នុងឆ្នាំ១៩៩៨-៩៩ ក៏ប៉ុន្តែ វាកើនឡើងវិញនៅឆ្នាំ១៩៩៩-២០០០ ។ ដំណាំទាំងអស់មានទិន្នផលកើនឡើងនៅ

អំឡុងឆ្នាំ១៩៩៩-២០០០ ដែលជាលទ្ធផលនៃអាកាសធាតុល្អប្រសើរក្នុងប្រទេស ។ ការឡើងចុះនៅក្នុងការផ្គត់ផ្គង់ផលិតផលកសិកម្ម គឺបណ្តាលមកពីកង្វះខាតប្រព័ន្ធស្រោចស្រពដែលធ្វើឱ្យផលិតកម្មកសិកម្មមួយភាគធំពឹងផ្អែកលើទឹកភ្លៀង ។ ក៏ប៉ុន្តែកង្វះខាតស្ថិតិអំពីប្រព័ន្ធស្រោចស្រពមិនអាចធ្វើឱ្យមានការវិភាគលើសពីនេះទៀតទេ ។ ផលិតផលស្រូវលើសក្នុងឆ្នាំ១៩៩៨-៩៩ មានចំនួន ៣០.០៧០តោនអង្ករ នៅឆ្នាំ១៩៩៩-២០០០ មានចំនួន ២៦០.៧១០តោនអង្ករ ដែលធ្វើឱ្យការនាំចេញស្រូវកាន់តែកើនឡើង ។ ដើម្បីថែរក្សាផលលើសក្នុងផលិតកម្មស្រូវគេត្រូវលើកកំពស់ឧបករណ៍កែច្នៃស្រូវ និងលក្ខខណ្ឌផ្លូវថ្នល់ ។ របាយការណ៍ប្រទេសរបស់ EIU នៅឆ្នាំ១៩៩៩ បានថ្លែងថា គំរោងកែច្នៃស្រូវជាច្រើនទាក់ទងនឹងវិនិយោគបរទេសកំពុងនៅរាំងស្ទះដោយសារជំលោះដីធ្លី ។ ម៉ាស៊ីនកិនស្រូវបច្ចុប្បន្នមានអាយុច្រើន ហើយមិនអាចបំពេញស្តង់ដាអន្តរជាតិបានទេដែល ជាមូលហេតុធ្វើឱ្យឈ្មួញថៃ និងវៀតណាមទិញស្រូវពីកម្ពុជាដើម្បីកែច្នៃនៅកន្លែងផ្សេងទៀត ។ ការណ៍នេះបង្ហាញនូវការខាតបង់ចំណូលសក្តានុពលសំរាប់កម្ពុជា ។

**តារាង ១.៥. ផ្ទៃដីដាំដុះ និង ផលិតផល នៃដំណាំចំបងៗ ១៩៩៥ -២០០០** [៥]

| | 1995–96 | 1996–97 | 1997–98 | 1998–99 | 1999–2000 |
|---|---|---|---|---|---|
| | | ផ្ទៃដីដាំដុះ ( គិតជាពាន់ហិកតា ) | | | |
| ស្រូវ | 2,086 | 2,171 | 2,076 | 2,104 | 2,157 |
| ពោត | 52 | 49 | 52 | 40 | 58.8 |
| បន្លែ | 42 | 46 | 44 | 38 | 45 |
| សណ្តែកបាយ | 26 | 28 | 27 | 25 | 29 |
| សណ្តែកសៀង | 17 | 29 | 33 | 31 | 35 |
| ល្ង | **9** | **12** | **17** | **15** | **16** |
| | | ផលិតកម្មសរុប ( គិតជាពាន់តោន ) | | | |
| ស្រូវ | 3,448 | 3,458 | 3,415 | 3,510 | 4,029 |
| ពោត | 55 | 64 | 67 | 49 | 69 |
| បន្លែ | 193 | 249 | 250 | 217 | 214 |
| សណ្តែកបាយ | 20 | 14 | 15 | 9 | 14 |
| សណ្តែកសៀង | 17 | 28 | 34 | 28 | 33 |
| ល្ង | 4 | 5 | 7 | 5 | 8 |

*ប្រភព : ស្ថិតិកសិកម្ម ( ច្រើនឆ្នាំរួមគ្នា ) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*

**តារាង ១.៦. ទិន្នផល នៃដំណាំកសិកម្ម គិតជាតោន ក្នុង១ហិកតា ១៩៩៥ - ១៩៩៩**

| | 1995–96 | 1996–97 | 1997–98 | 1998–99 | 1999–2000 |
|---|---|---|---|---|---|
| ស្រូវ | 1.79 | 1.83 | 1.77 | 1.79 | 1.94 |
| ពោត | 1.22 | 1.37 | 1.24 | 1.22 | 1.27 |
| បន្លែ | 4.92 | 5.96 | 5.1 | 5.88 | 5.91 |
| សណ្តែកបាយ | 0.78 | 0.51 | 0.56 | 0.56 | 0.58 |
| សណ្តែកសៀង | 1.07 | 1.69 | 1.72 | 0.89 | 0.95 |
| ល្ង | 0.45 | 0.45 | 0.20 | 0.54 | 0.55 |

*ប្រភព : ស្ថិតិកសិកម្ម (ច្រើនឆ្នាំរួមគ្នា)*

ផលិតកម្មសត្វពាហនៈ និងបសុបក្សី ក៏បានបង្ហាញឱ្យឃើញនូវនិន្នាការដូចផលិតកម្មដំណាំដែរ ។ នៅឆ្នាំ១៩៩៨ ផលិតកម្មសត្វពាហនៈមានការធ្លាក់ចុះ រីឯផលិតកម្មបសុបក្សីនៅតែកើនឡើង ។ ទាំងផលិតកម្មសត្វពាហនៈ ទាំងផលិតកម្មបសុបក្សី សុទ្ធតែមានកំណើននៅក្នុងឆ្នាំ១៩៩៩ ជាពិសេសផលិតកម្មសត្វពាហនៈដែលបានធ្លាក់ចុះ ៦.៧% ក្នុងឆ្នាំ១៩៩៨ ។ ផលិតកម្មបសុបក្សីកើនឡើងខ្ពស់ជាងគេបំផុតបើគិតក្នុងរយៈពេល ៥ឆ្នាំ កន្លងមក (តារាង ១.៧) ដែលបណ្តាលមកពីកំណើន

៥ ឆ្នាំទាំងនេះគឺ ឆ្នាំច្រូតកាត់ ឧទាហរណ៍ ពីខែមិថុនា - ឧសភា ។

តំរូវការពីវិស័យទេសចរណ៍ ( ឧទាហរណ៍ ភោជនីយដ្ឋាន) ។

**តារាង ១.៧. ផលិតកម្មសត្វពាហនៈ និង បសុបក្សី ១៩៩៥ - ១៩៩៩**

| | 1995 | 1996 | 1997 | 1998 | 1999 |
|---|---|---|---|---|---|
| | | | គិតជាពាន់ក្បាល | | |
| គោ | 2,778 | 2,762 | 2,872 | 2,680 | 2,887 |
| ក្របី | 765 | 744 | 766 | 694 | 696 |
| ជ្រូក | 2,039 | 2,151 | 2,237 | 2,339 | 2,362 |
| បសុបក្សី | 10,067 | 11,412 | 11,982 | 13,117 | 15,084 |
| | | | ការប្រែប្រួលធៀបនឹងឆ្នាំមុន គិតជាភាគរយ | | |
| គោ | 5.9 | -0.6 | 4.0 | -6.7 | 7.7 |
| ក្របី | -6.0 | -2.7 | 3.0 | -9.4 | 0.3 |
| ជ្រូក | 1.8 | 5.5 | 4.0 | 4.6 | 0.98 |
| បសុបក្សី | -0.3 | 13.4 | 5.0 | 9.5 | 15.0 |

*ប្រភព: ស្ថិតិកសិកម្ម ( ច្រើនឆ្នាំរួមគ្នា )*

ស្ថិតិផលិតផលត្រីក៏បានបង្ហាញឱ្យឃើញថា បរិមាណផលត្រីសរុបដែលចាប់បាននៅក្នុងឡូនេសាទ កើនឡើងនៅក្នុងឆ្នាំ ១៩៩៨ និង ១៩៩៩ ( តារាង ១.៨) លើកលែងតែត្រីទឹកសាប ។ នេសាទ គឺជាប្រភពសំខាន់មួយនៃជីវភាពសំរាប់ប្រជាជន ជនបទកម្ពុជាជាច្រើននាក់ ។ ករណីសិក្សាមួយរបស់ Kato (1999a) ស្តីអំពីភាពគ្មានដីនៅក្នុងភូមិមួយនៅកំពង់រាបដែលស្ថិតនៅក្នុងឡូនេសាទមួយបង្ហាញឱ្យឃើញនូវការធ្លាក់ចុះស្តុកត្រីក្នុងទសវត្សន៍ទី៩0 ។ ការធ្លាក់ចុះទាំងនេះ អាចបណ្តាលមកពីការបាត់បង់ព្រៃលិចទឹក និងការប្រើប្រាស់វិធីនេសាទខុសច្បាប់ និងបែបបំផ្លាញ ដូចជាការឆក់ត្រី ការដាក់មងក្រឡាតូចពេក និងការនេសាទក្នុងរដូវហាមឃាត់ ។ ស្ថានភាពស្រដៀងគ្នានេះ ទំនងជាកើតមាននៅទីកន្លែងផ្សេងទៀតលើផ្ទៃប្រទេស ដែលជាការបញ្ជាក់ថា គេត្រូវគិតគូរយ៉ាងម៉ត់ចត់អំពីការគ្រប់គ្រងធនធានរួមនៅកម្ពុជា ។ មានស្ថានភាពស្រដៀងគ្នានេះដែរ នៅក្នុងផ្នែកព្រៃឈើដែលជាប្រភពសំខាន់មួយទៀតសំរាប់ចំណូល និងជីវភាព ។ ឈើកែច្នៃ និងកៅស៊ូធម្មជាតិ គឺជាកសិទំនិញពីរផ្នែកធំជាងគេដែលនាំចេញពីកម្ពុជា ។ ការធ្វើអាជីវកម្មព្រៃឈើលើសកំរិតដែលចាប់ផ្តើមឡើងដោយការកាប់ឈើខុសច្បាប់ទ្រង់ទ្រាយធំកំពុងបណ្តាលឱ្យមានការបាត់បង់យ៉ាងខ្លាំងនៅក្នុងចំណូលថវិការដ្ឋ ។ ប្រសិនបើគ្មានការត្រួតពិនិត្យការណ៍នេះអាចកាត់បន្ថយសក្តានុពលពាណិជ្ជកម្មនៃធនធានព្រៃឈើរបស់កម្ពុជាក្នុងរយៈពេលតិចជាង ៥ឆ្នាំ ខាងមុខ [៦] ។

**តារាង ១.៨. ចំនួនផលិតផលត្រីសរុប ១៩៩៥-១៩៩៩**

| | 1995 | 1996 | 1997 | 1998 | 1999 |
|---|---|---|---|---|---|
| | | | តោន | | |
| ត្រីសរុប | 112,510 | 104,310 | 114,600 | 120,400 | 123,450 |
| ត្រីទឹកសាប | 72,500 | 63,510 | 73,000 | 75,700 | 71,000 |
| ត្រីទឹកប្រៃ | 30,500 | 31,200 | 29,800 | 32,200 | 38,000 |
| ត្រីចិញ្ចឹម | 9,510 | 9,600 | 11,800 | 12,500 | 14,450 |
| | | | ការប្រែប្រួលធៀបនឹងឆ្នាំមុន គិតជាភាគរយ | | |
| ត្រីសរុប | 9.0 | -7.3 | -1.4 | 5.0 | 2.5 |
| ត្រីទឹកសាប | 11.0 | -12.4 | 14.9 | 3.7 | -6.2 |
| ត្រីទឹកប្រៃ | 1.7 | -2.3 | -4.5 | 8.1 | 15.6 |
| ត្រីចិញ្ចឹម | n.a. | 1.0 | 22.9 | 5.9 | 15.6 |

៦ World Bank (1999:53)

*សំគាល់: ត្រីទឹកសាបសរុបគឺជាត្រីដែលចាប់បាននៅក្នុងឡូនេសាទប៉ុណ្ណោះ ។ ការនេសាទតាមគ្រួសារមិនត្រូវបានរាប់បញ្ចូលទេ ។ សំរាប់ឆ្នាំ១៩៩៩ ការនេសាទតាមគ្រួសារមានចំនួន ១១៥ ០០០តោន ហើយការចាប់ត្រីតាមវាលស្រែមានចំនួន ៤៥ ០០០តោន ។ ប្រភព: ស្ថិតិកសិកម្ម (ច្រើនឆ្នាំរួមគ្នា) ។*

### *១.២.២ ឧស្សាហកម្ម*

កម្មន្តសាលមានចំណែកប្រហែល ២០%នៃផសស ហើយបើតាមជំរឿន វាផ្តល់ការងារឱ្យ ៣% នៃកំលាំងពលកម្ម[៧] ក្នុងឆ្នាំ១៩៩៨ ។ ទោះបីជាឧស្សាហកម្មមានកំនើនយឺតនៅក្នុងឆ្នាំ១៩៩៧ ដោយសារវិបត្តិទាំងពីរខាងលើក៏ដោយ ក៏វានៅតែមានកំណើនវិជ្ជមាន និងនិន្នាការឈានឡើង ចាប់តាំងពីឆ្នាំ១៩៩៥មក (តារាង ៤.១) ។ ការវិនិយោគក្នុងស្រុក និងការវិនិយោគបរទេសនៅក្នុងវិស័យឧស្សាហកម្មមិនទាន់រីបឡើងពេលលេញទេ ដូចដែលគេបានឃើញស្រាប់អំពីចំនួនគំរោងវិនិយោគដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ។ ក្នុងឆ្នាំ១៩៩៩ មានគំរោងចំនួន ៩៥ ដែលមានតំលៃ ៤៦៤ លានដុល្លារ ត្រូវបានអនុម័ត ដែលជាការធ្លាក់ចុះអស់ ៤៤% ធៀបនឹងឆ្នាំមុន[៨] ។

ផ្នែកចំបងបំផុតនៅក្នុងកម្មន្តសាល គឺឧស្សាហកម្មសំលៀកបំពាក់ និងវាយនភ័ណ្ឌដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ ដើម្បីជំរុញការនាំចេញជាចំបង ។ ទោះបីជា ចំនួនអាជ្ញាប័ណ្ណសំរាប់ឧស្សាហកម្មសំលៀកបំពាក់ដែលបានផ្តល់ឱ្យមានការធ្លាក់ចុះក៏ដោយ ក៏ផលិតកម្ម និងការនាំចេញនៅតែបន្តកើនឡើងយ៉ាងខ្ពស់ ។ ការដាក់កូតាដោយសហរដ្ឋអាមេរិកដែលជាទីផ្សារចំបងចាប់តាំងពីឆ្នាំ១៩៩៧ មក បានដាក់ជាកំរិតចំពោះលទ្ធភាពពង្រីកបន្ថែម ។ ការចរចារជាមួយសហរដ្ឋអាមេរិកកំពុងបន្តដោយមានគោលដៅកែប្រែការដាក់កំរិតនេះឱ្យបានខ្ពស់ជាងអត្រា ៦% ក្នុងមួយឆ្នាំ ដែលគេកំពុងអនុញ្ញាត ។ នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០០០ ការនាំចេញសំលៀកបំពាក់បានកើនឡើង ៤៧% ដែលជាកំរិតខ្ពស់ជាងគេបំផុត គឺឡើងដល់ ១៩៥ លានដុល្លារ[៩] ។

យោងតាមនិយមន័យដែលគេបានប្រើប្រាស់នៅក្នុងគណនីជាតិ ឧស្សាហកម្មរួមមាន រ៉ែ កម្មន្តសាល និងសំណង់ ។ នៅខណៈដែលគេមិនអាចរកបានស្ថិតិលំអិត មានការរាយការណ៍ថា "…. កម្មន្តសាលធំបំផុតត្រូវបានអនុវត្តបែបក្រៅផ្លូវការ និងមានទ្រង់ទ្រាយតូចៗ ។ សកម្មភាពកម្មន្តសាលដូចជាការផលិតឥដ្ឋ និងសេរ៉ាមិក មានចំណងទាក់ទងគ្នាជាមួយនឹងសកម្មភាពសំណង់"[១០] ។ ការប្រព្រឹត្តិទៅនៃឧស្សាហកម្មក្នុងឆ្នាំ១៩៩៨ និង ១៩៩៩ មានកំរិតគួរជាទីមោទនៈសំរាប់អនាគតរបស់កម្ពុជា។ ការនេះនឹងជួយផ្ទេរពលកម្មដែលលើសនៅក្នុងវិស័យកសិកម្មឱ្យមានការងារដែលទទួលបានចំណេញច្រើនជាង ។ ការកើនឡើងនៅក្នុងផ្នែកសំណង់ គឺបណ្តាលមកពីការសាងសង់រោងចក្រកាត់ដេរចំនួនរាប់រយក៏ដូចជាសណ្ឋាគារថ្មីៗជាច្រើន ។ ការណ៍នេះគឺមកពីមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសង្គម ដែលជាចំបងត្រូវបានធ្វើហិរញ្ញប្បទានដោយរដ្ឋាភិបាលក្រោមជំនួយទ្វេភាគី និង ពហុភាគី[១១] ។

### *១.២.៣ សេវាកម្ម*

វិស័យសេវាកម្មដែលមានពាណិជ្ជកម្មលក់ដុល និងលក់រាយ, សណ្ឋាគារ និងភោជនីយដ្ឋាន, គមនាគមន៍ និងទំនាក់ទំនង,

---

៧ ដូចកត់សំគាល់ខាងលើរួចហើយ និយមន័យនៅក្នុងជំរឿន អំពីឧស្សាហកម្មកម្មន្តសាល មិនរាប់បញ្ចូលសកម្មភាពសាងសង់ទេ

៨ ទិន្នន័យរបស់ CDC

៩ តាម ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា (២០០០)

១០ ក្រសួងផែនការ (1999a:29)

១១ តាម ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា (២០០០)

ធនាគារកិច្ច, អចលនវត្ថុ, ជំនួញ និងសកម្មភាពអន្តរការីដទៃទៀតមានតំលៃប្រហែល ៤៥% នៃ ផសស និងផ្តល់ការងារដល់កំលាំងពលកម្មកម្ពុជា ចំនួន ១៧% កាលពីឆ្នាំ១៩៩៨ ។ វិស័យនេះបានទទួលឥទ្ធិពលអវិជ្ជមានពីវិបត្តិឆ្នាំ ១៩៩៧ ដែលធ្វើឱ្យមានកំណើនតិចតួចណាស់នៅក្នុងឆ្នាំ១៩៩៨ ។ ទោះជាដូច្នោះក៏ដោយ វិស័យនេះដំណើរការទៅគួរឱ្យកោតសរសើរនៅពេលដែលយើងពិនិត្យមើលការធ្លាក់ចុះ ១០% ក្នុងឆ្នាំ១៩៩៧ (សូមមើលតារាង ១.៤) ។ នៅឆ្នាំ១៩៩៩ វិស័យនេះបានកើនឡើងយ៉ាងឆាប់រហ័សក្នុងកំរិត ៨,៥% ហើយវាគឺជាកត្តាចំបងដែលជំរុញឱ្យមានកំណើន ៤% នៅក្នុង ផសស ។

វិស័យទេសចរណ៍ ក៏បានទទួលផលចំណេញខ្លាំងផងដែរ ពីការស្តារស្ថិរភាពនៅក្នុងបរិដ្ឋាននយោបាយជាតិឡើងវិញចាប់តាំងពីឆ្នាំ១៩៩៨ ។ ចំនួនអ្នកទេសចរដែលមកតាមព្រលានយន្តហោះពោធិចិនតុងនៅឆ្នាំ១៩៩៨ បានធ្លាក់ចុះ ១៨% បើធៀបនឹងឆ្នាំមុន ក៏ប៉ុន្តែបានកើនឡើងក្នុងកំរិតដូចគ្នានេះវិញកាលពីឆ្នាំ ១៩៩៩ ។ គំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដទៃទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលធ្វើផែនការនៅឡើយ ជាចំបងទទួលមូលនិធិពីជំនួយបរទេស ។ ឧទាហរណ៍ កំពង់ផែព្រះសីហនុបាន និងកំពុងពង្រីកដោយជំនួយពីប្រទេសជប៉ុន ហើយបារាំងបានផ្តល់ជំនួយបច្ចេកទេសដល់ក្រុមហ៊ុនអគ្គិសនីដែលគ្រប់គ្រង ដោយ រដ្ឋ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេសដែលជាជំនួយឥតសំណងចំនួន ១,៤៥លានដុល្លារ ដើម្បីលើកកំពស់ការ គ្រប់គ្រង និងការបង្កើនដំណើរការរបស់ស្ថាប័នដែលផ្តល់សេវាសន្សំ និងកំចីទ្រង់ទ្រាយតូចដែលគេហៅថាមីក្រូហិរញ្ញវត្ថុ [១២] ។

ក្នុងត្រីមាសទី១ នៃឆ្នាំ២០០០ ចំនួនអ្នកដំណើរដែលមកដល់អាកាសយានដ្ឋានពោធិចិនតុងបានកើនឡើងចំនួន ២១% បើធៀបនឹងពេលដូចគ្នាក្នុងឆ្នាំ១៩៩៩ ទោះបីជាចំនួនសរុបនៃអ្នកទេសចរដែលមកដល់ក្នុងប្រទេសបានធ្លាក់ចុះក៏ដោយ ។ ការណ៍នេះ គឺបណ្តាលមកពីកំណើនក្នុងចំនួនអ្នកដំណើរដែលមកសៀមរាបផ្ទាល់ដើម្បីទស្សនាប្រាសាទបុរាណ [១៣] ។

## ១.៣ ថ្លៃ និងអត្រាប្តូរប្រាក់

ស្ថិតិនៅឆ្នាំ១៩៩៨ ស្តីអំពីថ្លៃ បង្ហាញឱ្យឃើញនូវឥទ្ធិពលអវិជ្ជមាននៃវិបត្តិឆ្នាំ១៩៩៧ ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅឆ្នាំ១៩៩៨ កើនឡើងយ៉ាងខ្លាំងរហូតដល់ពេលបោះឆ្នោត ហើយទើបធ្លាក់ចុះវិញ [១៤] ។ អតិផរណាធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុនបានកើនឡើងដល់ ១៧% នៅក្នុងខែមិថុនា ឆ្នាំ១៩៩៨ ។ ការណ៍នេះ ជាចំបងបណ្តាលមកពីប្រជាជនស្តុកស្បៀងទុក និងការធ្លាក់តំលៃប្រាក់រៀលដែលធ្វើឱ្យថ្លៃទំនិញនាំចូលកើនឡើង ។ តួរលេខលំអិតអំពីចលនា CPI មាននៅក្នុងតារាង ១.៩។ អតិផរណាសំរាប់ឆ្នាំទាំងមូលមានកំរិតជិតប្រហែល ១៥% ។ នៅក្នុងឆ្នាំ១៩៩៩ មានការរើបឡើងវិញយ៉ាងល្អដែលជាលទ្ធផលនៃស្ថិរភាពសេដ្ឋកិច្ច និងនយោបាយ, ការថយចុះ ១០% នៃរូបិយវត្ថុនៅក្រៅធនាគារ, និងការឡើងថ្លៃប្រាក់រៀលវិញបន្តិច [១៥] ។ អតិផរណាប្រចាំឆ្នាំ១៩៩៩ មានកំរិតខ្ពស់ជាង ៤% បន្តិចហើយត្រូវបានព្យាករណ៍ថាមានកំរិត ២% ប៉ុណ្ណោះសំរាប់ឆ្នាំ២០០០ ។ ក៏ប៉ុន្តែ គេគួរអានតួលេខទាំងនេះដោយមានការប្រុងប្រយ័ត្ន ។ CPI ត្រូវបានគិតជារៀល ដែលបង្ហាញមិនអស់អំពីផលប៉ះពាល់នៃសេដ្ឋកិច្ចដុល្លារូបនីកម្មដូចជាកម្ពុជា ។ នៅខណៈដែលដុល្លារូបនីកម្មទូទៅទំនងជាជួយបន្ថយឥទ្ធិពលអវិជ្ជមាន

---

១២ EIU (2000)

១៣ តាមទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា (២០០០)

១៤ Economic and Monetary Statistics Review (1998). No. 62 Dec. 1998

១៥ *ibid*

ចំពោះស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច[១៦] ដូចដែលបានកត់សំគាល់នៅក្នុងការសិក្សាពីមុន (Chan *et al.* 1998) វាកាត់បន្ថយភាពយកជាការបានចំពោះ ការចាត់ទុក CPI ដែលគិតជារៀលថា ជាអាំងឌីការទ័រនៃថ្លៃចំណាយសំរាប់ជីវភាពនៅកម្ពុជា (Chan *ibid*) ។

អត្រាប្តូរប្រាក់រៀលដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា (NBC)ដើរតាមគោលនយោបាយអត្រាការប្រាក់ដែលផ្អែកលើទីផ្សារ ។ នៅក្នុងឆ្នាំ១៩៩៨ ប្រាក់រៀលបានធ្លាក់ថ្លៃប្រហែល ១៣% រហូតដល់ពេលបោះឆ្នោត ក៏ប៉ុន្តែមានស្ថិរភាពវិញបន្ទាប់ពីការបង្កើតរដ្ឋាភិបាល ហើយបន្ទាប់មកបានឡើងថ្លៃអស់មួយរយៈ ។ ជាថ្មីម្តងទៀត ដុល្លារូបនីយកម្មទូទៅនៅក្នុងសេដ្ឋកិច្ចបានកាត់បន្ថយប្រសិទ្ធិភាពគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិកម្ពុជា ដែលត្រូវពឹងផ្អែកលើការធ្វើអន្តរាគមន៍ដោយប្រើប្រាស់ដុល្លារដើម្បីធ្វើឱ្យមានស្ថិរភាពអត្រាប្តូរប្រាក់រៀល ។ នៅឆ្នាំ១៩៩៩ ប្រាក់រៀលចុះថ្លៃបន្តិចម្តងៗ ដោយបានឡើងថ្លៃបន្តិចវិញក្នុងខែតុលា ដោយសារមានស្ថិរភាពរដ្ឋាភិបាល ការបន្តឹងសារពើពន្ធ និងការសន្យាបន្តជំនួយបរទេស ។ ជាទូទៅប្រាក់រៀលមានស្ថិរភាពគ្រាន់បើ ។ ការណ៍នេះគឺបណ្តាលមកពីបរិស្ថានសេដ្ឋកិច្ចក្នុងតំបន់ត្រូវបានកែលំអផងដែរ ។ តារាងទី១ នៅក្នុងសេចក្តីបន្ថែម បង្ហាញអំពីចលនានៃអត្រាប្តូរប្រាក់រៀល និងរូបិយប័ណ្ណផ្សេងៗ របស់ប្រទេសអាស៊ានធៀបនឹងប្រាក់ដុល្លារ ។ រូបិយប័ណ្ណភាគច្រើន លើកលែងតែប្រាក់ Kyat របស់ភូមាមានស្ថិរភាពនៅក្នុងឆ្នាំ១៩៩៩ ។

---

១៦ តាមក្រសួងផែនការ (1999a)

**តារាង ១.៩. ការប្រែប្រួលជាភាគរយ នៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅកម្ពុជា**

| | សន្ទស្សន៍ (រយៈពេលគោល July-Sept 1994=100) | ការប្រែប្រួលពីត្រីមាសមួយទៅទីមាសមួយ | ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ |
|---|---|---|---|
| 1995 មធ្យមប្រចាំឆ្នាំ | 103.37 | | |
| ត្រីមាសទី ១ | 101.31 | -2.76 | |
| ត្រីមាសទី ២ | 99.64 | -1.65 | |
| ត្រីមាសទី ៣ | 105.46 | 5.84 | |
| ត្រីមាសទី ៤ | 107.06 | 1.51 | 2.75 |
| 1996 | 110.76 | 7.15 | 7.15 |
| ត្រីមាសទី ១ | 106.05 | -0.94 | 4.68 |
| ត្រីមាសទី ២ | 107.62 | 1.48 | 8.01 |
| ត្រីមាសទី ៣ | 112.68 | 4.70 | 6.85 |
| ត្រីមាសទី ៤ | 116.68 | 3.54 | 8.99 |
| 1997 | 119.58 | 7.96 | 7.96 |
| ត្រីមាសទី ១ | 111.94 | -4.06 | 5.55 |
| ត្រីមាសទី ២ | 114.88 | 2.63 | 6.74 |
| ត្រីមាសទី ៣ | 124.17 | 8.08 | 10.19 |
| ត្រីមាសទី ៤ | 127.32 | 2.54 | 9.12 |
| 1998 | 137.25 | 14.78 | 14.78 |
| ត្រីមាសទី ១ | 129.71 | 1.87 | 15.88 |
| ត្រីមាសទី ២ | 134.43 | 3.64 | 17.02 |
| ត្រីមាសទី ៣ | 141.45 | 5.22 | 13.92 |
| ត្រីមាសទី ៤ | 143.41 | 1.39 | 12.64 |
| 1999 | 142.78 | 4.03 | 4.03 |
| ត្រីមាសទី ១ | 140.76 | -1.85 | 8.52 |
| ត្រីមាសទី ២ | 143.00 | 1.59 | 6.37 |
| ត្រីមាសទី ៣ | 144.01 | 0.71 | 1.81 |
| ត្រីមាសទី ៤ | 143.37 | -0.45 | -0.03 |
| 2000 | | | |
| ត្រីមាសទី ១ | 140.87 | -1.74 | 0.78 |

*Source: Ministry of Planning (2000)*

## ១.៤ ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និង រូបិយវត្ថុ

ស្ថិតិរូបិយវត្ថុ បង្ហាញឱ្យឃើញនូវការប្រសើរឡើងនៅក្នុងឆ្នាំ១៩៩៨ ដោយការផ្គត់ផ្គង់ទាំងរូបិយវត្ថុ M1 កើនឡើង ៤១% និងរូបិយវត្ថុកើនឡើង ១៦% (តារាង ១.១០) ។ កំណើនរូបិយវត្ថុ M1 គឺបណ្តាលមកពីកំណើនដ៏ខ្ពស់នៅក្នុងក្រដាសប្រាក់ដែលនៅក្រៅធនាគារ ។ ក៏ប៉ុន្តែ ការធ្លាក់ចុះបញ្ញើរូបិយប័ណ្ណបរទេស (ដែលបន្តតាំងពីប្រតិកម្មវិបត្តិឆ្នាំ ១៩៩៧) បានកាត់បន្ថយកំណើននៅក្នុងសាច់ប្រាក់នៅក្រៅធនាគារ ហើយនាំឱ្យមានការធ្លាក់ចុះជាទូទៅក្នុងកំណើនសាច់ប្រាក់ងាយស្រួល[១៧] បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ ។ នៅឆ្នាំ១៩៩៩ មានភាពផ្ទុយកើតឡើង (រូបិយប័ណ្ណបរទេសកើនឡើងខ្ពស់) ដែលនាំឱ្យមានអត្រាកំណើនសាច់ប្រាក់ងាយស្រួលខ្ពស់ជាងមុន ។

**តារាង ១.១០. ការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុ និង រូបិយវត្ថុ ១៩៩៥-១៩៩៩**

| | 1995 | 1996 | 1997 | 1998 | 1999 |
|---|---|---|---|---|---|
| | | | I. ចំនួនសាច់ប្រាក់ គិតជា (ពាន់លានរៀល) | | |
| Broad Money (M2) | 650 | 912 | 1,063 | 1,230 | 1,442 |
| Money (M1) | 279 | 329 | 385 | 543 | 532 |
| ក្រដាសប្រាក់នៅក្រៅធនាគារ | 251 | 300 | 356 | 509 | 490 |
| ប្រាក់បញ្ញើគ្មានកំណត់ពេល | 28 | 29 | 29 | 34 | 42 |
| Quasi-money | 371 | 583 | 678 | 687 | 910 |
| ប្រាក់បញ្ញើមានកំណត់ពេល | 5 | 8 | 13 | 20 | 31 |
| បញ្ញើរូបិយប័ណ្ណបរទេស | 366 | 575 | 665 | 667 | 879 |
| | | | II. បំរែបំរួលពីឆ្នាំមុន គិតជា % | | |
| Broad Money (M2) | 44.4 | 40.3 | 16.6 | 15.7 | 17.2 |
| Money (M1) | 39.5 | 17.9 | 17.0 | 41.0 | -2.0 |
| ក្រដាសប្រាក់នៅក្រៅធនាគារ | 34.9 | 19.5 | 18.7 | 42.9 | -3.7 |
| ប្រាក់បញ្ញើគ្មានកំណត់ពេល | 100.0 | 3.6 | 0.0 | 17.2 | 23.5 |
| Quasi-money | 48.4 | 57.1 | 16.3 | 1.3 | 32.5 |
| ប្រាក់បញ្ញើមានកំណត់ពេល | -50.0 | 60.0 | 62.5 | 53.8 | 55.0 |
| បញ្ញើរូបិយប័ណ្ណបរទេស | 52.5 | 57.1 | 15.7 | 0.3 | 31.8 |

*Source: Economic and Monetary Statistics Review (various issues), National Bank of Cambodia*

នៅឆ្នាំ១៩៩៨ គេឃើញមានការធ្លាក់ចុះនៅក្នុងសកម្មភាពធនាគារផងដែរ ។ ឥណទានធនាគារផ្តល់ឱ្យវិស័យឯកជនបានកើនឡើង ១៥% នៅក្នុងឆមាសទី១ ក៏ប៉ុន្តែកំណើនសំរាប់ឆ្នាំទាំងមូលបានធ្លាក់ចុះមកនៅ ៣% រីឯឆ្នាំ១៩៩៧ មានដល់ ៤៧%[១៨] ។ ឥណទានសរុបរបស់ធនាគារពាណិជ្ជត្រូវបានពង្រីកនៅក្នុងឆ្នាំ១៩៩៨ ទោះបីជាមានកំនើនខ្ពស់ជាងនៅក្នុងឆ្នាំ១៩៩៩ គឺនៅពេលដែលឥណទានសរុបបានកើនឡើង ១៥% គិតត្រឹមខែតុលា (តារាង ១.១១) ។ វិស័យសេវាជាអ្នកទទួលឥណទានធនាគារច្រើនជាងគេបំផុតនៅក្នុងឆ្នាំ១៩៩៨ និងរហូតដល់ខែតុលា ១៩៩៩ ។ វិស័យបន្ទាប់មក គឺឧស្សាហកម្ម និងកសិកម្មដែលតិចជាងគេ ។ " នៅអំឡុងឆ្នាំ១៩៩៨ ធនាគារពាណិជ្ជមួយចំនួនបានបិទ ឬ កាត់បន្ថយប្រតិបត្តិការរបស់ពួកគេ ដោយសារវិបត្តិតំបន់នៅតែមានបន្ត ។ កំណើននៅក្នុងអត្រាឥណទានក្នុងឆ្នាំ១៩៩៩ ជាចំបងបណ្តាលមកពីការមានភាពប្រសើរឡើងនៅក្នុងស្ថិរភាពនយោបាយ និងការបន្តជំនួយបរទេស"[១៩] ។

---

១៧ សាច់ប្រាក់ងាយស្រួល (liquidity) រួមមានក្រដាសប្រាក់នៅក្រៅធនាគារ និង បញ្ញើរូបិយប័ណ្ណបរទេស ។

១៨ Economic and Monetary Statistics Review, No. 62-Dec. 1998.

១៩ Sok et al. (2000).

**តារាង ១.១១. ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ គិតតាមប្រភេទជំនួញ មិនរាប់បញ្ចូលសាខារបស់ ធនាគារជាតិនៃកម្ពុជា NBC ទេ (លានរៀល)**

| | គិតមកត្រឹម | | | | |
|---|---|---|---|---|---|
| | ធ្នូ. 95 | ធ្នូ. 96 | ធ្នូ. 97 | ធ្នូ. 98 | តុលា. 99 |
| កសិកម្ម | 15,015 | 31,685 | 27,531 | 39,078 | 32,521 |
| ឧស្សាហកម្ម | 44,970 | 64,006 | 114,481 | 120,504 | 157,293 |
| ផ្សេងៗ | 263,017 | 342,817 | 507,750 | 498,835 | 570,197 |
| សរុប | 323,002 | 438,508 | 649,762 | 658,417 | 760,011 |
| | ភាគរយនៃឥណទានសរុប | | | | |
| កសិកម្ម | 4.6 | 7.2 | 4.2 | 5.9 | 4.3 |
| ឧស្សាហកម្ម | 13.9 | 14.6 | 17.6 | 18.3 | 20.7 |
| ផ្សេងៗ | 81.5 | 78.2 | 78.1 | 75.8 | 75.0 |

**តារាង ១.១២. សង្ខេបអំពីប្រាក់បញ្ញើនៅធនាគារពាណិជ្ជ មិនរាប់បញ្ចូលសាខារបស់ NBC ទេ (ពាន់លានរៀល)**

| | គិតមកត្រឹម | | | | |
|---|---|---|---|---|---|
| | Dec. 95 | Dec. 96 | Dec. 97 | Dec. 98 | Oct. 99 |
| បញ្ញើជារៀល | 32,294 | 40,007 | 42,886 | 49,769 | 66,240 |
| បញ្ញើជារូបិយប័ណ្ណបរទេស | 515,384 | 731,613 | 832,063 | 841,651 | 1,045884 |
| សរុប | 547,773 | 771,716 | 875,046 | 891,518 | 1,112,223 |

*Source: Economic and Monetary Statistics Review (various issues), National Bank of Cambodia*

នៅឆ្នាំ១៩៩៨ ចំពោះផ្នែកទ្រព្យអសកម្មរបស់ធនាគារវិញ ប្រាក់បញ្ញើជាមួយធនាគារពាណិជ្ជបានកើនឡើងរហូតមកចាប់ពីឆ្នាំ១៩៩៥ គួរឱ្យកត់សំគាល់បំផុតគឺចាប់តាំងពីឆ្នាំ១៩៩៧ (តារាង ១.១២) ។ ចំណែកនៃប្រាក់បញ្ញើរជារូបិយប័ណ្ណបរទេសនៅតែមានកំរិតថេរ ៩១% ដដែល ។ ក៏ប៉ុន្តែ បើគិតជាដុល្លារ បញ្ញើរូបិយប័ណ្ណបរទេសបានធ្លាក់ចុះ ៨% ក្នុងឆ្នាំ១៩៩៨ និង ៩% ក្នុងឆ្នាំ១៩៩៧[២០] ។

## ១.៥ ហិរញ្ញវត្ថុសាធារណៈ

ការអនុវត្តសារពើពន្ធរបស់កម្ពុជាដែលធ្លាក់ចុះគួរឱ្យកត់សំគាល់ក្នុងឆ្នាំ១៩៩៨ បានបង្ហាញនូវសញ្ញាប្រសើរឡើងក្នុងឆ្នាំ១៩៩៩ ក្នុងចំណែកជាអតិរេក ឬ ឱនភាព និងសញ្ញាកំណើនចំណូលរដ្ឋាភិបាលគិតជា%នៃ ផសស (តារាង ១.១៣)[២១] ។

២0 Economic and Monetary Statistics Review, *ibid.*

២១ ជាការសំខាន់ត្រូវកត់សំគាល់ថា គ្មានតួរលេខណាដែលគេទទួលយកជាទូទៅនោះទេ ចំពោះថវិការដ្ឋ និងសមតុល្យទូទាត់សំរាប់ឆ្នាំ ១៩៩៥ - ១៩៩៩ ។ តារាង ១.១៣ និង ១.១៤ បង្ហាញតួលេខផ្លូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍ពង្រាងថវិកាឆ្នាំ ២000 ។ លើសពីនេះ តួរលេខម៉ាក្រូត្រូវកែតំរូវឡើងវិញជាប្រចាំយូរៗម្តង ដែលជាការធ្វើឱ្យមានទិន្នន័យជាច្រើនក្នុងមួយឆ្នាំៗ ។ ទោះបីជា

ដូចតារាង ១.១៣ និង ១.១៤ បង្ហាញស្រាប់ និន្នាការមុនឆ្នាំ១៩៩៨ ជាទូទៅគឺការបន្តមានឱនភាពសារពើពន្ធ និងឱនភាពគណនីចរន្ត, ចំណាយចរន្តខ្ពស់ (ជាចំបងគឺវិស័យការពារជាតិ) ចំណូលរដ្ឋាភិបាលមានចំនួនប្រហែល ៨-៩,៥% នៃ ផសស, ភាគរយខ្ពស់នៃហិរញ្ញប្បទានបរទេស និងការចាត់វិធានការណ៍តិចតួចចំពោះហិរញ្ញប្បទានឱនភាព ។ ការកែតំរូវសារពើពន្ធជាចំបងមានទំរង់ជាការកាត់បន្ថយប្រតិបត្តិក្រៅពីប្រាក់បៀវត្ស ដើម្បីកំហិតការធ្វើហិរញ្ញប្បទានដោយធនាគារ ។ នៅឆ្នាំ១៩៩៨ ការអនុវត្តន៍សារពើពន្ធកាន់តែដុនដាបថែមទៀត ដោយមានការចំណាយលើសការគ្រោងទុកទៅលើវិស័យការពារជាតិ ។ ហិរញ្ញប្បទានដោយធនាគារចំពោះឱនភាពថវិកាមានចំនួន ១២៥ពាន់លានរៀល ហើយចំណូលមូលធនបានធ្លាក់ចុះយ៉ាងខ្លាំង ។ កត្តាទាំងអស់នេះ គឺជាឥទ្ធិពលដែលមានជាបន្ត ដោយសារវិបត្តិទាំងពីរនៅឆ្នាំ១៩៩៧ ។ ក៏ប៉ុន្តែ នៅក្នុងឆ្នាំ១៩៩៩ ចំណូលរដ្ឋាភិបាលបានកើនឡើងច្រើនជាងចំណាយ គឺដោយសារការបង្កើតពន្ធលើតំលៃបន្ថែម (VAT) កំនើនចំណូលពីពន្ធនាំចូល និងចំណូលពីការផ្តល់អាជ្ញាប័ណ្ណ សំរាប់ការនាំចេញសំលៀកបំពាក់ ។ កត្តាទាំងនេះបានបង្កើតឱ្យមានអតិរេកនៅក្នុងគណនីចរន្ត ។

**តារាង ១.១៣. សង្ខេបនៃថវិការដ្ឋ ១៩៩៥ - ២០០០ (ពាន់លានរៀល)**

| | 1995 | 1996 | 1997 | 1998 | 1999[E] | 2000[P] |
|---|---|---|---|---|---|---|
| ចំណូល | 794 | 903 | 979 | 944 | 1417 | 1611 |
| ចំណូលចរន្ត | 635 | 709 | 868 | 909 | 1354 | 1520 |
| ចំណូលពន្ធ | 445 | 534 | 597 | 679 | 995 | 1110 |
| ចំណូលក្រៅពីពន្ធ | 189 | 175 | 271 | 230 | 359 | 410 |
| ***ចំណូលមូលធន*** | 159 | 193 | 110 | 35 | 64 | 91 |
| ចំណាយ | 1248 | 1419 | 1268 | 1557 | 1795 | 2335 |
| ***ចំណាយចរន្ត*** | 737 | 790 | 816 | 934 | 1125 | 1315 |
| ចំណាយមូលធន | 511 | 629 | 452 | 623 | 670 | 1,020 |
| ឱនភាពចរន្ត (accrual) | -102 | -81 | 52 | -25 | 229 | 205 |
| ឱនភាពរួម (accrual) | -454 | -516 | -289 | -613 | -378 | -724 |
| ហិរញ្ញប្បទាន | 557 | 693 | 379 | 614 | 465 | 830 |
| ហិរញ្ញប្បទានដោយបរទេស | 559 | 680 | 446 | 508 | 461 | 845 |
| ហិរញ្ញប្បទានក្នុងស្រុក | -2 | 13 | -67 | 106 | 4 | -15 |
| ក្នុងនេះហិរញ្ញប្បទានដោយធនាគារ | 6 | -17 | -75 | 125 | -70 | n.a. |
| ផសស (GDP) | 7,200 | 8,250 | 9,100 | 10,750 | 12,130 | 13,450 |
| | | | | ភាគរយ នៃ ផសស | | |
| ចំណូល | 11.0 | 10.9 | 10.8 | 8.8 | 11.7 | 12.0 |
| ចំណូលពន្ធ | 6.1 | 6.5 | 6.6 | 6.3 | 8.2 | 8.3 |
| ចំណូលក្រៅពីពន្ធ | 2.6 | 2.1 | 3.0 | 2.1 | 3.0 | 3.0 |
| ចំណាយ | 17.3 | 17.2 | 13.9 | 14.5 | 14.8 | 17.4 |
| ***ចំណាយចរន្ត*** | 10.2 | 9.6 | 8.9 | 8.7 | 9.3 | 9.8 |
| ចំណាយមូលធន | 7.09 | 7.62 | 4.97 | 5.79 | 5.52 | 7.58 |
| ឱនភាពចរន្ត (accrual) | -1.4 | -1.0 | 0.6 | -0.2 | 1.9 | 1.5 |
| ឱនភាពរួម (accrual) | -6.3 | -6.3 | -3.2 | -5.7 | -3.1 | -5.4 |
| ហិរញ្ញប្បទាន | 7.7 | 8.4 | 4.2 | 5.7 | 3.8 | 6.2 |
| ហិរញ្ញប្បទានដោយបរទេស | 7.8 | 8.2 | 4.9 | 4.7 | 3.8 | 6.3 |

ទិន្នន័យទាំងអស់មាននិន្នាការដូចគ្នាក៏ដោយ ក៏តំលៃរបស់មានតំលៃខុសគ្នា។ ប្រភពផ្សេងៗទៀតនៃទិន្នន័យម៉ាក្រូ គឺការគណនាដោយ CDRI ដែលបានបង្ហាញនៅក្នុងតារាងទី២ និង ទី៣ នៅក្នុងសេចក្តីបន្ថែម ។ កង្វះខាតវិធីសាស្ត្រស្ថិតិរួមបណ្តាលឱ្យមានទិន្នន័យម៉ាក្រូច្រើនយ៉ាងដូច្នេះ ។

| | | | | | | |
|---|---|---|---|---|---|---|
| ហិរញ្ញប្បទានក្នុងស្រុក | -0.02 | -0.21 | -0.70 | 0.98 | 0.03 | 0.11 |

*Note: E Estimated, P Planned. Source: Working Table. Ministry of Economy and Finance (2000)*

ក៏ប៉ុន្តែ នៅពេលដែលយើងពិនិត្យមើលរចនាសម្ព័ន្ធនៃចំណូល ចំណែកពីរផ្នែកផ្សេងៗគ្មានការប្រែប្រួលធំដុំទេ ក្នុងរយៈពេល៥ឆ្នាំកន្លងមក លើកលែងតែការបង្កើត VAT (តារាង ១.១៤) ។ ពន្ធលើពាណិជ្ជកម្មបរទេស ជាពិសេសពន្ធនាំចូលមានចំនួនជិត ៨៤% នៃចំណូលពន្ធនៅក្នុងឆ្នាំ១៩៩៩ ។ ចំណែកដែលបានមកពីពន្ធផ្ទាល់ មានកំរិតតិចតួចណាស់ ដោយសារលក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ។ ក្រៅពីការមានមូលដ្ឋានពន្ធជាទន់ខ្សោយ និងការលើកលែងឱ្យរួចពន្ធភ្លាមៗ រដ្ឋាភិបាលនៅបានបន្ថែមការលើកលែងការយកពន្ធសំរាប់ការត្រួតពិនិត្យមុនដឹកជញ្ជូនចំពោះសំលៀកបំពាក់ និងបារី ក្រោយពីព្រឹត្តិការណ៍ខែកក្កដា ឆ្នាំ១៩៩៧ [២២] ។ ការណ៍នេះគឺបានបណ្តាលឱ្យចំណូលធ្លាក់ចុះផងដែរ ។ ជាអាំងឌីកាទ័រមួយដែលបង្ហាញថាមានភាពប្រសើរឡើងការអនុវត្តន៍សារពើពន្ធក្នុងឆ្នាំ១៩៩៩ បង្ហាញឱ្យឃើញនូវភាពប្រសើរឡើងក្នុងការអនុវត្តន៍ប្រមូលចំណូល ។ ជាលទ្ធផល ចំណូលរដ្ឋាភិបាលមានចំនួន ១១.២% នៃ ផសស ។

ចំពោះផ្នែកចំណាយវិញ ក្រសួងការពារជាតិមានចំណែកជិត ៣០% នៃចំណាយសរុបក្នុងឆ្នាំ១៩៩៨ ក៏ប៉ុន្តែ ចំណែកនេះបានធ្លាក់ចុះដល់ ២៦% ក្នុងឆ្នាំ១៩៩៩ គឺទាបជាងគេបំផុតចាប់តាំងពីឆ្នាំ១៩៩៥មក (តារាង ១.១៤) ។ ចំណាយរដ្ឋាភិបាលគិតជាភាគរយនៃ ផសស មានកំរិតប្រហែលគ្នាចំពោះឆ្នាំ១៩៩៨ និង ១៩៩៩ (តារាង ១.១៣) ដែលបណ្តាលមកពីការបន្ថយចំណាយលើវិស័យការពារជាតិ ។ ចំណាយលើវិស័យសង្គម ទោះបីជាកើនឡើងក៏ដោយ ក៏នៅតែទាបខ្លាំងណាស់បើប្រៀបធៀបទៅនឹងតំរូវការ ។ ហិរញ្ញប្បទានបរទេសត្រូវបានប្រើប្រាស់ជាចំបងដើម្បីធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលជាការដាក់ឱ្យវិស័យសុខាភិបាលនៅមានហានិភ័យខ្ពស់ ខណៈដែលតំរូវការរបស់នេះនៅតែមិនត្រូវបានដោះស្រាយ ។

**តារាង ១.១៤. ចំណូល និងចំណាយរបស់រដ្ឋាភិបាល គិតតាមប្រភព និងវិស័យ (គិតជាពាន់លានរៀល)**

| | 1995 | 1996 | 1997 | 1998 | 1999E |
|---|---|---|---|---|---|
| ចំណូល | 794 | 903 | 979 | 944 | 1417 |
| ចំណូលពន្ធ | 445 | 534 | 597 | 679 | 995 |
| ពន្ធផ្ទាល់ | 22 | 26 | 46 | 59 | 76 |
| ពន្ធលើប្រាក់បៀវត្ស | 1 | 3 | 6 | 8 | 10 |
| ពន្ធលើប្រាក់ចំណេញ | 18 | 18 | 35 | 42 | 60 |
| ពន្ធលើដី និង ទ្រព្យសម្បត្តិ | 2 | 2 | 2 | 3 | n.a. |
| ពន្ធប្រយោល | 26 | 44 | 66 | 94 | 109 |
| ពន្ធក្នុងនោះអាករ | 9 | 7 | 11 | 16 | 19 |
| ពន្ធតំលៃបន្ថែម (VAT) | - | - | - | - | 54 |
| ពន្ធលើពាណិជ្ជកម្មបរទេស | 397 | 465 | 486 | 527 | 810 |
| ពន្ធនាំចូល | 300 | 334 | 336 | 372 | 439 |
| ពន្ធនាំចេញ | 17 | 8 | 10 | 3 | 12 |
| ចំណូលក្រៅពីពន្ធ | 190 | 176 | 271 | 230 | 359 |
| ចំណូលមូលធន | 159 | 193 | 110 | 35 | 64 |
| ចំណាយ | 1248 | 1419 | 1268 | 1557 | 1795 |
| ចំណាយចរន្ត | 737 | 790 | 816 | 934 | 1125 |
| ចំណាយលើវិស័យការពារជាតិ | 430 | 406 | 419 | 453 | 470 |
| ចំណាយលើវិស័យសង្គម | 148 | 179 | 189 | 203 | 316 |

២២ World Bank (1999) ។

| | | | | | |
|---|---|---|---|---|---|
| អប់រំ | 74 | 80 | 83 | 102 | 150 |
| សុខាភិបាល | 26 | 42 | 45 | 43 | 80 |
| ចំណាយមូលធន | 511 | 629 | 452 | 623 | 670 |

*Source: Ministry of Economy and Finance (2000)*

## ១.៦ ពាណិជ្ជកម្មក្រៅប្រទេស

ជញ្ជីងទូទាត់របស់កម្ពុជាបង្ហាញឱ្យឃើញនូវឱនភាពពាណិជ្ជកម្មដែលមានជាបន្តនៅឆ្នាំ១៩៩៨ និង១៩៩៩ ។ ទំហំនៃឱនភាពបានថយចុះកាលពីឆ្នាំ១៩៩៧ អាស្រ័យដោយមានកំណើននាំចេញសំលៀកបំពាក់ និងទំនិញនាំចូលដែលរក្សាទុកនៅកម្ពុជាដែលជាការឆ្លុះបញ្ចាំងឱ្យឃើញនូវការឡើងថ្លៃប្រាក់រៀល និងដុល្លារក្នុងអំឡុងពេលនោះ ។ នៅឆ្នាំ១៩៩៨ ការធ្លាក់ចុះចំណូលពីការនាំឈើចេញមានកំរិតខ្ពស់ជាងកំណើនចំណូលបានមកពីការនាំចេញសំលៀកបំពាក់ ដែលធ្វើឱ្យឱនភាពពាណិជ្ជកម្មបានកើនឡើងវិញបន្តិច ។ កាលពីឆ្នាំ១៩៩៩ អាស្រ័យដោយទំនិញនាំចូលដែលរក្សាទុកកើនឡើង, ថ្លៃប្រេងនាំចូលកើនឡើង និងចំណូលពីព្រៃឈើធ្លាក់ចុះ ឱនភាពកាន់តែមានកំរិតខ្ពស់រហូតដល់ ៤០១ លានដុល្លារ ( តារាង ១.១៥) ។

**តារាង ១.១៥. សមតុល្យជញ្ជីងទូទាត់របស់កម្ពុជា ១៩៩៥-១៩៩៩, (គិតជាលានដុល្លារ)**

| | 1995 | 1996 | 1997 | 1998 | 1999 |
|---|---|---|---|---|---|
| សមតុល្យពាណិជ្ជកម្ម ( ទំនិញ ) | -350 | -499 | -338 | -341 | -401 |
| នាំចេញ (FOB) | 890 | 712 | 756 | 746 | 756 |
| ក្នុងនោះ មាននាំចេញពីក្នុងស្រុក | 350 | 351 | 506 | 616 | 636 |
| នាំចេញទំនិញបរទេស (Re-exports) | 540 | 361 | 250 | 130 | 120 |
| សមតុល្យសេវា | -29 | 5 | 27 | 6 | 27 |
| វិក័យប័ត្រ (Receipts) | 107 | 147 | 142 | 126 | 164 |
| ចំណាយ (Payments) | 136 | 142 | 115 | 120 | 137 |
| សមតុល្យទំនិញ និង សេវា | -379 | -494 | -311 | -335 | -374 |
| ចំណូលសុទ្ធ (Net income) | -18 | -16 | -15 | -14 | -12 |
| វិក័យប័ត្រ (Receipts) | 25 | 28 | 31 | 35 | 37 |
| ចំណាយ (Payments) | 43 | 44 | 46 | 49 | 49 |
| ប្រាក់ផ្ទេរឯកជន | 20 | 23 | 25 | 30 | 30 |
| សមតុល្យគណនីចរន្ត ( រួមទាំងប្រាក់ផ្ទេរផ្លូវការ ) | -30 | -188 | -100 | -125 | -164 |
| កំចីផ្លូវការតាមវិស័យ ( មិនរាប់ពី IMF) | 71 | 56 | 38 | 49 | 43 |
| កំចីដុលដែលបានប្រគល់ | 75 | 75 | 38 | 50 | 44 |
| ចំនួនសង | 4 | 19 | 0 | 1 | 1 |
| វិនិយោគឯកជន ( សុទ្ធ) | 151 | 240 | 150 | 120 | 150 |
| វិនិយោគផ្ទាល់ សុទ្ធ | 151 | 240 | 150 | 120 | 150 |
| វិនិយោគ Portfolio, សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| លំអៀងសុទ្ធ និង ការកែតំរូវ | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សមតុល្យសរុប | 79 | | 34 | 14 | 24 |
| កំចីពី IMF | 42 | 0.0 | 0.0 | 0.0 | 11 |
| បំរែបំរួលសុទ្ធ នៅក្នុងប្រាក់បរទេសបំរុង | 40 | 54 | 33 | 126 | 24 |

*Source: Ministry of Economy and Finance (2000)*

ដូចជាការអនុវត្តន៍ពាណិជ្ជកម្មដែរ ជំនួយជាផ្លូវការណ៍ កំចី និងវិនិយោគបរទេសផ្ទាល់ (FDI) សុទ្ធតែបានធ្លាក់ចុះនៅក្នុងឆ្នាំ១៩៩៧ ដោយសារការផ្អាកជំនួយបណ្តោះអាសន្ន និងភាពមិនប្រាកដប្រជានៅក្នុងសេដ្ឋកិច្ច ។ ប្រាក់ផ្ទេរផ្លូវការ និងការប្រគល់ កំចី បានធ្លាក់ចុះបន្តទៀតនៅក្នុងឆ្នាំ១៩៩៩ ទោះបីជា FDI បានកើនឡើងវិញគួរឱ្យកត់សំគាល់ ដែលនាំឱ្យសមតុល្យទូទាត់ទាំង មូលមានភាពប្រសើរជាងមុន គឺពី ១៤លានដុល្លារ នៅឆ្នាំ១៩៩៨ ដល់ ២៤លានដុល្លារ នៅឆ្នាំ១៩៩៩ ។ ប្រាក់បរទេសបំរុងក៏បានកើនឡើងច្រើនដែរ នៅក្នុងឆ្នាំ១៩៩៨ និង ១៩៩៩ ។

**តារាង ១.១៦. រចនាសម្ព័ន្ធការនាំចេញនាំចូលរបស់កម្ពុជា និងគំរោងវិនិយោគមកពីប្រទេសផ្សេងៗ ដែលបានអនុម័ត**

| | ភាគរយនៃការនាំ ចេញ នៅឆ្នាំ ១៩៩៨ | ភាគរយនៃការនាំ ចូលនៅឆ្នាំ ១៩៩៨ | ភាគរយនៃវិនិយោគ (ទ្រព្យអចល័ត) |
|---|---|---|---|
| តំលៃសរុប | $795 million | $1,127 million | $2,543 million |
| **អាស៊ាន** | **32.9** | **38.2** | **34.9** |
| សឹង្ហបូរី | 16.7 | 8.5 | 7.8 |
| ថៃ | 9.7 | 14.9 | 6.4 |
| ម៉ាឡេ | 0.8 | 4.1 | 20.4 |
| ឥណ្ឌូនេស៊ី | 0.1 | 2.5 | 1.0 |
| វៀតណាម | 5.3 | 8.0 | 0.0 |
| ភីលីភីន | 0.4 | 0.2 | 0.0 |
| ឡាវ | 0.0 | 0.0 | 0.0 |
| ភូមា | 0.0 | 0.0 | 0.0 |
| **អាស៊ីផ្សេងទៀត** | **16.4** | **37.0** | **39.2** |
| តៃវ៉ាន់ | 2.6 | 11.2 | 14.6 |
| ហុងកុង | 3.4 | 11.5 | 8.5 |
| ចិន | 5.3 | 8.5 | 8.3 |
| កូរ៉េខាងត្បូង | 0.0 | 5.9 | 7.8 |
| **ប្រទេសឧស្សាហកម្មផ្សេងទៀត** | **50.7** | **16.6** | **20.6** |
| សហរដ្ឋ | 36.8 | 3.5 | 8.7 |
| ជប៉ុន | 1.0 | 6.3 | 0.3 |
| បារាំង | 1.5 | 3.6 | 7.5 |
| អាល្លឺម៉ង់ | 9.0 | 0.9 | 0.0 |
| ចក្រភពអង់គ្លេស | 3.1 | 1.3 | 2.8 |
| អូស្ត្រាលី | 0.1 | 0.9 | 1.3 |
| ផ្សេងៗ | 0.0 | 8.2 | 5.3 |

*Source: Ministry of Finance and Economy (2000)*

**តារាង ១.១៧. តំលៃទំនិញនាំចេញរបស់កម្ពុជា នៅឆ្នាំ១៩៩៨**

| | គិតជាលានដុល្លារ | ភាគហ៊ុន គិតជា% |
|---|---|---|
| សរុប | 795 | 100.0 |
| ទំនិញកម្មន្តសាល | 466 | 58.6 |
| សំលៀកបំពាក់ | 420 | 52.8 |
| បារី | 36 | 4.5 |
| ផ្សេងៗ | 10 | 1.2 |
| ទំនិញកសិកម្ម និង ផ្នែកពាក់ព័ន្ធ | 135 | 17.0 |
| ឈើកែច្នៃ (Processed wood) | 102 | 12.9 |
| កៅស៊ូធម្មជាតិ (Natural rubber) | 25 | 3.2 |
| ផលិតផលត្រី (Fishing products) | 4 | 0.5 |
| ផ្សេងៗ | 3 | 0.4 |

| | | |
|---|---|---|
| ផ្សេងៗ | 194 | 24.5 |

Source: Ministry of Economy and Finance (2000)

ប្រទេសអាស៊ាន ជាពិសេសប្រទេសថៃ សិង្ហបុរី និងវៀតណាម គឺជាដៃគូពាណិជ្ជកម្មធំជាងគេរបស់កម្ពុជា ។ ប្រទេសអាស៊ាន ទទួល ៣៣% នៃការនាំចេញពីប្រទេសកម្ពុជា និងជាអ្នកនាំចូលទំនិញមកកម្ពុជា ចំនួន ៣៨% (តារាង ១.១៦ ) ។ សហរដ្ឋអាមេរិក គឺជាដៃគូនាំទំនិញចេញធំបំផុតរបស់កម្ពុជា ជាចំបង គឺមកពីការនាំចេញសំលៀកបំពាក់ ដែលមានចំនួន ៣៧% នៃទំនិញនាំចេញសរុប ។ តារាង ១.១៧ បង្ហាញថា បន្ទាប់ពីឧស្សាហកម្មសំលៀកបំពាក់គួរជាទីមោទនៈ ដែលមានចំណែក ៦០% នៃតំលៃនាំចេញសរុប គឺ បារី និង ឈើកែច្នៃ បើមើលតាមលំដាប់ក្នុងតារាង ។

## ១.៧ តួនាទីនៃជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) នៅក្នុងសេដ្ឋកិច្ចកម្ពុជា

រដ្ឋាភិបាលកម្ពុជា និងសេដ្ឋកិច្ចកម្ពុជា មានការពឹងពាក់ខ្លាំងទៅលើជំនួយបរទេស ក្នុងទំរង់ជាជំនួយឥតសំណងផង (មានចំនួន ៣២៨លានដុល្លារ នៅឆ្នាំ១៩៩៨ ) និងកំចីផង (មានចំនួន ៧៥លានដុល្លារ នៅឆ្នាំ១៩៩៨) ។ ពតិមានលំអិតអំពីជំនួយបច្ចេកទេសមកកម្ពុជា មានត្រឹមឆ្នាំ១៩៩៨ ប៉ុណ្ណោះ ដូចនេះ ផ្នែកនេះគឺផ្តោតតែឆ្នាំនេះប៉ុណ្ណោះ ។

កំរិតសារៈសំខាន់នៃជំនួយបច្ចេកទេសត្រូវបានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងឯកសាររបស់ Godfrey et al. (2000) នៅពេលដែលអ្នកនិពន្ធទាំងនោះបានសេរសេរថា :

*ជំនួយបច្ចេកទេសមកពីបរទេស គឺជាឧស្សាហកម្មមួយ ក្នុងចំណោមឧស្សាហកម្មនាំចេញដ៏ធំជាងគេទាំងអស់នៅកម្ពុជា ។ វាមានចំនួនលើសពីចំណូលរបស់រដ្ឋាភិបាល និងលើសពីចំណាយចរន្តក្រៅពីចំណាយលើវិស័យការពារជាតិ បើគិតនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ហើយវាជាប្រភពចំណូលរូបិយប័ណ្ណបរទេសមួយសំខាន់ជាងការនាំចេញចំបងៗទាំងឡាយ*[២៣] ។

ទំហំនៃជំនួយបច្ចេកទេស អាចឃើញនៅក្នុងតារាង ១.១៨ ដែលបង្ហាញឱ្យឃើញថា តួលេខទាក់ទងនឹងចំណូល និងការនាំចេញមានកំរិតខ្ពស់ណាស់ ។

**តារាង ១.១៨. ទំហំ និង សារៈសំខាន់នៃជំនួយបរទេស (ជំនួយសរុប និង ជំនួយបច្ចេកទេស ) ចំពោះកម្ពុជានៅឆ្នាំ១៩៩៨**

| | ជំនួយបរទេសសរុប * | ជំនួយបច្ចេកទេស ** |
|---|---|---|
| គិតក្នុងប្រជាជនម្នាក់ | $36 | $21 |
| គិតជា % នៃ | | |
| ផសស (GDP) | 14 | 8 |
| នាំចេញ | 57 | 33 |
| នាំចេញទំនិញក្នុងស្រុក | 70 | 40 |
| នាំចេញសេវា | 370 | 211 |
| វិនិយោគបរទេសសុទ្ធ | 335 | 191 |
| ចំណូលរដ្ឋាភិបាល | 167 | 95 |
| ចំណូលពន្ធ | 226 | 129 |
| ចំណាយចរន្តរបស់រដ្ឋាភិបាល | 169 | 96 |

២៣ Godfrey et al. (2000).

| | | |
|---|---|---|
| ចំណាយចរន្តរបស់រដ្ឋាភិបាលក្រៅពីការពារជាតិ | 305 | 174 |

*សំគាល់ :* ជំនួយបរទេសរួមមាន: ជំនួយគំរោងវិនិយោគ ជំនួយទ្រទ្រង់ថវិការដ្ឋ និងការទ្រទ្រង់សមតុល្យទូទាត់ និងជំនួយស្បៀងអាហារ និងជំនួយសង្គ្រោះបន្ទាន់ព្រមទាំងជំនួយបច្ចេកទេសផងដែរ ។ ** ជំនួយបច្ចេកទេសមានពីរប្រភេទ: ជំនួយបច្ចេកទេសសុទ្ធ (មានចំនួនសរុប ២០៨ លានដុល្លារ ) និង ជំនួយពាក់ព័ន្ធគំរោងវិនិយោគ (មានចំនួនសរុប ២៣លានដុល្លារ) ប្រភព: Godfrey et al (2000), Table 2.1.*

ការប្រគល់ជំនួយបរទេសសរុបដោយទាយកទ្វេភាគី ពហុភាគី និង ស្ថាប័នក្រៅរដ្ឋាភិបាល សំរាប់ឆ្នាំ១៩៩៨ មានចំនួន ៤០៤លានដុល្លារ ដែលជាការកើនឡើង ៧,៦% ពីឆ្នាំ១៩៩៧ ។ ជំនួយឥតសំណងសំរាប់ការអភិវឌ្ឍន៍ មានចំនួន ៣២៨ដុល្លារ (ដែលជាការធ្លាក់ចុះអស់ ៣% ធៀបនឹងឆ្នាំ១៩៩៧) នៅខណៈដែលកំចីសរុបមានចំនួន ៧៥លានដុល្លារ (កើនឡើង ១០៦% ពីឆ្នាំ១៩៩៧)[២៤] ។ ក្នុងនេះ ៣៣% បានមកពីទាយកពហុភាគី ៥៣% បានមកពីទាយកទ្វេភាគី និងចំនួនផ្សេងទៀត បានមកអង្គការក្រៅរដ្ឋាភិបាល (តារាង ១.១៩)។ បើគិតជារបាយតាមវិស័យយើងឃើញថា ជំនួយភាគច្រើនជាងគេត្រូវបាន ប្រគល់ឱ្យវិស័យអភិវឌ្ឍន៍ជនបទ (គឺ១៤%)។ បន្ទាប់មកគឺវិស័យរដ្ឋបាលកិច្ចអភិវឌ្ឍន៍ (១២,៤%) វិស័យហេដ្ឋារចនាសម្ព័ន្ធ ឬគមនាគមន៍ (១២% ) វិស័យជំនួយមនុស្សធម៌ និងជំនួយសង្គ្រោះ (៩,៤%) វិស័យសុខាភិបាល (៨%) វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៧%) វិស័យអភិវឌ្ឍន៍សង្គម (៦%) និង វិស័យថាមពល (៥%) ។

ជំនួយបរទេសនៅកម្ពុជា ត្រូវបានចែកជាប្រភេទផ្សេងៗគ្នាគឺ: កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធ និង កិច្ចសហប្រតិបត្តិការបច្ចេកទេសទាក់ទងនឹងការវិនិយោគ (ដែលរួមទាំងពីរនេះមកហៅថាជំនួយបច្ចេកទេស) ជំនួយគំរោងវិនិយោគ ជំនួយទ្រទ្រង់ថវិការដ្ឋ និងការទ្រទ្រង់សមតុល្យទូទាត់ និងជំនួយស្បៀងអាហារ និងជំនួយសង្គ្រោះបន្ទាន់ ។ គ្មានការប្រគល់ជំនួយប្រភេទទីពីរចុងក្រោយនេះទេ កាលពីក្នុងឆ្នាំ១៩៩៨ ។ ជំនួយបច្ចេកទេសមានចំនួនសរុប ២៣១លានដុល្លារ និង ជំនួយគំរោងវិនិយោគ មានចំនួនសរុប ១៦៨លានដុល្លារ។ របាយការណ៍កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់រដ្ឋាភិបាលកម្ពុជា ធ្វើការកត់សំគាល់ផងដែរថា ស្ថាប័នទាយកទ្វេរភាគីជាច្រើនអនុវត្តកម្មវិធីរបស់ពួកគេមួយចំណែក ឬទាំងស្រុងតាមរយ:ស្ថាប័ន នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ឬ តាមរយ:អង្គការ NGOs ។

**តារាង ១.១៩. ជំនួយបរទេស ចំពោះកម្ពុជា ១៩៩៥-៩៨ តាមប្រភេទទាយក (គិតជាលានដុល្លារ)**

| | 1995 | 1996 | 1997 | 1998 |
|---|---|---|---|---|
| ទាយកពហុភាគី | 169.6 | 198.0 | 123.1 | 133.4 |
| UN agencies | 31.0 | 50.3 | 39.8 | 40.5 |
| World Bank | 29.6 | 40.4 | 28.1 | 29.3 |
| IMF | 42.3 | 0.4 | 0.0 | 0.0 |
| ADB | 37.9 | 49.2 | 18.4 | 41.3 |
| EU | 28.9 | 57.6 | 36.8 | 22.3 |
| ទាយកទ្វេភាគី | 328.1 | 284.3 | 202.5 | 214.4 |
| Australia | 27.5 | 20.2 | 27.3 | 18.2 |
| China | 3.1 | 10.9 | 9.5 | 14.3 |
| Denmark | 5.1 | 20.8 | 5.1 | 4.5 |
| France | 62.2 | 42.9 | 26.5 | 29.5 |
| Germany | 13.9 | 9.6 | 10.1 | 9.8 |
| Japan | 117.9 | 111.0 | 59.8 | 71.4 |
| Netherlands | 3.4 | 11.5 | 3.3 | 5.7 |
| Sweden | 25.3 | 16.1 | 17.4 | 13.5 |
| UK | 10.7 | 4.1 | 2.3 | 6.0 |
| USA | 45.1 | 28.8 | 30.5 | 30.4 |

២៤ CDC (1999) ។

| | | | | |
|---|---|---|---|---|
| Non-governmental organizations | 21.1 | 35.8 | 49.9 | 56.1 |
| Total | 518.8 | 518.1 | 375.4 | 403.9 |

Source: Godfrey et al. (2000)

**តារាង ១.២០. សមាសភាគជំនួយបរទេស ជំនួយឥតសំណង គិតជាភាគរយនៃជំនួយសរុប**

| | 1995 | 1996 | 1997 | 1998 |
|---|---|---|---|---|
| ជំនួយ | 80.0 | 81.0 | 90.0 | 81.0 |
| កំចី | 20.0 | 19.0 | 10.0 | 19.0 |

Source: CDC (1999) Chart 3

តារាង ១.២០ បង្ហាញឱ្យឃើញថា ជំនួយបរទេសភាគច្រើនចំពោះកម្ពុជា គឺជាជំនួយឥតសំណង ។ ទំហំជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) មានកំរិតខ្ពស់ខ្លាំងក៏ពិតមែន ក៏ប៉ុន្តែ មិនគ្រប់គ្រាន់សំរាប់បំពេញតំរូវការជាតិឡើយ ជាពិសេស នៅក្នុងវិស័យសង្គម ។ នៅមានបញ្ហារបាយជំនួយដែលមិនស្មើគ្នាតាមតំបន់ទៀតផង ។ ឧទាហរណ៍ ភ្នំពេញបានទទួលភាគរយនៃជំនួយច្រើនជាងតំបន់ផ្សេងៗទៀតក្នុងប្រទេស ។ មានការចាំបាច់ ក្នុងការលើកកំពស់ការសំរបសំរួលជំនួយពីទាយកទាំងអស់ ដើម្បីកែតំរូវអតុល្យភាពទាំងនេះ ។

# ជំពូក ពីរ

# ជីវភាពនៅជនបទ និង ការទទួលនិងប្រើប្រាស់ដី

## ២.១ ដី កំលាំងពលកម្ម និងជីវភាពកសិកម្ម

ប្រទេសកម្ពុជា គឺជាប្រទេសសេដ្ឋកិច្ចកសិកម្មស្ទើរតែទាំងស្រុង ។ ក្នុងឆ្នាំ១៩៩៨ វិស័យកសិកម្មមានជាង ៣៥% នៃផលិតផលសរុបក្នុងស្រុក (GDP) ដែលបានផ្តល់ការងារប្រហែល ៧៧% នៃកំលាំងពលកម្មទាំងអស់ ហើយបានរួមចំណែកមួយភាគធំនៃចំណូលដែលបានមកពីការនាំចេញ ។ ប្រជាជន ៨៤% រស់នៅតាមជនបទ ដែលមានប្រភពចំណូលចំបងពីការធ្វើកសិកម្ម ។ ហេតុនេះ ការអភិវឌ្ឍន៍វិស័យនេះគឺជាអាទិភាពខ្ពស់មួយដើម្បីកែលំអកំរិតជីវភាពនៅជនបទ និងប្រជាជនទូទាំងប្រទេស ។ ការអភិវឌ្ឍន៍វិស័យកសិកម្មប្រហែជាកត្តាដែលមានសារៈសំខាន់ជាងគេសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រនៅកម្ពុជា ។ ប៉ុន្តែដោយសារការគ្រប់គ្រងដីធ្លីដែលមិនមានប្រសិទ្ធិភាព និងមិនមានច្បាប់កំណត់ត្រឹមត្រូវ[១] ក៏ដូចជាការបរាជ័យក្នុងការអនុវត្តន៍ក្រិត្យច្បាប់ដែលពាក់ព័ន្ធនឹងដីធ្លីឱ្យបានច្បាស់លាស់ និងសមស្របអាច រាំងស្ទះដល់ការអភិវឌ្ឍន៍កសិកម្ម ។

ក្នុងចំណោមផ្ទៃដីសរុប ១៨១.០៣៥គីឡូម៉ែត្រការ៉េ ដី៦០% គឺជាដីព្រៃ និងមានតែដី ៤លានហិកតា (២១%) ប៉ុណ្ណោះជាតំបន់មានសក្តានុពលកសិកម្ម ។ ក្នុងចំណោមនេះ ២,៤លានហិកតា គឺស្ថិតនៅក្រោមផលិតកម្មដំណាំប្រចាំឆ្នាំ ។ ស្រូវដែលជាដំណាំស្បៀងនៅកម្ពុជាគ្របដណ្តប់វប្បកម្មកសិកម្ម និងបានកាន់កាប់ដីជាង ៩០% នៃផ្ទៃដីដំណាំទាំងអស់ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ។ វាក៏បានផ្តល់ការងារអោយកំលាំងពលកម្មដែលកំពុងកើនឡើងយ៉ាងឆាប់រហ័សជាពិសេស នៅតំបន់ជនបទ ។ យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រហែលជា ៨៣% នៃគ្រួសារនៅកម្ពុជា (ជិត ២លានគ្រួសារ) គឺជាអ្នកដាំស្រូវ និង ៦៥% នៃកំលាំងពលកម្មសរុបធ្វើផលិតកម្មស្រូវដោយផ្ទាល់ ។ ជីវភាពរបស់ពួកគេពឹងផ្អែកយ៉ាងខ្លាំងលើផលិតកម្មមួយគ្រប់ហូប ។ ហេតុនេះ ដីស្រែគឺជាទ្រព្យសម្បត្តិផលិតកម្មដ៏សំខាន់បំផុត ហើយកំណត់ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ពួកគេបានមួយកំរិតធំ ។

ដោយមានប្រជាជន ៦៤នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានរបាយប្រជាជនទាបនៅក្នុងចំណោមបណ្តាប្រទេសនៅតំបន់អាស៊ីអគ្នេយ៍ ។ ទោះបីជាយ៉ាងណា គេគួរតែពិចារណាពីដង់ស៊ីតេប្រជាជនទាបនេះ ធៀបទៅនឹងសមាសភាគដ៏តូចនៃផ្ទៃដីកសិកម្ម ។ គ្រួសារជនបទនៅកម្ពុជាមានដីកសិកម្មជាមធ្យមប្រហែលតែ ១,០ហិកតាប៉ុណ្ណោះ (ភាគច្រើនជាដីស្រែវស្សា) សំរាប់ធ្វើសិកម្មបានមួយគ្រប់ហូបប៉ុណ្ណោះ ។

---

១ ច្បាប់ភូមិបាលថ្មីបានត្រូវគេពង្រាង និងពិភាក្សាជាមួយនឹងផ្នែកផ្សេងៗ ហើយគេរំពឹងថានឹងដាក់ឱ្យរដ្ឋសភាជាតិអនុម័តនៅខែកក្កដា ឆ្នាំ២០០០ ។

ក្នុងរយៈពេល ២០ឆ្នាំកន្លងមកនេះ ផលិតផលកសិកម្មបានកើនឡើងច្រើនដោយមានកំណើនប្រចាំឆ្នាំជាមធ្យម ២.៥% ដែលភាគច្រើនបានមកពីផលិតកម្មស្រូវ ។ ផលិតកម្មស្រូវបានកើនឡើងគួរអោយកត់សំគាល់ទោះជាវាពឹងផ្អែកភាគច្រើនទៅលើទឹកភ្លៀង និងការដាំដុះតាមបែបប្រពៃណីក៏ដោយ ។ ផលស្រូវលើសពីសេចក្តីត្រូវការចាប់តាំងពី ១៩៩៥ និងក្នុងឆ្នាំ១៩៩៨ ឡើងខ្ពស់បំផុតរហូតដល់ ៣,៩លានតោន បានផ្តល់បរិមាណអង្ករលើស ៣០,០០០តោន សំរាប់ការនាំចេញ ។ ជាលទ្ធផល ផលិតភាពក្នុងមនុស្សម្នាក់បានកើនឡើងបន្តិចបន្តួចដល់ ០,៨៨តោន ក្នុងឆ្នាំ១៩៩៨ (តារាង២.១) ។ តារាងនេះ ក៏បង្ហាញថា កំណើនថ្មីៗនៃផលិតកម្មស្រូវបណ្តាលមកពីការកើនឡើងទាំងផ្ទៃដីដាំដុះ និងផលិតភាពដី។

ផ្ទៃដីដាំស្រូវបានកើនឡើងគួរឱ្យកត់សំគាល់ពី ១,៤លានហិកតា ទៅ ២,១លានហិកតា ដែលមានកំរិតជាមធ្យម ២.០% ក្នុងចន្លោះឆ្នាំ១៩៨០ និង ១៩៩៨ ហើយស្ទើរតែឡើងដល់កំរិតខ្ពស់បំផុត ២,៥លានហិកតានៅចុងទសវត្សរ៍១៩៦០ ។ កំណើននេះជាចំបងដោយសារតែការពង្រីកយកដីដែលមិនប្រើប្រាស់ ការសំអាតដីមីន និងការកែលំអសន្តិសុខ ដែលបានអនុញ្ញាតឱ្យកសិករទទួលបានដីដែលពីមុនស្ថិតនៅតំបន់មានអន្តិសុខខ្ពស់ ។ ថ្វីបើមានកំណើនប្រជាជនខ្ពស់ក៏ដោយ ក៏ដីស្រែក្នុងមនុស្សម្នាក់បានកើនឡើងបន្តិចបន្តួចពី ០,៥១ហិកតា ក្នុងឆ្នាំ១៩៨០ ដល់ ០,៥៣ ក្នុងឆ្នាំ១៩៩៨ (តារាង២.១) ។ ទោះជាយ៉ាងណាក៏ដោយ កំណើននេះនឹងធ្លាក់ចុះមកវិញដោយសារតែដីធ្លីមានកំណត់ ។

ក្នុងអំឡុងពេលដូចគ្នានេះ ផលិតភាពស្រូវក៏បានកើនឡើងពី ១,១៩តោនក្នុងមួយហិកតា ទៅ ១,៦៨តោនក្នុងមួយហិកតា ដែលមានកំរិតខ្ពស់ច្រើនជាងកាលពីមុនសង្គ្រាមដែលបានតែ ១,០តោនក្នុងមួយហិកតា ។ និន្នាការនៃផលិតភាពដីដែលកំពុងកើនឡើង ជាពិសេសគេកត់សំគាល់ឃើញបន្ទាប់ពីមានកំណែទំរង់សេដ្ឋកិច្ចធំៗនៅចុងទសវត្សរ៍១៩៨០ រួមមានគោលនយោបាយតំលៃផលិតផលកសិកម្ម ។ យោងតាម Nesbitt (១៩៩៧) កំនើននេះជាចំបង គឺអាស្រ័យដោយសារតែហេតុផលដូចតទៅ: ការកើនឡើងនៃការប្រើប្រាស់ជី និងសំភារៈផលិតកម្មកសិកម្មដទៃទៀត ការកើនឡើងនៃការប្រើប្រាស់ពូជមានទិន្នផលខ្ពស់ ការកែលំអប្រព័ន្ធដឹកជញ្ជូន អាកាសធាតុអំណោយផល ការកើនឡើងនៃលទ្ធភាពទទួលបានឥណទានជនបទការកើនឡើងនៃវិនិយោគទុនឯកជនក្នុងផ្នែកដទៃទៀត និងការកើនឡើងនៃតំលៃស្រូវក្នុងទីផ្សារសេរី ដែលជាលទ្ធផលនៃកំណែទំរង់សេដ្ឋកិច្ចចំបងៗ ។ ផលិតផលស្រូវក្នុងមនុស្សម្នាក់បានកើនឡើងពី ០,៧២តោន ក្នុងឆ្នាំ១៩៩៣ ដល់ ០,៨៨តោនក្នុងឆ្នាំ១៩៩៨ ។ កំណើននៃផលិតភាពអាចបង្កើនបាន ហើយវាមិនដូចគ្នានឹងផ្ទៃដីកសិកម្មទេ ដោយគេអាចបង្កើនការប្រើប្រាស់ជីពង្រីកប្រព័ន្ធស្រោចស្រព និងការប្រើប្រាស់ពូជមានទិន្នផលខ្ពស់នានា ។

**តារាង២.១. ប្រជាជន កំលាំងពលកម្ម និងដីធ្លី ១៩៨០-១៩៩៨**

| | 1980 | 1993 | 1998 |
|---|---|---|---|
| ប្រជាជនសរុប ជាពាន់នាក់ ('000នាក់) | 6.500 | 9.900 | 11.438 |
| ភាគរយនៃប្រជាជននៅជនបទ | 88 | 85 | 84 |
| ប្រជាជនសកម្មសរុប ជាពាន់នាក់ [១] ('000នាក់) | 3.100 | 4.235 | 5.118 |
| ភាគរយនៃប្រជាជនសកម្មក្នុងវិស័យកសិកម្ម | 91 | 81 | 77 |
| ផ្ទៃដីដាំដំណាំសរុប ពាន់ហិកតា [២] ('000ហិកតា) | 1.619 | 2.021 | 2.298 |
| ទំហំដីដាំដំណាំក្នុងកំលាំងពលកម្មកសិកម្មម្នាក់ | 0,57 | 0,58 | 0,61 |
| ដីស្រែជាពាន់ហិកតា ('000ហិកតា) | 1.441 | 1.857 | 2.095 |
| ទំហំដីស្រែក្នុងកំលាំងពលកម្មកសិកម្មម្នាក់ | 0,51 | 0,56 | 0,53 |
| ផិន្នផលស្រូវក្នុងមួយហិកតា | 1,19 | 1,28 | 1,68 |
| ទិន្នផលស្រូវក្នុងកំលាំងពលកម្មកសិកម្មម្នាក់ (តោន/ហិកតា) | 0,61 | 0,72 | 0,88 |

*កំនត់សំគាល់: (១) គិតទាំងអ្នកដែលមានការធ្វើ និងគ្មានការធ្វើពីមុនមក ។ (២) ដីដាំដំណាំសំដៅទៅលើដីដែលបែងចែក សំរាប់ដាំស្រូវ និងដំណាំផ្សេងៗ ទៀត ។* ប្រភព: ក្រសួងផែនការ *(1989), NIS (1994), NIS (1997) and NIS (1999)*

ក្រៅពីការអភិវឌ្ឍន៍សំខាន់ៗទាំងនេះ កំណើនប្រជាជនយ៉ាងឆាប់រហ័សពិតជានឹងបង្កើនសម្ពាធកាន់តែធំទៅលើផលិកម្មកសិកម្មទាំងមូល និងផលិតកម្មស្រូវជាពិសេស ។ សម្ពាធនឹងមានកាន់តែធំទៅលើដីដាំស្រូវ ដែលអាចជាឧបសគ្គដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម ។ យោងតាមលទ្ធផលជំរឿនប្រជាជនឆ្នាំ១៩៩៨ ចំនួនប្រជាជនសរុបកើនឡើងជិតពីរដងក្នុងចន្លោះឆ្នាំ១៩៨០ និង ១៩៩៨ ចាប់ពី ៦,៥លាន ដល់ ១១,៤លាន (តារាង២.១) ។ ក្នុងខណៈពេលនេះ ភាគរយប្រជាជននៅជនបទបានធ្លាក់ចុះបន្តិចបន្តួចប៉ុណ្ណោះ ពី ៨៨% មក ៨៤% ។ ប៉ុន្តែប្រជាជនភាគច្រើន នៅតែរស់នៅក្នុងតំបន់ជនបទនានា និងធ្វើផលិកម្មកសិកម្មដោយសារតែមិនសូវមានឱកាសការងារក្រៅពីកសិកម្មនៅតំបន់ជនបទ ។ ប្រការនេះបានបង្ហាញថា ការរីកចំរើននៃវិស័យដទៃផ្សេងៗទៀត ដូចជាឧស្សាហកម្ម និងសេវាកម្ម ដែលផ្តល់ការងារដល់កំលាំងពលកម្ម ប្រហែលជា ២៣% នៃកំលាំងពលកម្មទាំងអស់ក្នុងឆ្នាំ១៩៩៨ មិនគ្រប់គ្រាន់ដើម្បីស្រូបយកកំលាំងពលកម្ម ដែលកំពុងតែកើនឡើងយ៉ាងឆាប់រហ័សនោះទេ ។

បន្ថែមលើកំនើនប្រជាជនយ៉ាងខ្ពស់ ២,៤៩% បញ្ហានានានៃការប្រមូលផ្តុំដីធ្លីអាចបង្ហាញអោយឃើញច្បាស់ដោយរបាយអាយុរបស់ប្រជាជន ។ ជំរឿនប្រជាជននៅឆ្នាំ១៩៩៨ បង្ហាញថា ប្រជាជនសរុបប្រហែលជា ៤៣% គឺមានអាយុតិចជាង ១៥ឆ្នាំដែលជាអត្រានៅក្នុងបន្ទុក (ប្រជាជនដែលមិនធ្វើការត្រូវផ្គត់ផ្គង់ដោយកំលាំងពលកម្ម) ខ្ពស់ជាងបណ្តាប្រទេសផ្សេងៗ ។ រឿង នេះប្រហែលជាអាចសន្មតបានដោយកំណើតកូនក្មេងច្រើន (baby boom) ដែលបានរាយការណ៍នៅដើមទសវត្សរ៍១៩៨0 នៅពេលដែលគ្រួសារបានជួបជុំគ្នា និងអត្រាបង្កើតកូនខ្ពស់ក្នុងឆ្នាំបន្តបន្ទាប់នៃទសវត្សរ៍នោះ (វិជ្ជាស្ថានជាតិស្ថិតិ ១៩៩៩:១៤) ។ ចំនួនប្រជាជនវ័យក្មេងនេះនឹងបន្តកើនឡើងយ៉ាងរហ័សនូវទំហំកំលាំងពលកម្ម ក្នុងកំឡុងទសវត្សរ៍ក្រោយនេះហើយនឹងបង្កើនសម្ពាធថែមទៀតទៅលើដីធ្លី ។ ដូចក្នុងតារាង២.២ កំលាំងពលកម្មត្រូវបានគេរំពឹងថានឹងកើនដល់ជិតមួយលាននាក់ (១៩%) នៅឆ្នាំ២00៣ ។ រឿងនេះបញ្ជាក់ថា ប្រជាជន ២0,000នាក់ ថែមទៀតនឹងចូលក្នុងទីផ្សារពលកម្មរៀងរាល់ឆ្នាំដែលនឹងមិនអាចចៀសផុតបណ្តាលអោយមានសម្ពាធយ៉ាងធំដើម្បីបង្កើតឱកាសការងារ ។ ប្រសិនបើលំនាំនៃការងារនៅក្នុងវិស័យកសិកម្មនៅដដែល (ផ្តល់ការងារបានប្រហែល ៧៧% នៃកំលាំពលកម្មទាំងអស់) ដែលប្រហែលជាមានកំលាំងពលកម្មថ្មីចំនួនប្រមាណ ១៥0,000នាក់រៀងរាល់ឆ្នាំនឹងស្វែងរកដីធ្លីដើម្បីចិញ្ចឹមជីវិតរបស់ពួកគេ។

**តារាង២.២. ការព្យាករណ៍នៃកំណើនកំលាំងពលកម្ម ១៩៩៨-២00៣**

| ក្រុមអាយុ | ប្រជាជនសរុប១៩៩៨ | កំលាំងពលកម្មសរុប១៩៩៨ (១) | អត្រាចូលរួមក្នុងកំលាំងពលកម្ម (២) | ប្រជាជនសរុប ២00៣ | កំលាំងពលកម្មដែលមិនទាន់កែតម្រូវ ២00៣ | កំលាំងពលកម្មដែលបានកែតំរូវ ២00៣ | ការប្រែប្រួលកំលាំងពលកម្ម | % នៃការប្រែប្រួល |
|---|---|---|---|---|---|---|---|---|
| 10-14 | 1.658.196 | 74.904 | 4,52 | 1.772.820 | 80.082 | 79.041 | 4.137 | 5,52 |
| 15 – 19 | 1.344.258 | 652.735 | 48,56 | 1.658.196 | 805.175 | 796.318 | 143.583 | 22,00 |
| 20 – 24 | 745.687 | 615.936 | 82,60 | 1.344.258 | 1.110.354 | 1.093.699 | 477.763 | 77,57 |
| 25 – 29 | 888.540 | 785.409 | 88,39 | 745.687 | 659.137 | 648.590 | -136.819 | -17,42 |
| 30 – 34 | 782.682 | 704.222 | 89,98 | 888.540 | 799.468 | 777.083 | 72.861 | 10,35 |
| 35 – 39 | 695.868 | 631.919 | 90,81 | 782.682 | 710.755 | 694.408 | 62.489 | 9,89 |
| 40 – 44 | 497.067 | 448.200 | 90,17 | 695.868 | 627.457 | 616.163 | 167.963 | 37,47 |
| 45 – 49 | 415.931 | 376.350 | 90,48 | 497.067 | 449.765 | 434.473 | 58.123 | 15,44 |
| 50 – 54 | 312.463 | 275.263 | 88,09 | 415.931 | 366,413 | 351.756 | 76.493 | 27,79 |
| 55 – 59 | 256.930 | 215.638 | 83,93 | 312.463 | 262.246 | 252.281 | 36.643 | 16,99 |
| 60 – 64 | 204.994 | 148.489 | 72,44 | 256.930 | 186.109 | 171.779 | 23.290 | 15,68 |
| 65 – 69 | 166.928 | 48.794 | 29,23 | 204.994 | 59.921 | 54.109 | 5.315 | 10,89 |
| សរុប | 7.969.544 | 4.977.859 | 62,46 | 9.575.436 | 6.116.881 | 5.969.699 | 991.840 | 19,93 |

*កំណត់សំគាល់: (១) រួមទាំងអ្នកដែលមានការធ្វើ និងអ្នកដែលគ្មានការធ្វើពីមុន ។ អង្កេត NIS បញ្ចូលប្រជាជនទាំងអស់ ដែលមានអាយុលើ ៦ឆ្នាំក្នុងកំលាំងពលកម្ម ។ (២) អត្រាចូលរួមក្នុងកំលាំងពលកម្មរបស់ប្រជាជនដែលមានអាយុក្រោម ១០ឆ្នាំ និងលើសពី ៦៩ឆ្នាំមិនត្រូវបានរាប់បញ្ចូលទេ អាស្រ័យដោយអត្រាចូលរួមរបស់ពួកគេមានកំរិតទាប ។ (៣) តួលេខត្រូវបានកែតំរូវដោយគិតអត្រាចូលរួមនៃក្រុមអាយុជាក់លាក់នៅក្នុងកំលាំងពលកម្ម និងអត្រាមរណៈនៃក្រុមអាយុជាក់លាក់ ។ ប្រភព: ការគណនារបស់អ្នកនិពន្ធផ្អែកលើ Huguet (1997:5) និងតារាងអាទិភាពនានារបស់ជំរឿនប្រជាជន ១៩៩៨(1999, CDROM # 1) ។*

**តារាង២.៣. ប្រជាជនសរុប កំលាំងពលកម្ម និងផ្ទៃដាំស្រូវ ក្នុងខេត្ត ១៩៩៨**

| ខេត្ត | ប្រជាជនសរុប '000 | ផ្ទៃដី '000ហិកតា | % នៃប្រជាជន នៅតាមជនបទ | % នៃកំលាំង ពលកម្មកសិកម្ម | ដីដាំស្រូវ '000ហិកតា | ដីស្រូវ/កំលាំង ពលកម្មម្នាក់ |
|---|---|---|---|---|---|---|
| កំពង់ចាម | 1.609 | 942 | 97 | 84,77 | 189 | 0,32 |
| កណ្តាល | 1.075 | 357 | 95 | 76,27 | 88 | 0,25 |
| ភ្នំពេញ | 1.000 | 37 | 43 | 9,64 | 9 | 0,24 |
| ព្រៃវែង | 946 | 482 | 94 | 89,97 | 262 | 0,65 |
| បាត់តំបង | 793 | 1.245 | 82 | 70,11 | 203 | 0,96 |
| តាកែវ | 790 | 349 | 95 | 89,79 | 229 | 0,74 |
| សៀមរាប | 696 | 1.196 | 83 | 81,93 | 192 | 0,76 |
| កំពង់ស្ពឺ | 599 | 682 | 93 | 88,92 | 85 | 0,36 |
| បន្ទាយមានជ័យ | 578 | 671 | 83 | 74,63 | 158 | 0,88 |
| កំពងធំ | 569 | 1.245 | 88 | 86,05 | 123 | 0,65 |
| កំពត | 528 | 469 | 94 | 87,27 | 132 | 0,65 |
| ស្វាយរៀង | 478 | 286 | 96 | 90,27 | 164 | 0,82 |
| កំពង់ឆ្នាំង | 418 | 529 | 90 | 85,19 | 90 | 0,55 |
| ពោធិសាត់ | 360 | 1.160 | 84 | 82,20 | 77 | 0,61 |
| ក្រចេះ | 263 | 1.197 | 70 | 77,58 | 30 | 0,36 |
| ក្រុងព្រះសីហនុ | 156 | 139 | n.a. | 49,81 | 10 | 0,33 |
| កោះកុង | 132 | 1.239 | 78 | 51,80 | 7 | 0,26 |
| ព្រះវិហារ | 119 | 1.402 | 82 | 83,21 | 15 | 0,33 |
| រតនៈគីរី | 94 | 1.190 | 82 | 88,10 | 17 | 0,40 |
| ស្ទឹងត្រែង | 81 | 1.190 | 70 | 79,17 | 16 | 0,51 |
| ឧត្តមានជ័យ | 68 | 511 | 7 | 78,80 | n.a. | n.a. |
| មណ្ឌលគីរី | 32 | 1.366 | 78 | 74,28 | 5 | 0,45 |
| ក្រុងកែប | 29 | 15 | n.a. | 81,71 | 3 | 0,26 |
| ក្រុងប៉ៃលិន | 23 | 255 | n.a. | 48,78 | n.a. | n.a. |
| កម្ពុជា | 11.438 | 18.153 | 84 | 76,82 | 2.104 | 0,56 |

*ប្រភព: NIS (1999) និង Dept. of Planning and Statistics (1999) ។*

ដង់ស៊ីតេប្រជាជន និងអត្រាដី/អត្រាកំលាំងពលកម្មក៏មានភាពខុសគ្នាខ្លាំងតាមតំបន់ផងដែរ ដែលបង្កើនសម្ពាធទៅលើដីធ្លីកាន់តែធំថែមទៀត ។ ប្រជាជនភាគច្រើនប្រមូលផ្តុំនៅក្នុងតំបន់វាលទំនាបដែលលាតសន្ធឹងពីអគ្នេយ៍ (ជាប់ព្រំប្រទល់ប្រទេសវៀតណាម) ទៅពាយព្យ (ជាប់ព្រំប្រទល់ថៃ) ។ មើលតារាង២.៣ និងក្រាហ្វិក ២.១ ។ អាស្រ័យដោយជំរឿន១៩៩៨ ជាង ៩០% នៃប្រជាជនទាំងអស់រស់នៅក្នុងតំបន់កណ្តាលក្នុងខេត្ត១៥[២] ដែលមានផ្ទៃដីតែ ៦០% នៃផ្ទៃដីទាំងអស់ ។ សម្ពាធដីធ្លីនៅក្នុងតំបន់ទាំងនេះមានកំរិតខ្ពស់រួចស្រេចទៅហើយ ។ ទំហំដីស្រែជាមធ្យមក្នុងមនុស្សម្នាក់នៃកំលាំងពលកម្មកសិកម្មមានទំហំពី ០,២៣ហិកតា នៅភ្នំពេញ ដល់ ០,៨៨ហិកតានៅខេត្តបន្ទាយមានជ័យ (តារាង២.៣) ។

ស្ថានការណ៍នេះអាចកាន់តែធ្ងន់ធ្ងរថែមទៀត នៅកំរិតគ្រួសារជាងតួលេខសរុប ។ ផ្នែកខាងក្រោមនេះមានបំណែងកំណត់ប្រភេទនៃបញ្ហាដីធ្លីនៅកំរិតគ្រួសារក្នុងប្រទេសកម្ពុជា ។ អាស្រ័យដោយមិនមានទិន្នន័យ និងការអង្កេតអោយបានគ្រប់ជ្រុង

២ ខេត្តទាំង១៥ គឺភ្នំពេញ កណ្តាល តាកែវ ព្រៃវែង កំ.ចាម ស្វាយរៀង កំពត កំ.ស្ពឺ បន្ទាយមានជ័យ កំ.ឆ្នាំង បាត់ដំបង សៀមរាប កំពង់ធំ ពោធិសាត់ និងក្រចេះ ។

ជ្រោយពីបញ្ហាដែលពាក់ព័ន្ធនឹងដីធ្លី វាជាការលំបាកក្នុងការវាយតំលៃទំហំនៃបញ្ហាដីធ្លីនានា និងផលប៉ះពាល់ទៅលើគ្រួសារ ។ ជាសំណាងល្អ គេមានអង្កេតមួយចំនួនដែលរួមគ្នាផ្តល់រូបភាពមួយចំនួននៃស្ថានការណ៍នេះ ទោះមិនល្អិតល្អន់ក៏ដោយ ។

**រូបភាព២.១. ដង់ស៊ីតេប្រជាជន ១៩៩៨**




*ប្រភព: ជំរឿនឆ្នាំ១៩៩៨ ។*

## ២.២ ការទទួលបានដីធ្លី

### ២.២.១ សាវតារសង្ខេប

ដោយហេតុថា ដីជាសម្បត្តិដ៏មានតំលៃជាងគេបង្អស់សំរាប់ប្រជាជនភាគច្រើន រដ្ឋាភិបាលនានាដែលគ្រប់គ្រងប្រទេសកម្ពុជាបានយកបញ្ហាដីធ្លីនេះមកពិចារណាក្នុងការធ្វើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងក្នុងការកាត់បន្ថយភាពក្រីក្រឱ្យមានចីរភាព ។ ជាញឹកញាប់ ដីធ្លីជាចំនុចប្រមូលផ្តុំនៃអន្តរាគមន៍របស់រដ្ឋាភិបាល ដូចជាការកែសម្រួលគោលនយោបាយដីធ្លីដែលបានដាក់អោយអនុវត្តតាំងពីសតវត្សរ៍ទី១៩ មកបានបង្ហាអោយឃើញស្រាប់ ។

*មុនសម័យអាណានិគមបារាំង (មុនឆ្នាំ១៨៦៣):* គេមានជំនឿថា ដីទាំងអស់ជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ[៣] ។ ក្នុងការអនុវត្តន៍ជាក់ស្តែង ប្រជាជនភាគច្រើនមានសិទ្ធិប្រកបរបរកសិកម្មនៅលើដីធ្លីរបស់ខ្លួនដោយសេរី និងអាចកាន់កាប់ និងប្រើប្រាស់ដីទៅតាមលទ្ធភាពដែលខ្លួនអាចធ្វើបាន ។ ដោយប្រជាជនមានចំនួនតិច និងពុំទាន់មានទីផ្សារដីធ្លីផង កសិករម្ចាស់ដីអាចចល័តពីកន្លែងមួយទៅកន្លែងមួយទៀតដោយសេរី និងក្លាយជាម្ចាស់ដីដែលខ្លួនបានត្រួសត្រាយ ។ ពួកគេមានសិទ្ធិផ្តាច់មុខក្នុងការកាន់កាប់ប្រើប្រាស់ និងទទួលមរតកដីកសិកម្មដោយមិនបាច់បំពេញបែបបទផ្លូវការណាមួយឡើយ ក្រៅតែពីកំណែន និងសួយ

៣ តាមទ្រឹស្តី ព្រះមហាក្សត្រមានសិទ្ធិផ្តាច់ការនៅលើដីធ្លី (Meijers, 1994:3) ។

សារផ្សេងៗជាលក្ខណៈសក្ដិភូមិ ។

*សម័យអាណានិគមបារាំង (១៨៦៣-១៩៥៣):* បន្ទាប់ពីដាក់អាណានិគមលើប្រទេសកម្ពុជាក្នុងឆ្នាំ១៨៦៣ បារាំងបានកែប្រែប្រព័ន្ធកាន់កាន់ និងប្រើប្រាស់ដីធ្លីជាប្រពៃណីក្នុងប្រទេសកម្ពុជា ដោយប្រកាសអោយប្រើប្រាស់ច្បាប់ដីធ្លីមួយនៅឆ្នាំ១៨៨៤ ។ ដោយសារតែមានចលនាតស៊ូរបស់កសិករកម្ពុជា ច្បាប់នេះមិនត្រូវបានអនុវត្តពេញលេញទេមុនឆ្នាំ១៩១២ ។ មកដល់ឆ្នាំ១៩៣០ ដីស្រែភាគច្រើនត្រូវបានគេចុះបញ្ជីជាទ្រព្យសម្បត្តិឯកជន ហើយប្រជាជនមានសេរីភាពគ្រប់គ្រាន់ក្នុងការលក់ដូរដីធ្លីរបស់ពួកគេដែរ ។ សំខាន់ជាងនេះទៀត ចំពោះដីទាំងអស់ដែលនៅទំនេរ ឬគ្មានអ្នកណាកាន់កាប់ គេអាចយកវាជាកម្មសិទ្ធិតាមទំលាប់ពីមុនបាន[៤] និងអាចលក់ដូរបានក្រោយពេលបានកាប់ឆ្ការ និងកាន់កាប់វាហើយ ។ ដីព្រៃនៅមានច្រើនណាស់ទោះជាគេបានអនុញ្ញាតអោយអ្នកដែលកាប់ឆ្ការ និងកាន់កាប់លក់ ហើយចល័តទៅកន្លែងថ្មីក៏ដោយ ។ មកដល់ឆ្នាំ១៩៣០ ដីភាគច្រើនត្រូវបានបែងចែកជាដុំៗ មានទំហំមិនលើសពី ៥ហិកតា ហើយចំការដំណាំធំៗក៏ត្រូវបានបង្កើតឡើង (Greve, 1993) ។

*សម័យឯករាជ្យ (១៩៥៣-១៩៧៥):* បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យពីប្រទេសបារាំងនៅឆ្នាំ១៩៥៣ ប្រព័ន្ធកម្មសិទ្ធិដីធ្លីតាមបែបលោកខាងលិចត្រូវបានអនុវត្តជាបន្តទៀត ដោយមានកំណើននៃការទិញដូរដីធ្លី ។ លោក Meijers (១៩៩៤) បានអះអាងថា មកដល់ឆ្នាំ១៩៦២ ប្រជាជនមិនមែនជាកសិករជាង ៣០,០០០គ្រួសារ មានដីធ្លី ។ គាត់បានបញ្ជាក់ថា ទោះបីជាជំរឿននៅឆ្នាំ១៩៦២ បានបង្ហាញអោយឃើញថា ក្នុងចំណោមកសិករប្រហែល ៨០០,០០០គ្រួសារ មាន ៨៤% បាន កាន់កាប់ដីធ្លីក្នុងទំរង់ជា "ម្ចាស់" ប៉ុន្តែគ្រួសារទាំងនោះពុំមានជីវភាពធូរធារណាស់ណាទេ ។

ដោយសារតែដីស្រែភាគច្រើនផ្ដល់ទិន្នផលស្រូវទាបប្រហែល ១តោន/ហិកតា នៅក្នុងប្រព័ន្ធផលិតកម្មដែលពឹងផ្អែកលើទឹកភ្លៀងជាសំខាន់ កសិករតែងតែជំពាក់បំណុលគេ (ឧ. បីភាគបួនក្នុងឆ្នាំ១៩៥២) ហើយក្នុងចំនោមនោះមួយចំនួនក៏បានក្លាយជា អ្នកគ្មានដី ។ សំរាប់ការចំនាយក្នុងផលិតកម្ម និងក្រៅពីផលិតកម្មរបស់ពួកគេកសិករច្រើនតែខ្ចីបុលពីពួកអ្នកចងការប្រាក់ឯកជន ដែលយកការប្រាក់យ៉ាងខ្ពស់រហូតដល់ ៣០% ហើយជួនកាលដល់ទៅ ១០០-២០០% ក្នុងមួយរដូវ (Meijers, 1994) ។ ដើម្បី សងបំនុលកសិករត្រូវបង្ខំចិត្តលក់ផលស្រូវរបស់ពួកគេឱ្យអ្នកចងការប្រាក់ឯកជនក្នុងតំលៃមួយដែលមានកំរិតទាបជាងទីផ្សារ ។ ជាលទ្ធផលកសិករនៅសល់ផលិតផលតែបន្តិចបន្តួចប៉ុណ្ណោះសំរាប់ចិញ្ចឹមគ្រួសារ ហើយត្រូវតែខ្ចីប្រាក់ជាថ្មីម្ដងទៀត ហើយនឹងត្រូវសងនៅរដូវប្រមូលផលលើកក្រោយ ។ ក្នុងដំណើរការនេះ កសិករមួយចំនួននៅទីបំផុតត្រូវលក់ដីដើម្បីសងបំណុលគេ ហើយក៏ក្លាយជាអ្នកគ្មានដីធ្លី (Greve, 1993) ។

*របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩):* ពួកខ្មែរកុម្មុយនិស្តដែលគេស្គាល់ថាជាខ្មែរក្រហម បានដណ្ដើមអំណាចពី លន់ ណុល និងបានប្រកាសយកឆ្នាំ១៩៧៥ ជាឆ្នាំសូន្យ ។ នៅក្រោមមនោគមវិជ្ជារបស់ខ្មែរក្រហម ប្រជាជនទាំងអស់មានសិទ្ធិស្មើៗគ្នា ហើយត្រូវធ្វើស្រែចំការ ។ ដីធ្លីទាំងអស់ជាសម្បត្តិរបស់អង្គការ ហើយគ្មាននរណាម្នាក់អាចមានដីធ្លី ទោះជាតូចក៏ដោយ ដោយសារតែទ្រព្យសម្បត្តិឯកជន[៥] និងកម្មសិទ្ធិឯកជន[៦] ត្រូវបានគេលុបបំបាត់ចោល ។ អង្គការ គឺជាម្ចាស់ទឹកម្ចាស់ដី (Greve, 1993) ។

ផលិតកម្មស្រូវ គឺជាអាទិភាពខ្ពស់បំផុតនៅក្នុងគោលនយោបាយខ្មែរក្រហម ។ ដីស្រែត្រូវបានរៀបចំឡើងវិញជាស្រែដែលមានទំហំ ១ហិកតា ហើយប្រព័ន្ធផលិតកម្មត្រូវបានរៀបចំ ជាសហករណ៍ដែលមានរបបធ្វើការងារធ្ងន់ធ្ងរបំផុតរហូតដល់

---

៤ សិទ្ធិក្នុងការរានដីព្រៃ ឬដីនៅទំនេរដើម្បីកាន់កាប់ ប្រើប្រាស់ និងផ្ទេរមរតក។

៥ គឺជាទ្រព្យដែលជាទូទៅមិនផ្ដល់អត្ថប្រយោជន៍ដល់សាធារណជនទាំងមូលទេ ហើយដែលបុគ្គលឯកជនអាចយកជាកម្មសិទ្ធិរបស់ខ្លួនបាន ។

៦ គឺស្ថានភាពដែលបុគ្គល/គ្រួសារជាឯកជនណាមួយ ត្រូវបានអនុញ្ញាតឱ្យមានកម្មសិទ្ធិលើទ្រព្យអ្វីមួយ ។

១៨ ម៉ោងក្នុងមួយថ្ងៃ ។ ដោយមានបំណងបង្កើនទិន្នផលស្រូវអោយបាន ៧តោន/ហិកតា ប្រព័ន្ធស្រោចស្រពជាច្រើនដែលមិនសម ស្របតាមលក្ខណៈបច្ចេកទេសដូចជា ប្រឡាយ ទំនប់ទឹក និងអាងស្តុកទឹក ជាដើមត្រូវបានកសាងឡើងដោយប្រើកំលាំងពលកម្ម មនុស្ស ។ សំណង់ធារាសាស្ត្រទាំងនេះភាគច្រើនពុំមានប្រសិទ្ធភាពទេ ។

*សម័យសេដ្ឋកិច្ចតាមផែនការប្រមូលផ្តុំ (១៩៧៩-១៩៨៩):* បន្ទាប់ពីពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបាន ទទួលបរាជ័យនៅឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានទទួលរងការខូចខាតយ៉ាងធំធេង និងប្រឈមមុខនឹងការគំរាមកំហែងនៃគ្រោះទុរ្ភិក្ស ។ ប្រជាជនរាប់លាននាក់ដែលត្រូវបានជម្លៀសចេញពីភូមិ-ឃុំរបស់ពួកគេ និងដែលកំពុងមានការអត់ឃ្លានបានវិលត្រឡប់មកកាន់ភូមិដ្ឋានរបស់ពួកគេវិញ ។ ដោយមានជំនួយបរទេសតែបន្តិចបន្តួច (ភាគច្រើនជាជំនួយពីអតីតប្លុកកុម្មុនិស្ត) និងនៅក្នុងស្ថានភាពដែលហេដ្ឋារចនាសម្ព័ន្ធត្រូវបានខ្ទេចខ្ទាំដោយសារតែសង្គ្រាម និងធនធានមនុស្សមានការខ្វះខាតយ៉ាងខ្លាំង រដ្ឋាភិបាលបានសំរេចបង្កើតរបបកម្មសិទ្ធិសមូហភាព[៧] នៅលើដីធ្លី និងផ្ទះសំបែង ។ ដោយសារមានការខ្វះខាត កំលាំងពលកម្មកំលាំងអូសទាញ ឧបករណ៍ផលិតកម្ម រដ្ឋាភិបាលក៏បានបង្កើតឡើងនូវក្រុមសាមគ្គី ដើម្បីដោះស្រាយជាបន្ទាន់នូវតំរូវការស្បៀង ។

ក្រុមសាមគ្គីនីមួយៗ មានសមាជិកប្រមាណ ១០-១៥ គ្រួសារដែលប្រើប្រាស់ដីធ្លី កំលាំងពលកម្ម និងសត្វអូសទាញរួមគ្នា ។ ក្រុមសាមគ្គីត្រូវបានអនុញ្ញាតឱ្យកាន់កាប់ និងប្រើប្រាស់ដីកសិកម្ម ទោះបីជាផ្លូវការ ដីទាំងអស់ក្នុងនេះមានទាំងដីលំនៅដ្ឋានផង គឺជាកម្មសិទ្ធិរបស់រដ្ឋក៏ដោយ ។ ដីត្រូវបានបែងចែកទៅឱ្យក្រុមសាមគ្គី ដោយផ្អែកលើមូលដ្ឋានកំលាំងពលកម្មក្នុងក្រុម កំលាំងអូសទាញ និងទំហំដីដែលមាននៅតាមតំបន់នីមួយៗ ។ គួរបញ្ជាក់ជាពិសេសថា ទោះបីនៅពេលនោះដីទាំងអស់ គឺជារបស់រដ្ឋក៏ដោយ ក៏ម្តងម្កាលគេសង្កេតឃើញដីលំនៅដ្ឋានខ្លះៗ ត្រូវបានប្រជាជនផ្ទេរចុះឡើងជាលក្ខណៈក្រៅផ្លូវការតាមការព្រមព្រៀងគ្នាទៅវិញទៅមកនៅក្នុងកំឡុងពេលនោះ (Greve, 1993)[៨] ។

*សម័យកាលក្រោយឆ្នាំ១៩៨៩ (១៩៨៩-បច្ចុប្បន្ន):* មកដល់ឆ្នាំ១៩៨៩ គេអាចមើលឃើញយ៉ាងច្បាស់នូវបរាជ័យនៃរបបសមូហភាព និងប្រព័ន្ធសេដ្ឋកិច្ចតាមផែនការប្រមូលផ្តុំ ដោយរដ្ឋាភិបាលបានយល់ច្បាស់ថា នៅក្នុងស្ថានភាពនៃប្រទេសកម្ពុជា គេមិនអាចអនុវត្តគោលនយោបាយបែបនេះបានទេ ។ បន្ទាប់ពីការកាត់បន្ថយយ៉ាងច្រើន នូវជំនួយឧបត្ថម្ភពីបណ្តាប្រទេសប្លុកខាងកើត រដ្ឋាភិបាលបានចាប់ផ្តើមធ្វើកំណែទំរង់លើប្រព័ន្ធសេដ្ឋកិច្ចទាំងមូល ដើម្បីឈានទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចតាមទីផ្សារសេរីវិញ នៅឆ្នាំ១៩៨៩ ។ បន្ថែមលើកំណែទំរង់ដ៏សំខាន់ៗ ខាងសេដ្ឋកិច្ច រដ្ឋាភិបាលក៏បានឈានមួយជំហានទៀតដោយអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លីឡើងវិញ[៩] ។

យោងតាមសេចក្តីប្រកាសណែនាំលេខ ០៣ ដីទាំងអស់នៅក្នុងប្រទេសកម្ពុជា គឺជារបស់រដ្ឋ "ដីធ្លីនៃរដ្ឋកម្ពុជា ជាសម្បត្តិរបស់រដ្ឋ" ។ ប៉ុន្តែជនកម្ពុជាមានសិទ្ធិកាន់កាប់ និងប្រើប្រាស់ដី "ពលរដ្ឋកម្ពុជាមានសិទ្ធិពេញទី ក្នុងការកាន់កាប់ប្រើប្រាស់ដី និងមានសិទ្ធិតំណមរតកលើដីធ្លីដែលរដ្ឋប្រគល់ឱ្យសំរាប់រស់នៅ និងធ្វើអាជីវកម្ម" ។ ក្នុងពេលជាមួយគ្នានោះ កម្មសិទ្ធិមុនឆ្នាំ១៩៧៩ ត្រូវបានចាត់ទុកជាមោឃៈ "គ្មានជនណាម្នាក់អាចទាមទារសិទ្ធិលើកម្មសិទ្ធិចាស់មុនឆ្នាំ១៩៧៩ លើដីធ្លីបានទេ" ។ បន្ថែមលើនេះទៀត ការកាន់កាប់ដី និងអគារលំនៅដ្ឋានចាប់តាំងពីថ្ងៃ ៧ មករា ១៩៧៩ មកត្រូវបានរដ្ឋទទួលស្គាល់: "រដ្ឋមិនសើរើ និងបែងចែកជាថ្មីលើដីដែលបានកាន់កាប់រួចហើយ ចាប់ពីថ្ងៃរំដោះ ៧ មករា ១៩៧៩ មកទល់ថ្ងៃចេញសេចក្តីណែនាំអនុវត្តនេះ រហូតដល់មានច្បាប់ភូមិបាល" ។ សេចក្តីប្រកាសនេះបានបែងចែកដីជាបីប្រភេទដូចតទៅ:

---

៧ សិទ្ធិផ្តល់អោយប្រជាជនមួយក្រុម (សមូហភាព ឬក្រុមសាមគ្គី) ដើម្បីកាន់កាប់ និងប្រើប្រាស់ហើយផលដែលទទួលបានពីដីនោះ ត្រូវបានបែងចែកឱ្យសមាជិកក្រុមគ្រប់ៗគ្នា ។

៨ ពត៌មាននេះបានទទួលពីការសំភាសន៍ជាមួយលោក ហ៊ុយ ភាព អនុប្រធានការិយាល័យអភិរក្សដី និងបច្ចុប្បន្ន ជាអនុប្រធាននាយកដ្ឋានអភិរក្សសុរិយោដីនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ។

៩ គឺសិទ្ធិផ្តល់ឱ្យបុគ្គល/គ្រួសារ ជាឯកជន មានកម្មសិទ្ធិលើដី/អគារ សំរាប់លំនៅដ្ឋាន និងមានសិទ្ធិកាន់កាប់ (ភោគៈ) ដី កសិកម្ម ។

- ដីលំនៅដ្ឋានៈ នឹងប្រគល់ជូនជាកម្មសិទ្ធិចំពោះដីសំរាប់សង់លំនៅដ្ឋាន ដែលត្រូវសំរេចចេញដោយប្រធានគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ។
- ដីដាំដុះ/ដីកសិកម្មៈ ផ្តល់ជូនជាភោគៈ ។ ដីភោគៈ គឺជាដីដែលរដ្ឋប្រគល់សិទ្ធិផ្តាច់មុខជូនដល់គ្រួសារកសិករកាន់កាប់ប្រើប្រាស់ក្នុងពេលធ្វើផលិតកម្ម អាជីវកម្ម និងបន្តមរតក ។ និង
- ដីសម្បទានៈ ដីនេះត្រូវមានទំហំលើសពី ៥ហិកតាឡើងទៅ ។ សម្បទាន គឺជាសិទ្ធិកាន់កាប់ដីសំរាប់ផលិតកម្មផលដំណាំទ្រង់ទ្រាយធំ ដែលបំរើអោយសេដ្ឋកិច្ចជាតិ ។

ចំពោះដីទាំងបីប្រភេទខាងលើ មានតែដីលំនៅដ្ឋានទេដែលរដ្ឋអាចផ្តល់កម្មសិទ្ធិឯកជនឱ្យបាន ចំណែកឯដីដាំដុះផ្តល់ឱ្យត្រឹមសិទ្ធិភោគៈ (សិទ្ធិកាន់កាប់ និងប្រើប្រាស់) និងដីសម្បទានផ្តល់ឱ្យត្រឹមសិទ្ធិកាន់កាប់ផ្តាច់មុខ ។

ជាមួយគ្នានឹងការអនុញ្ញាតឡើងវិញនូវកម្មសិទ្ធិឯកជនលើដីធ្លី អនុក្រិត្យលេខ២៥ និងសេចក្តីប្រកាសលេខ ០៣ ក៏បានធ្វើការបែងចែកឡើងវិញនូវដីធ្លីទៅឱ្យគ្រួសារឯកជននានា ។ ការបែងចែកដីនៅពេលនោះផ្អែកលើចំនួនសមាជិកក្នុងគ្រួសារនីមួយៗ និងទំហំដីដែលមាននៅតាមតំបន់នីមួយៗ ។ ជាទូទៅ ការបែងចែកដីត្រូវបានអនុវត្តឡើងដោយរដ្ឋអំណាចមូលដ្ឋានដោយមានការចូលរួមយ៉ាងផុលផុសពីសំណាក់សហគមន៍ក្នុងមូលដ្ឋាន ។ នៅក្នុងការងារនេះ ពួកអ្នកភូមិប្រហែលជាបានមកជួបជុំគ្នាដើម្បីធ្វើស្ថិតិសមាជិកក្នុងគ្រួសារនីមួយៗ និងកំណត់ពីទំហំដីដែលមាននៅក្នុងភូមិ-ឃុំរបស់ពួកគេ ។ បន្ទាប់មកគេធ្វើការបែងចែកដី ទៅតាមចំនួនសមាជិកក្នុងគ្រួសារ និងទំហំដីធ្លីដែលមាននៅកន្លែងនោះ ។ គុណភាពដី និងទីតាំងនៃ ដីធ្លីគេក៏យកមកគិតគូរដែរ ។ ហេតុដូច្នេះហើយ បានជាគ្រួសារនីមួយៗ ទទួលបានដីកសិកម្ម ២-៣កន្លែង ។ ការបែងចែកដីនៅពេលនោះហាក់ដូចជា បានស្មើភាពគ្នាល្អចំពោះប្រជាជនធម្មតា និងជនដែលវិលមករួមរស់ក្នុងសង្គមជាតិវិញផងដែរ ពីព្រោះសេចក្តីប្រកាសបានបញ្ជាក់យ៉ាងច្បាស់ថា ចំពោះជនភៀសខ្លួនកម្ពុជា ជនរួមជាតិកម្ពុជានៅបរទេសដែលបានវិលត្រឡប់មកមាតុភូមិវិញ និងជនទាំងឡាយដែលបានបោះបង់ចោលជួរខ្មាំង (ខ្មែរក្រហម) វិលត្រឡប់មកជាមួយប្រជាជនវិញ នឹងត្រូវបែងចែក (បើពួកគេវិលមករស់នៅក្នុងភូមិ) ដីសង់លំនៅដ្ឋាន ដីស្រែចំការសល់ទំនេរ ឬដីរុករានថ្មីសមស្របតាមលទ្ធភាពមូលដ្ឋាននីមួយៗ (Meijers, 1994) ។

ទំហំដីដែលគ្រួសារនីមួយៗ ទទួលបានវាប្រែប្រួលទៅតាមដង់ស៊ីតេប្រជាជននៅក្នុងតំបន់នីមួយៗ ។ នៅតាមបណ្តាខេត្តមួយចំនួនដែលមានដង់ស៊ីតេប្រជាជនទាប ប្រជាជនអាចទទួលបានរហូតដល់ ៣ហិកតាក្នុងមួយគ្រួសារ (ឧ. ខេត្តពោធិសាត់) ចំណែកឯនៅតាមខេត្តដែលមានដង់ស៊ីតេប្រជាជនខ្ពស់ប្រជាជនទទួលបានតែ ០.៥-១.០ហិកតាក្នុងមួយគ្រួសារប៉ុណ្ណោះ ដូចជានៅខេត្តតាកែវជាដើម[១០] ។ មានតែដីលំនៅដ្ឋាន និងដីដាំដុះទេដែលត្រូវបានបែងចែកទៅឱ្យប្រជាជនជាកម្មសិទ្ធិ ឬឱ្យប្រជាជនកាន់កាប់ ។ ចំណែកឯដីទៅសល់ផ្សេងទៀតត្រូវរក្សាទុកជាដីរបស់រដ្ឋ ឬដីរួមសំរាប់ការអភិវឌ្ឍន៍នាពេលអនាគត ។

បន្ថែមលើអនុក្រឹត្យលេខ២៥ និងសេចក្តីប្រកាសណែនាំលេខ ០៣ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ក៏បានកំណត់ឡើងនូវបទប្បញ្ញត្តិដ៏សំខាន់ៗដូចជា មាត្រា១ និងមាត្រា២ ជាដើមៈ

*មាត្រា១: ដីធ្លីនៃរដ្ឋកម្ពុជាជាសម្បត្តិរបស់រដ្ឋ ហើយត្រូវបានរដ្ឋគ្រប់គ្រងដោយឯកភាពទូទាំងប្រទេស ។ រដ្ឋមិនទទួលស្គាល់ដាច់ខាត របបកម្មសិទ្ធិចាស់លើដីធ្លីមុនឆ្នាំ១៩៧៩ ។ កម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើដីធ្លីត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់នេះ ។*

*មាត្រា២: ពលរដ្ឋកម្ពុជាមានសិទ្ធិពេញទីក្នុងការកាន់កាប់ ប្រើប្រាស់ដី និងមានសិទ្ធិតំណមរតកលើដីធ្លីដែលរដ្ឋប្រគល់*

---

១០ Huy, P (1999) ។ សំភាសន៍នៅថ្ងៃទី ២៣ មិថុនា ឆ្នាំ១៩៩៩ នៅភ្នំពេញ ។

*ឱ្យសំរាប់រស់នៅ និងធ្វើអាជីវកម្ម ។*

មាត្រានេះមានន័យថា ដីធ្លីទាំងអស់ជាទ្រព្យសម្បត្តិរបស់រដ្ឋ តែប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ ប្រើប្រាស់ ផ្ទេរ និងបន្តមរតក រីឯកម្មសិទ្ធិមុនឆ្នាំ១៩៧៩ មិនត្រូវបានបង្វិលទៅឱ្យម្ចាស់ពីមុននោះវិញទេ ។

### ២.២.២ ការពិពណ៌នាទិន្នន័យ

ការសិក្សានេះមានបំណងកំណត់រក និងធ្វើវិភាគនូវអថេរមួយចំនួនធំនៃកត្តាដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី និងដែលមានស្រាប់នៅក្នុងមូលដ្ឋានទិន្នន័យធំៗមួយចំនួន ។ យើងបានទទួលពីស្ថាប័នផ្សេងៗនូវទិន្នន័យនៃអង្កេតគ្រួសារទ្រង់ទ្រាយធំចំនួនបួន គឺពីគណៈកម្មការទន្លេមេគង្គ (MRC) ពីវិទ្យាស្ថានជាតិស្ថិតិ (NIS) និងពីរទៀតពីអង្គការស្បៀងអាហារពិភពលោក (WFP) ។ ចំណុចសំខាន់ដែលត្រូវចងចាំ គឺអង្កេតទាំងនេះមានលក្ខណៈដោយឡែកៗពីគ្នា ពីព្រោះវាផ្តោតទៅលើក្រុមប្រជាជនខុសគ្នា ហើយគេបានរៀបចំវាឡើងដើម្បីបំរើគោលដៅផ្សេងៗគ្នា ។

*អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ចំពោះគ្រួសារនៅក្នុងសហគមន៍នេសាទ (ការវាយតំលៃខាងសេដ្ឋកិច្ច-សង្គមកិច្ចលើការនេសាទត្រីទឹកសាបនៅកម្ពុជា) គណៈកម្មការទន្លេមេគង្គ ឆ្នាំ១៩៩៥-៩៦ (តទៅនេះហៅថា អង្កេតMRC)*

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចមួយ លើគ្រួសារដែលរស់នៅក្នុងសហគមន៍នេសាទ ត្រូវបានធ្វើឡើងនៅចន្លោះ ឆ្នាំ១៩៩៥-៩៦ ដោយគណៈកម្មការទន្លេមេគង្គ (Mekong River Commission: MRC)[១១] នៅក្នុងគំរោង "ការគ្រប់គ្រងការនេសាទត្រីទឹកសាបនៅកម្ពុជា" ។ គោលបំណងចំបងនៃគំរោងនេះគឺ ការវាយតំលៃពីស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចនៃប្រជាពលរដ្ឋនានាដែលរស់នៅតាមបណ្តាឃុំពឹងផ្អែកលើការនេសាទ ដើម្បីទទួលបាននូវពត៌មានដ៏ចាំបាច់ និងការយល់ដឹងដ៏សមស្របមួយចំនួនសំរាប់ធ្វើការគ្រប់គ្រងធនធានត្រីទឹកសាបនៅកម្ពុជាឱ្យមានចីរភាព ។

ក្នុងការធ្វើអង្កេត គេបានជ្រើសយកខេត្ត-ក្រុងចំនួន៨[១២] ដែលមានប្រជាជនរស់នៅចំនួន ៤,១៩លាននាក់ (ជាង ៤០% នៃប្រជាជនសរុបទូទាំងប្រទេស) ដើម្បីសិក្សាស្រាវជ្រាវលើបណ្តាសហគមន៍ធ្វើនេសាទទឹកសាប ។ ក្នុងខេត្ត-ក្រុងទាំង៨ គេបានជ្រើសយក៩.១១៧ គ្រួសារសំណាកគំរូ តាមវិធីចៃដន្យចេញពី ៨៣ ឃុំសំណាកគំរូ នៅក្នុង ៥១ស្រុកមានសកម្មភាពនេសាទ ដើម្បីតំណាងឱ្យ ៣២៨ឃុំ ដែលពឹងផ្អែកលើការនេសាទ ។ ការជ្រើសរើសឃុំនេះបានគ្របដណ្តប់លើតំបន់នេសាទដ៏ធំទាំងពីររបស់ប្រទេសកម្ពុជាគឺ: ប្រព័ន្ធបឹងទន្លេសាបនិងទន្លេសាប និងប្រព័ន្ធទន្លេមេគង្គ-ទន្លេបាសាក់ ព្រមទាំងប្រព័ន្ធដីលិចទឹកដែលនៅជាប់ជាមួយគ្នា ។

### *អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៧ (តទៅនេះហៅថា អង្កេត SES)*

ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា គឺជាអង្កេតលើគ្រួសារដ៏ធំទីមួយ ដែលមានកម្មវត្ថុអង្កេតច្រើន ។ ការអង្កេតនេះត្រូវបានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ១៩៩៧ ។ កម្មវត្ថុចំបងនៃអង្កេតនេះ គឺការប្រមូលទិន្នន័យចាំបាច់មួយចំនួន ដើម្បីវាស់ស្ទង់កំរិតជីវភាពរបស់ប្រជាជន និងពិនិត្យតាមដាន និងវិភាគពីទំហំនៃភាពក្រីក្រ ។

ការធ្វើអង្កេតផ្អែកលើការជ្រើសរើសយកសំណាកគំរូតាមវិធីចៃដន្យពីរដំណាក់កាល (two-stage stratified random sampling design) ដោយជ្រើសយកភូមិសំណាកគំរូនៅកំរិតទីមួយ និងជ្រើសរើសយកគ្រួសារសំណាកគំរូនៅកំរិតទីពីរ ។ ក្របខ័ណ្ឌនៃការជ្រើសរើសបានគ្របដណ្តប់លើភូមិទាំងអស់នៅរាជធានីភ្នំពេញ ៩១,២% នៃភូមិនៅតាមទីប្រជុំជននៃខេត្ត-ក្រុងផ្សេងទៀត និង ៨៦,៣% នៃភូមិនៅតាមតំបន់ជនបទ ។ ប៉ុន្តែ ដោយសារមានបញ្ហាអសន្តិសុខនៅក្នុងខេត្ត២ និងឃុំ

---

១១ គំរោងមានឈ្មោះថា ការគ្រប់គ្រងការនេសាទត្រីទឹកសាបរបស់ប្រទេសកម្ពុជា។ សូមអានរបាយការណ៍របស់លោក Ahmed et al (998) ។

១២ គឺខេត្តសៀមរាប បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កណ្តាល ភ្នំពេញ កំពង់ចាម និងកំពង់ធំ ។

មួយចំនួនក្នុង ១៥ខេត្តផ្សេងទៀត ត្រូវបានដកចេញពីក្របខ័ណ្ឌនៃការធ្វើអង្កេត ។ អត្រាគ្រួសារដែលមិនត្រូវបានរាប់បញ្ចូលក្នុងការជ្រើសរើសយកធ្វើជាសំណាកគំរូ មានកំរិតទាបទេគឺ ៤,៨% នៃគ្រួសារដែលរស់នៅតាម "ទីប្រជុំជនផ្សេងទៀត" និង ១,៦% នៃគ្រួសារដែលរស់នៅតាមតំបន់ជនបទ ។

ផ្អែកតាមលក្ខណៈវិនិច្ឆ័យខាងលើ គេជ្រើសរើសបាន ៦.០១០គ្រួសារ ពីខេត្ត-ក្រុងមួយចំនួនដូចខាងក្រោម ដើម្បីធ្វើសម្ភាសន៍:

| | | | | | |
|---|---|---|---|---|---|
| ភ្នំពេញ | ១២០ | ភូមិសំណាកគំរូ | និង | ១.២០០ | គ្រួសារសំណាកគំរូ |
| ទីប្រជុំជនផ្សេងទៀត | ១០០ | ភូមិសំណាកគំរូ | និង | ១.០០០ | គ្រួសារសំណាកគំរូ |
| តំបន់ជនបទ | ២៥៤ | ភូមិសំណាកគំរូ | និង | ៣.៨១០ | គ្រួសារសំណាកគំរូ |
| សរុប | ៤៧៤ | ភូមិសំណាកគំរូ | និង | ៦.០១០ | គ្រួសារសំណាកគំរូ |

*អង្កេតមូលដ្ឋានឆ្នាំ១៩៩៨ នៃគំរោង CASD និងតំបន់មុខសញ្ញារបស់ WFP, UNICEF-WFP (តទៅនេះហៅថា អង្កេត Baseline)*

នេះជាអង្កេតរួមគ្នារបស់អង្គការ UNICEF និង WFP ហើយត្រូវបានធ្វើឡើងដោយអង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) ក្នុងខែឧសភា-មិថុនា ឆ្នាំ១៩៩៨ ។ អង្កេតនេះមានគោលដៅចំបងប្រមូលពត៌មានឱ្យបានសព្វគ្រប់សំរាប់យកមកប្រើក្នុងការកសាងការកំណត់គោលដៅ និងការវាយតំលៃ: (១) កម្មវិធីសកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គម (CASD) របស់ UNICEF ដែលផ្តោតលើបញ្ហាសុខភាព និងអាហារូបត្ថម្ភ និង (២) គំរោងរបស់ WFP ក្នុងវិស័យសន្តិសុខស្បៀង និងភាពងាយទទួលរងគ្រោះ ។ អង្កេតបានផ្តោតលើខេត្តមួយចំនួន ដោយជ្រើសយកភូមិដែលមានគំរោង CASD ឬកម្មវិធីរបស់ WFP ។ អង្កេតបានកំណត់យកជាសំណាកគំរូតែគ្រួសារណាដែលមានកុមារអាយុក្រោម ៥ឆ្នាំម្នាក់យ៉ាងតិច ។

ការអង្កេតនេះផ្អែកលើការជ្រើសរើសយកសំណាកគំរូ ដោយប្រើនីតិវិធីជ្រើសសំណាកគំរូច្រើនថ្នាក់ តាមវិធីចៃដន្យ (multi-stage random sampling procedure) ដោយយកភូមិជាឯកតាសំណាកគំរូគោល ។ ភូមិប្រហែល ៥០ ត្រូវបានជ្រើសរើសដោយចៃដន្យពីខេត្តចំនួន៦ ដែលមានគំរោង CASD-UNICEF ។ បន្ថែមលើនេះ ១៣ភូមិផ្សេងទៀតដែលមានគំរោង CASD-PFD ត្រូវបានជ្រើសរើសតាមវិធីចៃដន្យមកពីខេត្តស្ទឹងត្រែង និងក្រចេះ ។ ក្រៅពីនេះមាន ៦២ភូមិផ្សេងទៀតត្រូវបានជ្រើសរើសចេញពីតំបន់សេដ្ឋកិច្ចស្បៀង (food economy zones) នៃ WFP ដោយផ្អែកទៅលើការបែងចែកកំរិតជាតិនូវភូមិនានាជាតំបន់ៗ (national distribution of villages by zone) ។ សរុបមក គេបានជ្រើសយក ១២៥ភូមិ ដើម្បីធ្វើអង្កេត ។

ចំនួនគ្រួសារដែលត្រូវបានជ្រើសរើសក្នុងភូមិនីមួយៗ គឺអាស្រ័យដោយទំហំនៃភូមិនោះ ។ ភូមិខ្លះមានរហូតដល់ ៣០០គ្រួសារ ឯភូមិខ្លះទៀតមានត្រឹមតែ ៥០គ្រួសារប៉ុណ្ណោះ ។ អង្កេតនេះក៏បានកំនត់ចំនួនគ្រួសារដែលត្រូវធ្វើសំភាសន៍មកត្រឹម ៨គ្រួសារ ចំពោះភូមិដែលមានប្រជាជនតិចជាង ៨០គ្រួសារ, ១០គ្រួសារ ចំពោះភូមិដែលមាន ៨០-១២០គ្រួសារ និង ១២ គ្រួសារ ចំពោះភូមិដែលមានចំនួនលើសពី ១២០គ្រួសារ ។ សរុបមកមាន ១.២៣០គ្រួសារ ត្រូវជ្រើសរើសសំរាប់ធ្វើសំភាសន៍ ។

***អង្កេតមុខសញ្ញាសង្គ្រោះបន្ទាន់រយៈពេលយូរ UNWFP 1998 (តទៅនេះហៅថា អង្កេត PET)***

អង្កេតនេះត្រូវបានធ្វើឡើងដោយ WFP នៅចុងឆ្នាំ១៩៩៨ ។ គោលដៅចំបងនៃអង្កេត គឺប្រមូលពត៌មានជាមូលដ្ឋានមួយចំនួនដូចជា ស្ថានភាពសង្គម និងស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជនធ្វើមាតុភូមិនិវត្តន៍ និងជនភៀសសឹក (IDP)[១៣]

---

១៣ WFP-Cambodia បានឱ្យនិយមន័យជនភៀសសឹកថា "ជាជនទាំងឡាយដែលត្រូវបានជម្លៀសចេញពីកន្លែងរស់នៅជាធម្មតារបស់ពួកគេ ដោយសារការច្បាំងគ្នា

សំរាប់ប្រៀបធៀបនៅពេលគេធ្វើការវាស់វែងក្នុងឆ្នាំ២០០០ អំពីផលប៉ះពាល់នៃកម្មវិធីជំនួយ ។ ដូចជាអង្កេត Baseline ដែរ អង្កេត PET បានផ្តោតតែលើចំណែកខ្លះនៃខេត្តដែលបានជ្រើសរើសឡើង ក្នុងនេះមានភូមិធ្វើអង្កេតត្រូវបានជ្រើសរើសដោយចៃដន្យចេញពីបណ្តាឃុំ PET ។ ក្នុងភូមិគោលដៅ គ្រួសារមុខសញ្ញា ២៦គ្រួសារ ត្រូវបានជ្រើសរើសពីភូមិនិមួយៗ ដើម្បីអោយបានគ្រួសារមុខសញ្ញាសរុប ១,០៤០គ្រួសារ ។ គ្រួសារសមស្របនឹងលក្ខណៈវិនិច្ឆ័យរបស់ PET (គ្រួសារមានកូនអាយុក្រោម ៥ឆ្នាំយ៉ាងតិចម្នាក់ដែលមានម្តាយនៅជាមួយ) ត្រូវបានជ្រើសរើសដោយចៃដន្យតាមវិធីសាស្ត្រចន្លោះពេលនៃការជ្រើសរើស (interval selection) ។ ក្នុងពីរ-បីករណីដែលភូមិមានប្រជាជន តិចពេកមិនអាចមានគ្រប់ចំនួន ២៦គ្រួសារ ដែល (មានកុមារ និងម្តាយ) ស្របតាមលក្ខណៈវិនិច្ឆ័យគេជ្រើសយកភូមិទីបីមួយទៀតដោយចៃដន្យ ហើយជ្រើសបន្ថែមនូវគ្រួសារពីភូមិទីបីនោះ ដើម្បីបង្គ្រប់ចំនួនត្រូវបញ្ចូលទៅក្នុងអង្កេត[១៤] ។

## *លក្ខណៈប្រៀបធៀបគ្នាបាន និងចំណុចខ្វះខាតនៃអង្កេត*

អង្កេតទាំងបួនមានលក្ខណៈខុសប្លែកគ្នា ទាំងខាងតំបន់ភូមិសាស្ត្រ ក្របខ័ណ្ឌពេលវេលា និងក្រុមមុខសញ្ញា ។ ដោយសារអង្កេតទាំងនេះត្រូវបានគេកសាងឡើង និងអនុវត្តដាច់ដោយឡែកពីគ្នាដើម្បីបំរើគោលដៅខុសៗគ្នាទិន្នន័យមួយចំនួនដែលទាក់ទិននឹងរឿងជីវភាព យើងអាចប្រមូលបានពីអង្កេតខ្លះ តែមិនឃើញមាននៅក្នុងអង្កេតខ្លះទៀតទេ (តារាង២.៤) ។

ដោយសារអង្កេតរបស់ MRC និង NIS ជ្រើសយកដោយចៃដន្យនូវសំណាកគំរូពីក្នុងតំបន់ធ្វើអង្កេត អត្រាគ្រួសារមានស្ត្រីជាមេគ្រួមានកំរិតខ្ពស់គឺ ១៩% (អង្កេត MRC) និង ២៤% (អង្កេត NIS) ។ តួលេខនេះស៊ីគ្នា (ទោះបីវាទាបជាងបន្តិចក្តី) នឹងលទ្ធផលជំរឿនប្រជាជនឆ្នាំ១៩៩៨ ដែលមានអត្រា ២៥.៧% (NIS, 1999:4) ។ ប៉ុន្តែ អត្រានេះមានកំរិតទាបជាខ្លាំងនៅក្នុងអង្កេត Baseline (៦%) និងនៅក្នុងអង្កេត PET (៨%) ដោយការកំណត់យកគ្រួសារសំណាកគំរូដែលត្រូវមានកុមារអាយុក្រោម ៥ឆ្នាំយ៉ាងតិចម្នាក់ (ភាគច្រើនជាកុមារដែលមានឳពុកម្តាយរៀបការត្រឹមត្រូវ) ។ ដូច្នេះ ហើយគ្រួសារដែលមានស្ត្រីជាមេគ្រួក្នុងអង្កេតទាំងពីរខាងក្រោម ជាគ្រួសារដែលទើបតែមានស្ត្រីជាមេគ្រួសារក្នុងអំឡុងពេល៥-៦ឆ្នាំចុងក្រោយនេះប៉ុណ្ណោះ ។

ចំណុចខ្សោយនៃអង្កេតទាំងនេះ (តាមទស្សនៈនៃការសិក្សានេះ) គឺភាពខុសគ្នារវាងក្រុមសំណាកគំរូ ។ ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចក្នុងសហគមន៍នេសាទ គឺផ្តោតតែលើប្រជាជនដែលរស់នៅតាមបណ្តាឃុំធ្វើនេសាទ ។ ចំណែកឯអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចរបស់ NIS វិញ បានផ្តោតលើសំណាកគំរូទូលំទូលាយជាង ប៉ុន្តែគេត្រូវដកចេញពីក្របខ័ណ្ឌសំណាកគំរូនូវតំបន់ខ្លះដែលមានបញ្ហាចោទខាងសន្តិសុខ ។ ការបែងចែកជាស្រទាប់ត្រូវបានធ្វើឡើងដោយឈរលើការកំណត់ថាមានបីស្រទាប់ គឺ មានភ្នំពេញ ទីប្រជុំជនផ្សេងទៀត និងតំបន់ជនបទ ។ ការបែងចែកនេះត្រូវបានកំណត់ឡើងដោយការិយាល័យជំរឿនប្រជាជន ហើយនេះជាចំណុចខ្សោយគួរឱ្យកត់សំគាល់មួយ ។ អង្កេត Baseline ផ្តោតលើតែប្រជាជនដែលនៅក្នុងគំរោង CASD និងតំបន់មុខសញ្ញារបស់ WFP ។ នៅក្នុងអង្កេត PET ក្រុមប្រជាជននៅក្នុងឃុំ PET និងគ្រួសារនានាដែលត្រូវបានជ្រើសយកជាសំណាកគំរូ គឺសុទ្ធតែជាគ្រួសារមានកូនម្នាក់យ៉ាងតិច មានអាយុក្រោម ៥ឆ្នាំ ហើយមានម្តាយនៅជាមួយ ។

ថ្វីបើមិនមានភាពខុសគ្នាយ៉ាងនេះក៏ដោយ ជាទូទៅ អង្កេតទាំងបួនបានផ្តល់នូវពត៌មានដ៏មានតំលៃ ក្នុងនេះមានទិន្នន័យ

---

នៅក្នុងរយៈពេលក្រោយឆ្នាំ១៩៨៩ Helmers and Kenefick, 1999:12 ។

១៤ ដោយផ្អែកលើការបែងចែកតាមតំបន់ តាមភាពដូចគ្នានៃស្ថានភាពសង្គម និងប្រភពដើមនៃជនភៀសខ្លួនក្នុងស្រុក សំណាកគំរូត្រូវបានបែងចែកជាបួនតំបន់ និងពីរថ្នាក់ ហើយវិធីសាស្ត្រជ្រើសសំណាកគំរូចៃដន្យពីរថ្នាក់ (two-stage random sampling) ត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើសយកសំណាកគំរូ។ នៅថ្នាក់ទីមួយឃុំចំនួន៩ នៅក្នុងតំបន់ PET នីមួយៗ ត្រូវបានជ្រើសរើសដោយចៃដន្យ ។ នៅថ្នាក់ទីពីរ ក្នុងឃុំនីមួយៗភូមិពីរដែលស្របតាមលក្ខណៈវិនិច្ឆ័យរបស់ WFP ត្រូវបានជ្រើសយក ឯភូមិណាដែលមិនមែនជាភូមិ PET ត្រូវបានជំរុះចោល ។ ការជ្រើសរើសភូមិនេះទៀតសោត ត្រូវបានធ្វើឡើងដោយប្រើប្រាស់តារាងចៃដន្យ ។ ប៉ុន្តែ ភូមិឃុំទាំងឡាយណា ដែលមានគ្រោះថ្នាក់ដោយសារគ្រាប់មីនខ្លាំងពេកដូចជាមានគ្រាប់មីននៅតាមផ្លូវចូលទៅឃុំជាដើម ក៏ត្រូវបានដកចេញពីសំណាកគំរូផងដែរ ។

លំអិតស្តីពីប្រជាសាស្ត្រនៃគ្រួសារ កម្មសិទ្ធិដីធ្លី លទ្ធភាពប្រើប្រាស់ធនធានទ្រព្យរួម កម្មសិទ្ធិជាទ្រព្យជាប់លាប់ផ្សេងទៀតចំណូលចំណាយគ្រួសារ និងពតិមានជាច្រើនទៀត ។ ប៉ុន្តែគេគួរចាំថា អង្កេតទាំងបួនមិនគ្របដណ្តប់លើបញ្ហាដូចគ្នាទាំងអស់ទេ ។ មួយចំណែកទៀត វិធីរៀបចំតាក់តែងបញ្ជីសំណួរ និងវិធីសាកសួរសំណួរក៏ខុសពីគ្នាដែរ ។

**តារាង២.៤. សង្ខេបពតិមានដែលទទួលបានពីអង្កេត**

| ពតិមានអាចស្រង់បាន | អង្កេត MRC | អង្កេត SES | អង្កេត Baseline | អង្កេត PET |
|---|---|---|---|---|
| ១. ទំហំសំណាកគំរូ | 5,117 | 6,010 | 1,230 | 1,040 |
| ២. ចំនួនខេត្តក្នុងសំណាកគំរូ | 8 | 20 | 14 | 7 (4 zones) |
| ៣. % នៃគ្រួសារមានស្ត្រីជាមេគ្រួសារ | 19% | 24% 1/ | 6% | 8% |
| ៤. ប្រជាសាស្ត្រគ្រួសារ | | | | |
| • អាយុ, ភេទ, ករិតសិក្សា ... | √ | √ | √ | √ |
| • ការផ្លាស់ទីលំនៅ | √ | × | √ | √ |
| • ស្ថានភាពការងារ | √ | √ | √ | √ |
| ៥. ដីធ្លី | | | | |
| • លទ្ធកម្មដីធ្លី | × | × | × | √ |
| • ការកាន់កាប់ដីធ្លី | √ | √ | √ | √ |
| • កម្មសិទ្ធិដីធ្លី | × | √ | × | √ |
| • ការលក់ដូរដីធ្លី | × | × | √ | √ |
| ៦. ធនធានទ្រព្យរួម ១ជកប្រ | | | | |
| • លទ្ធភាពប្រើប្រាស់ CPR | √ | × | √ | √ |
| • ការប្រែប្រួលនៃ CPR | √ | × | √ | √ |
| ៧. ទ្រព្យសម្បត្តិ | | | | |
| • ប្រភេទផ្ទះ | √ | √ | √ | √ |
| • ទ្រព្យសម្បត្តិមានតំលៃ | √ | √ | √ | √ |
| • សត្វ, ដើមឈើ... | √ | √ | √ | √ |
| ៨. វិបត្តិ | | | | |
| • បំណុល | √ | √ | √ | √ |
| • ភាពទាល់ច្រក | √ | x | √ | √ |
| ៩. ប្រាក់ចំណូល | | | | |
| • កសិផល | √ | × | √ | √ |
| • ប្រភពប្រាក់ចំណូល | √ | √ | √ | √ |
| ១០. ចំណាយ | | | | |
| • ចំណាយលើម្ហូបអាហារ | × | √ | √ | √ |
| • ចំណាយក្រៅពីម្ហូបអាហារ | × | √ | √ | √ |
| ១១. សុខភាព | | | | |
| • អាហារូបត្ថម្ភ | × | × | √ | √ |
| • អាហារូបត្ថម្ភកុមារ និងមាតា | × | √ | √ | √ |

*ចំណាំ: √ = មាន, ក្នុងអង្កេតមានសំណួរនេះ × = គ្មាន, ក្នុងអង្កេតគ្មានសំណួរនេះទេ ១. ភាគរយនៃគ្រួសារមានស្ត្រីជាមេគ្រួសារទាំងនៅក្នុងតំបន់ជនបទ និងទីក្រុង, ទីក្រុង-២៧% និង ជនបទ-២៣% ។ ប្រភព: អង្កេត MRC ១៩៩៥-៩៦, អង្កេត SES, NIS 1997; អង្កេត Baseline, UNWFP 1998 និង អង្កេត PET, UNWFP 1998 ។*

## ២.៣ លទ្ធកម្មដីធ្លី

អាស្រ័យលើក្រឹត្យច្បាប់នានា និងការបែងចែកដីធ្លីឡើងវិញក្នុងទសវត្សរ៍១៩៨០ គេសន្មតយ៉ាងសមរម្យថា ប្រជាជនកម្ពុជាភាគច្រើនបានទទួលដីលំនៅដ្ឋាន និងដីកសិកម្ម ។ ជាងនេះទៅទៀត ដោយផ្អែកលើនិតិវិធីចែកដីធ្លីក្នុងទសវត្សរ៍១៩៨០ (សូមអានពត៌មានលំអិតនៅក្នុងកថាខ័ណ្ឌ ២.១) គេអាចស្មានថាប្រជាជនភាគច្រើនបានទទួលដីធ្លីដោយស្របច្បាប់ និងត្រូវបានទទួលស្គាល់ជាផ្លូវការថា ជាម្ចាស់ដោយដោយអាជ្ញាធរមូលដ្ឋាន ។

**ក្រាហ្វិក ២.២ លទ្ធកម្មដីធ្លីនៅក្នុងប្រទេសកម្ពុជា ដោយផ្អែកលើការអង្កេត PET ១៩៩៨**




*ប្រភព: អង្កេត PET (Question 601, Appendix A-4), UNWFP 1998* ។

ប៉ុន្តែលទ្ធផលនៃអង្កេត PET (ជាការអង្កេតតែមួយគត់ដែលមានសំណួរពីការទទួលដីធ្លី ហើយដែលផ្តោតតែទៅលើជនភៀសសឹក) បានបង្ហាញថា បណ្តាគ្រួសារ PET ជារឿយៗ បានទទួលដីធ្លីពីប្រភពផ្សេងទៀត: ៤៣% នៃគ្រួសារឆ្លើយសំភាសន៍បានបញ្ជាក់ថា បានទទួលដីពីបងប្អូន ឬមិត្តភក្តិ ក្រាហ្វិក ២.២ ។ តួលេខដ៏ខ្ពស់នេះ គេគិតថាវាកើតចេញពីអត្រាដ៏ខ្ពស់នៃការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនសំណាកគំរូ: បីភាគបួននៃគ្រួសារដែលត្រូវបានអង្កេតបានភៀសខ្លួន (ដោយសារការប្រយុទ្ធគ្នា) តាំងពីឆ្នាំ១៩៨៩ មក ។ ដូច្នេះហើយ ពួកគេងាយនឹងបាត់បង់ដីធ្លីនៅក្នុងភូមិដើមរបស់ពួកគេណាស់ ។ មួយចំណែកទៀត ពួកគេប្រហែលជាមិនអាចមានលទ្ធភាពទទួលបានដីធ្លីនៅក្នុងភូមិតាំងលំនៅថ្មីបានឡើយ (តារាង២.៥) ។ លទ្ធផលនៃអង្កេត PET ក៏បានបង្ហាញដែរថា ២៨% នៃប្រជាជនអ្នកឆ្លើយសំភាសន៍បានទទួលដីពីអាជ្ញាធរមូលដ្ឋាន ប៉ុន្តែមានតែ ៥% ប៉ុណ្ណោះដែលបានទទួលដីពីក្រុមសាមគ្គីក្នុងពេលបែងចែកដីនៅឆ្នាំ១៩៨៩ ។ នេះជាអត្រាមួយយ៉ាងទាបគួរឱ្យភ្ញាក់ផ្អើល ពីព្រោះការបែងចែកដីដោយអាជ្ញាធរមូលដ្ឋាន និងដោយក្រុមសាមគ្គី គឺជាច្រកចំបងជាងគេដែលប្រជាជនបានទទួលដីធ្លីនៅក្នុងប្រទេសកម្ពុជា នៅក្នុងរយៈពេលមុនឆ្នាំ១៩៨៩ ។ ហេតុផលមួយទៀតដែលបញ្ជាក់ថា ហេតុអ្វីបានជាគ្រួសារជាច្រើននៅក្នុងតំបន់ទាំងនេះទើបមានដីធ្លីពីត្រឹមឆ្នាំ១៩៨៩ មក គឺអាយុជាមធ្យមដ៏ក្មេង នៃមេគ្រួសារនានាដែលបានឆ្លើយសំភាសន៍ ហើយរឿងនេះត្រូវបានបញ្ជាក់កាន់តែច្បាស់ឡើង ដោយសារគ្រួសារជាច្រើនបានទទួលដីធ្លីពីបងប្អូន ។

**តារាង២.៥. ការផ្លាស់ប្តូរ និងការតាំងទីលំនៅរបស់គ្រួសារ**

| គ្រួសារ | ភាគរយ |
|---|---|
| បានផ្លាស់ប្តូរទីលំនៅដោយសារសង្គ្រាមតាំងពីឆ្នាំ១៩៨៩ | 76% |
| ធ្វើមាតុភូមិនិវត្តន៍ពីជំរំ តាមកម្មវិធីរបស់ UN | 8% |
| តាំងទីលំនៅនៅភូមិថ្មី (ដែលកើតក្រោយឆ្នាំ១៩៩២) | 11% |
| កំពុងភៀសខ្លួនចេញពីកន្លែងដែលធ្លាប់រស់នៅជាធម្មតា | 4% |
| ផ្លាស់ប្តូរទីលំនៅលើសពីពីរដងតាំងពីឆ្នាំ១៩៨៩ | 36% |
| តាំងទីលំនៅលើសពីពីរកន្លែងខុសគ្នាតាំងពីឆ្នាំ១៩៨៩ | 28% |

*ប្រភព: អង្កេតPET, UNWFP 1998 ។*

## ២.៤ ការកាន់កាប់ដីធ្លី

### *សិទ្ធិកាន់កាប់ដីធ្លី*

ក្នុងពីរ-បីខែដំបូង ក្រោយពេលធ្វើឯកជននីយកម្មដីធ្លីក្នុងឆ្នាំ១៩៨៩ ប្រជាជនជាច្រើននាក់ បានដាក់ពាក្យសុំកម្មសិទ្ធិលើដីធ្លីរបស់ខ្លួន ប៉ុន្តែមានប្រជាជនមួយភាគតូចប៉ុណ្ណោះដែលបានទទួលប័ណ្ណកម្មសិទ្ធិក្នុងមួយទសវត្សរ៍ក្រោយមក ។ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ[១៥] បានផ្តល់ពត៌មានថា ក្នុងចំណោមពាក្យសុំ ៤,៥លាន មានតែ ១៤% ប៉ុណ្ណោះដែលបានទទួលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ។ ប៉ុន្តែចំពោះអ្នកឯទៀតដែលបានដាក់ពាក្យសុំសិទ្ធិកាន់កាប់ដែរ រហូតមកទល់ពេលនេះ ប្រហែលគ្រាន់តែបានទទួលត្រឹមបង្កាន់ដៃទទួលពាក្យពីអាជ្ញាធរមូលដ្ឋានតែប៉ុណ្ណោះ (ចំពោះពតិមានលំអិតអំពីដំណើរការដាក់ពាក្យសុំ សូមអានឧបសម្ព័ន្ធ ខ) ។

អង្កេត NIS បង្ហាញថា ភាគច្រើននៃប្រជាជនឆ្លើយសំភាសន៍ គេមានប័ណ្ណប្រភេទណាមួយសំរាប់បញ្ជាក់សិទ្ធិលើដីធ្លី ។ ប្រហែល ៨០% នៃអ្នកឆ្លើយសំភាសន៍ទាំងនៅក្នុងតំបន់ទីក្រុង និងជនបទបានរាយការណ៍ថា ពួកគេមានកម្មសិទ្ធិ/កាន់កាប់លើដីលំនៅដ្ឋាន និងដីកសិកម្ម ដោយមានប័ណ្ណសំគាល់សិទ្ធិ (តារាង២.៦) ។ ប៉ុន្តែនៅក្នុងអង្កេតនេះ គេមិនបានបញ្ជាក់ច្បាស់លាស់ពីសិទ្ធិលើដីធ្លីទេ: អាចថាពួកអ្នកឆ្លើយសំភាសន៍ គេនិយាយពីបង្កាន់ដៃទទួលពាក្យដែលពួកគេបានទទួលនៅពេលដាក់ពាក្យសុំសិទ្ធិភោគៈ ។ ក្នុងបញ្ជីសំនួរក៏មានសួរដែរថា តើអ្នកឆ្លើយសំភាសន៍នៅមានបង្កាន់ដៃទទួលពាក្យដែរឬទេ? ដូច្នេះភាគរយដ៏ខ្ពស់នៃកម្មសិទ្ធិដោយមានប័ណ្ណសំគាល់ អាចកើតចេញពីលក្ខណៈមិនច្បាស់លាស់នៃសំនួរ (សំនួរ ២៤ ឧបសម្ព័ន្ធក-២ របស់ SES) ។ សំនួរបានអនុញ្ញាតឱ្យអ្នកដែលមានដីលំនៅដ្ឋាន និងដីកសិកម្ម មានចម្លើយតែបីបែបទេគឺ ១. មានកម្មសិទ្ធិដីធ្លីដោយមានប័ណ្ណសំគាល់ ២. កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬកាន់កាប់ដោយសេរី និង ៣. ជួលពីគេ ។ ដូច្នេះអ្នកឆ្លើយសំភាសន៍ដែលមានដីមុខតែរាយការណ៍ថា ខ្លួនមានកម្មសិទ្ធិដីដោយមានប័ណ្ណសំគាល់ បើគាត់មិនបានកាន់កាប់ដីដោយសេរី និង/ឬជួលដីទេនោះ ។ ដូច្នេះគេមិនអាចធ្វើការប៉ាន់ស្មាន ដោយទុកចិត្តនូវកំរិតភាគរយនៃប័ណ្ណកម្មសិទ្ធិដីធ្លី ដោយប្រើទិន្នន័យនៃអង្កេត SES បានទេ ។

សំនួរនៅក្នុងអង្កេត PET អំពីឯកសារបញ្ជាក់កម្មសិទ្ធិដីធ្លី[១៦] ដែលខិតខំស្រាវជ្រាវអំពីប្រភេទឯកសារបញ្ជាក់កម្មសិទ្ធិដែលប្រជាជនមាន បានបង្ហាញនូវរូបភាពមួយផ្សេង ។ មានគ្រួសារ PET តែមួយភាគតូចទេដែលមានបង្កាន់ដៃទទួលពាក្យដើម្បីបញ្ជាក់ពីសិទ្ធិកាន់កាប់របស់ខ្លួន ហើយមានអ្នកឆ្លើយសំភាសន៍តែ ២% ប៉ុណ្ណោះ ដែលបានទទួលប័ណ្ណផ្លូវការសំរាប់ដីលំ

---

១៥ បច្ចុប្បន្នជាអគ្គនាយករងនៃ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ។

១៦ សំនួរ៦០៣-៦០៤ រៀបរៀងដោយលោក Shaun Williams (Oxfam GB) បានផ្តល់ជំរើសជាច្រើន ដើម្បីឱ្យអ្នកឆ្លើយសំភាសន៍អាចផ្តល់ចម្លើយបានសមស្រប អំពីឯកសារកម្មសិទ្ធិដីធ្លីដែលគេមាន ។ ប៉ុន្តែអ្នកចុះធ្វើសំភាសន៍មិនបានសួរទេថាតើ អ្នកឆ្លើយសំភាសន៍នៅមានឯកសារទាំងនោះនៅឡើយ ឬយ៉ាងណា (បង្កាន់ដៃ, ពាក្យសុំ, កំណត់ហេតុអង្កេតដី) ។

នៅដ្ឋានរបស់ខ្លួន ។ អ្នកឆ្លើយសំភាសន៍ ១% មានប័ណ្ណបញ្ជាក់សំរាប់ដីកសិកម្ម (តារាង២.៧) ។ ដូច្នេះ គ្រួសារជាង ៧០% គ្មានឯកសារអ្វីសំរាប់បញ្ជាក់សិទ្ធិកាន់កាប់លើដីលំនៅដ្ឋាន ឬដីកសិកម្មរបស់ខ្លួនទេ ។

**តារាង២.៦. ភាគរយនៃគ្រួសារនៅទីក្រុង និងជនបទដែលរាយការណ៍ថា មានដី និងមានសិទ្ធិលើដី**

| លក្ខណៈនៃសិទ្ធិលើដី | ដីលំនៅដ្ឋាន | | ដីកសិកម្ម | |
|---|---|---|---|---|
| | ទីក្រុង | ជនបទ | ទីក្រុង | ជនបទ |
| មានប័ណ្ណកម្មសិទ្ធិ | 77% | 82% | 79% | 87% |
| កម្មសិទ្ធិមិនដាច់ស្រេច ឬកាន់កាប់ដោយសេរី | 22% | 17% | 19% | 12% |
| ជួលពីគេ | 1% | 1% | 2% | 1% |
| សរុប | 100% | 100% | 100% | 100% |

*ប្រភព: អង្កេត* SES (Questions 24 .1-24 .3), NIS 1997 ។

អង្កេត PET បានបង្ហាញថា អត្រាគ្រួសារមានស្ត្រីជាមេគ្រួសារដែលបានដាក់ពាក្យសុំកាន់កាប់ដី មានកំរិតខ្ពស់ជាងអត្រាសំរាប់គ្រួសារមានបុរសជាមេគ្រួសារ ។ តារាង២.៧ បានបង្ហាញថា អត្រាគ្រួសារមានស្ត្រីជាមេគ្រួសារដែលមានក្រដាសស្នាម (បង្កាន់ដៃទទួលពាក្យ ពាក្យសុំកាន់កាប់ដី ឬកំណត់ហេតុអង្កេតដី) មានកំរិតខ្ពស់ជាងអត្រាសំរាប់គ្រួសារមានបុរសជាមេគ្រួសារបន្តិច ។ ប៉ុន្តែគ្មានគ្រួសារមានស្ត្រីជាមេគ្រួសារណាមួយដែលបានទទួលនូវប័ណ្ណបញ្ជាក់សិទ្ធិកាន់កាប់ដីលំនៅដ្ឋាន ឬដីកសិកម្មរបស់ខ្លួនទេ ។ លក្ខណៈខុសគ្នានេះ អាចបណ្តាលមកពីចំនួនដ៏ តូចនៃគ្រួសារមានស្ត្រីជាមេគ្រួសារ (មានតែ ៧២គ្រួសារ) នៅក្នុងប្រជាជនសំណាកគំរូនៃអង្កេត PET ។ រឿងនេះ ហើយដែលធ្វើឱ្យលទ្ធផលខាងស្ថិតិពុំមានតួលេខអាចកត់សំគាល់បាន ។

**តារាង២.៧. ភាគរយនៃគ្រួសារដែលរាយការណ៍ថា មានប័ណ្ណសំគាល់សិទ្ធិលើដីធ្លី អាស្រ័យដោយការអង្កេត** PET

| លក្ខណៈនៃសិទ្ធិ | ដីលំនៅដ្ឋាន | | | ដីកសិកម្ម | | |
|---|---|---|---|---|---|---|
| | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] |
| | n=934 | n=72 | n=1006 | n=902 | n=69 | n=971 |
| គ្មានលិខិតស្នាម | 74% | 60% | 73% | 75% | 62% | 74% |
| មានបង្កាន់ដៃទទួលពាក្យ | 14% | 18% | 15% | 13% | 16% | 13% |
| មានពាក្យសុំកាន់កាប់ដី | 2% | 4% | 2% | 2% | 6% | 2% |
| មានកំណត់ហេតុអង្កេតដី | 1% | 3% | 1% | 1% | 1% | 1% |
| មានប័ណ្ណកម្មសិទ្ធិ | 2% | 0% | 2% | 1% | 0% | 1% |
| គ្មានដី | 7% | 15% | 7% | 8% | 15% | 9% |
| សរុប | 100% | 100% | 100% | 100% | 100% | 100% |

*កំណត់សំគាល់:* [១] *មធ្យមភាគសមតា ។ ប្រភព: អង្កេត* PET (Questions 603-604, Appendix A-4), UNWFP *១៩៩៨* ។

អង្កេត PET បានបង្ហាញដែរថា ចំនួនគ្រួសារមានស្ត្រីជាមេគ្រួសារដែលគ្មានដីលំនៅដ្ឋាន ឬដីកសិកម្ម មានកំរិតខ្ពស់ជាងចំនួនគ្រួសារមានបុរសជាមេគ្រួសារ ដល់ទៅពីរដង ។ សរុបមក ៩៨% នៃគ្រួសារមាន បុរសជាមេគ្រួសារ និងគ្រួសារ មានស្ត្រីជាមេគ្រួសារទាំងអស់ ពុំមានឯកសារតាមផ្លូវច្បាប់ណាមួយសំរាប់បញ្ជាក់ពីដីលំនៅដ្ឋាន ឬដីកសិកម្មរបស់ខ្លួនទេ ។

### *កម្មសិទ្ធិដីធ្លី*

បញ្ហាជាប់ទាក់ទិននឹងកម្មសិទ្ធិដីធ្លី មានសារៈសំខាន់ណាស់ចំពោះប្រជាជនកម្ពុជាជាង ៨០% ដែលរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតនៅតាមតំបន់ជនបទ ។ ភាគច្រើននៃប្រជាជនភាគនៅជនបទ តែងតែខិតខំធ្វើយ៉ាងណាឱ្យមានដីមួយកន្លែងសំរាប់ធ្វើស្រូវហូបខ្លួនឯង និងបន្តមរតក ។

ជាទូទៅ ដីត្រូវបានធ្វើចំណាត់ថ្នាក់ខុសៗគ្នាទៅតាមការប្រើប្រាស់របស់វា ។ ឧទាហរណ៍ ការអង្កេត MRC បានបែងចែក

ដីនៅក្នុងសហគមន៍ដែលពឹងផ្អែកលើនេសាទ ជាដីលំនៅដ្ឋាន ដីកសិកម្ម ដីចំការ ដំណាំហូបផ្លែ ស្រះត្រី និងដីផ្សេងទៀត ។ អង្កេតបានបង្ហាញថា ប្រជាជនសំណាកគំរូភាគច្រើនមានដីលំនៅដ្ឋាន ជិតដល់ ១០០% ទោះបីពួកគេរស់នៅក្នុងសហគមន៍នេសាទក៏ដោយ ។ ប៉ុន្តែមានអ្នកឆ្លើយសំភាសន៍ប្រមាណ ៧៥% ប៉ុណ្ណោះដែលមានដីកសិកម្ម (ភាគច្រើនដីស្រែ) និងមានប្រជាជនតិចទេដែលមានដីផ្សេងទៀតដូចជា ដីចំការ ដំណាំហូបផ្លែ ដីស្រះត្រីនៅក្នុង ឬក្រៅដីលំនៅដ្ឋានជាដើម ។ អត្រាគ្រួសារមានស្ត្រីជាមេគ្រួដែលមានកាន់កាប់ដីផ្សេងៗ មានកំរិតទាបជាងអត្រាសំរាប់គ្រួសារមានបុរសជាមេគ្រួសារតែបន្តិចបន្តួចទេ (តារាង២.៨) ។

**តារាង២.៨. ភាគរយនៃគ្រួសារដែលរាយការណ៍ថាកាន់កាប់ដីធ្លី**

| ប្រភេទដី | បុរសមេគ្រួសារ ន=៣៩៩៩ | ស្ត្រីមេគ្រួសារ ន=៩៥៣ | សរុប[១] ន=៤៩៥២ |
|---|---|---|---|
| ដីលំនៅដ្ឋាន | 99 .1% | 99 .2% | 99 .1% |
| ដីកសិកម្ម | 76 .9% | 70 .2% | 75 .6% |
| ដីចំការដំណាំហូបផ្លែ | 15 .4% | 13 .2% | 15 .0% |
| ដីផ្សេងទៀត | 0 .5% | 0 .3% | 0 .5% |
| ស្រះត្រីក្នុងដីលំនៅដ្ឋាន | 3 .6% | 2 .6% | 3 .4% |
| ស្រះត្រីក្រៅដីលំនៅដ្ឋាន | 0 .5% | 0 .1% | 0 .4% |

*កំណត់សំគាល់:[១] មធ្យមភាគសមតា ។ ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ, MRC ១៩៩៥-៩៦ ។*

ចំណែកឯអង្កេត SES វិញ បានបែងចែកដីជាដីលំនៅដ្ឋាន និងដីកសិកម្មតែប៉ុណ្ណោះ ហើយបានបងាញថា ប្រជាជនជាង ៩៥% បានរាយការណ៍ថា "មានកម្មសិទ្ធិ" ដីលំនៅដ្ឋានទាំងនៅក្នុងតំបន់ទីក្រុង និងជនបទ។ មួយចំណែកទៀត ប្រជាជននៅជនបទជាង ៨០% បានរាយការណ៍ថា មានដីកសិកម្ម ។ គួរកត់សំគាល់ដែរថា ២៧%នៃប្រជាជនតំបន់ទីក្រុង បានកាន់កាប់ ២៥% នៃដីកសិកម្មសរុប ។ នៅក្នុងអង្កេតនេះ គេកំណត់និយមន័យនៃប្រជាជនតំបន់ទីក្រុងមិនបានច្បាស់លាស់ទេ ពីព្រោះប្រជាជននៅតាមជាយក្រុងនៃទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងបណ្តាទីរួមខេត្តផ្សេងទៀត ក៏អាចត្រូវបានចាត់ថ្នាក់ជាប្រជាជនជនបទផងដែរ ។ ប្រជាជនទាំងនេះមួយចំនួនគេរស់នៅក្នុងតំបន់ជនបទនៅឡើយទេ (ទោះបីគេ នៅជិតទីក្រុងក៏ដោយ) ហើយពួកគេធ្វើស្រែចំការ និងពឹងផ្អែកជាសំខាន់លើរបរកសិកម្ម ។ ដូចមុនដែរចំពោះ គ្រួសារមានស្ត្រីជាមេគ្រួសារ គេបានពិនិត្យឃើញថា អត្រាកាន់កាប់ដីលំនៅដ្ឋាន និងដីកសិកម្ម មានកំរិតទាបជាង គ្រួសារមានបុរសជាមេគ្រួសារ (តារាង២.៩) ។ ចំពោះគ្រួសារមានស្ត្រីជាមេគ្រួសារ អត្រាទាបជាងគួរឱ្យកត់សំគាល់នៃការកាន់កាប់ដីកសិកម្មនៅក្នុងតំបន់ជនបទ អាចបណ្តាលមកពីគ្រួសារទាំងនេះ មានកំលាំងពលកម្មមិនគ្រប់គ្រាន់សំរាប់រៀបចំដី ឬរានយកដីថែមទៀត ។

**តារាង២.៩. ភាគរយនៃគ្រួសារនៅតំបន់ទីក្រុង និងជនបទដែលរាយការណ៍ថា មានដីលំនៅដ្ឋាន និងដីកសិកម្ម**

| ប្រភេទដី | តំបន់ទីក្រុង | | | តំបន់ជនបទ | | |
|---|---|---|---|---|---|---|
| | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] | បុរសមេគ្រួ. | ស្ត្រីមេគ្រួសារ | សរុប[១] |
| ដីលំនៅដ្ឋាន | 95 .7% | 94 .9% | 95 .4% | 97 .4% | 97 .3% | 97 .4% |
| ដីកសិកម្ម | 27 .6% | 26 .5% | 27 .3% | 87 .0% | 83 .7% | 86 .2% |

*កំណត់សំគាល់:[១] មធ្យមភាគសមតា ។ ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច, NIS ១៩៩៧ ។*

អង្កេត Baseline និង PET បានបែងចែកដីកសិកម្ម ជាដីស្រែវស្សា ដីស្រែប្រាំង និងដីចំការ។ ភាគច្រើននៃគ្រួសារក្នុងតំបន់មុខសញ្ញារបស់ WFP មានកាន់កាប់ដីលំនៅដ្ឋានដីស្រែ ឬដីចំការ (ដីមានដំណាំផ្សំគ្នាច្រើនមុខ គឺមានដើមឈើហូបផ្លែ

បន្លែ និងដំណាំក្រៅពីស្រូវផ្សេងទៀត)[១៧] ។ ដោយសារស្រូវវស្សាជាដំណាំសំខាន់ជាងគេ បើគិតតាមទំហំនៃផលិតកម្មគ្រួសារ សំណាកគំរូភាគច្រើនបានរាយការណ៍ថា មានដីស្រែវស្សា ។ នៅក្នុងបណ្តាឃុំធ្វើអង្កេត Baseline និង អង្កេត PET គេមិនសូវឃើញមានដីស្រែប្រាំងទេ ។ ដូចគ្នានឹងលទ្ធផលនៃអង្កេត SES ដែរ អត្រានៃគ្រួសារមានស្ត្រីជាមេគ្រួសារ ដែលមានកាន់កាប់ដីមានកំរិតទាបជាងអត្រាសំរាប់គ្រួសារមានបុរសជាមេគ្រួសារ (តារាង២.១០) ។

**តារាង២.១០. ភាគរយនៃគ្រួសារដែលរាយការណ៍ថា មាន ដីស្រែ និងដីចំការ**

| ប្រភេទដី | អង្កេត Baseline | | | អង្កេត PET | | |
|---|---|---|---|---|---|---|
| | បុរសមេគ្រួ. | ស្ត្រីមេគ្រួសារ | សរុប[១] | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] |
| ដីគ្រប់ប្រភេទ | .. | .. | .. | 93% | 83% | 92% |
| ស្រែវស្សា | 82% | 86% | 82% | 74% | 62% | 73% |
| ស្រែប្រាំង | 8% | 8% | 8% | 2% | 4% | 2% |
| ចំការ | 24% | 19% | 24% | 42% | 31% | 41% |
| ច្បារដំណាំក្បែរផ្ទះ | 32% | 32% | 32% | 61% | 62% | 61% |
| ដីលំនៅដ្ឋាន | .. | .. | .. | 89% | 78% | 88% |
| ដីផ្សេងៗទៀត | .. | .. | .. | 4% | 3% | 4% |

*កំណត់សំគាល់:*[១] *មធ្យមភាគសមតា ។ ប្រភព: អង្កេតBaseline និង អង្កេតPET, UNWFP ១៩៩៨ ។*

## ២.៥ ការបែងចែកដីធ្លី និងភាពគ្មានដីធ្លី

សំពាធ (នៃតំរូវការ) ដីធ្លី និងការប្រមូលផ្តុំដីធ្លី អាចក្លាយជាបញ្ហាប្រឈមមួយដ៏ស្រួចស្រាវបំផុតនៃគោលនយោបាយខាងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។ គេមានជំនឿថា បច្ចុប្បន្ននេះនៅកម្ពុជា ចំនួនប្រជាជនដែលគ្មានដីសង់លំនៅដ្ឋាន ឬដីកសិកម្ម បានកើនឡើងនៅក្នុងតំបន់ទីក្រុង និងតំបន់ជនបទជាច្រើន ។ ភាពគ្មានដីធ្លីនេះ បានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាជនជាច្រើន ពីព្រោះពួកគេគ្មានដីធ្លីសំរាប់រស់នៅ និង/ឬគ្មានដីគ្រប់គ្រាន់ដើម្បីផលិតស្បៀងដោះស្រាយតំរូវការប្រចាំថ្ងៃរបស់ខ្លួន ។

អត្រាប្រជាជនដែលគ្មានដីសង់លំនៅដ្ឋាន មានការប្រែប្រួលយ៉ាងខ្លាំងពីអង្កេតមួយទៅអង្កេតមួយ ។ អង្កេត (MRC) បង្ហាញអោយឃើញថា នៅក្នុងបណ្តាសហគមន៍ពឹងផ្អែកលើការនេសាទ មានប្រជាជនប្រមាណ 0,៩% ប៉ុណ្ណោះដែលពុំមានដីសំរាប់សង់លំនៅដ្ឋាន ។ ចំណែកឯអង្កេត NIS រាយការណ៍ថា ២,៦% នៃប្រជាជនក្នុងតំបន់ជនបទ និង ៤,៦% នៃប្រជាជននៅតាមតំបន់ទីក្រុង ពុំមានដីលំនៅដ្ឋានទេ ។ អង្កេត PET ដែលផ្តោតលើជនភៀសសឹក (IDPs) បានបង្ហាញថា ក្នុងឆ្នាំ១៩៩៨ ប្រហែល ១២% នៃប្រជាជនដែលគេបានធ្វើអង្កេត ពុំមានដីលំនៅដ្ឋានទេ (ក្រាហ្វិក ២.៣) ។ ក្នុងតួលេខនេះ គេគិតបញ្ចូលតែប្រជាជនដែលគ្មានដីលំនៅដ្ឋាន ឬដែលមិនមែនជាម្ចាស់ដីដែលខ្លួនបានសង់ផ្ទះនៅពីលើ ប៉ុន្តែដែលកំពុងតែរស់នៅៗក្នុងភូមិឃុំធ្វើអង្កេត ។ ដូច្នេះតួលេខនឹងត្រូវធំជាងនេះយ៉ាងច្រើន បើសិនគេគិតបញ្ចូលទាំងប្រជាជនដែលពុំមានដីលំនៅដ្ឋាន ហើយបានចាកចេញទៅរស់នៅក្នុងតំបន់ទីក្រុងដើម្បីរកចំណូលចិញ្ចឹមជីវិតតាមមធ្យោបាយផ្សេងទៀត ។ អត្រាគ្មានដីលំនៅដ្ឋាននៃគ្រួសារមានស្ត្រី ជាមេគ្រួសារ មានកំរិតខ្ពស់ជាងអត្រាសំរាប់គ្រួសារមានបុរសជាមេគ្រួសារ ។

ចំនួនដីកសិកម្មសរុប បានកើនឡើងប្រហែល ១៤% ពីឆ្នាំ១៩៩៣ ដល់១៩៩៨ ។ ប៉ុន្តែកសិករជាច្រើនបានត្អូញត្អែរថា ខ្លួនពុំមានដីគ្រប់គ្រាន់ដើម្បីធ្វើផលិតកម្មកសិកម្មឧបត្ថម្ភខ្លួនឯងឱ្យបានម្ចាស់ការទេ ។ កង្វះខាតនេះគឺជាឥទ្ធិពលគួបផ្សំគ្នានៃកំនើន

១៧ Helmers and Keneflick (1999:26)

ប្រជាជន និងការប្រមូលផ្តុំដីធ្លីដែលមិនបានគ្រប់គ្រងឱ្យបានសមស្រប ។

នៅប្រទេសកម្ពុជា ដីធ្លីជាមធ្យមក្នុងមួយគ្រួសារ មានទំហំតូចគួរសម ។ អង្កេតទាំង៤ បានរកឃើញថា ទំហំដីកសិកម្មជាមធ្យមរបស់ប្រជាជននៅជនបទ មានប្រហែល ១,0 ហិកតាក្នុងមួយគ្រួសារ (គឺប្រហែលគ្នានឹងការ ប៉ាន់ស្មានកំរិតជាតិ ១,៣ ហិកតាក្នុងមួយគ្រួសារ) ។ ប៉ុន្តែពីអង្កេតមួយទៅអង្កេតមួយ ទំហំជាមធ្យមនៃដីកសិកម្មក្នុងមួយគ្រួសារ មានការខុសគ្នាយ៉ាងច្រើន គឺប្រែប្រួលពី 0,៧៥ ហិកតា ដល់ ១,៣២ ហិកតា ។ ដីកសិកម្មកាន់កាប់ ជាមធ្យម មានទំហំតូចបំផុតគឺប្រហែល 0,៧៥ ហិកតា/គ្រួសារ នៅតាមបណ្តាសហគមន៍នេសាទនៃអង្កេត MRC និងមានទំហំប្រហែល ១ហិកតា/គ្រួសារនៅក្នុងអង្កេតបីផ្សេងទៀត (ក្រាហ្វិក ២.៤) ។ គ្មានអ្វីចំឡែកទេ ទំហំដ៏តូចនៃដីកសិកម្មកាន់កាប់ដែលអង្កេត MRC បានរកឃើញ គឺប្រហែលមកពីនៅក្នុងតំបន់ធ្វើអង្កេតនេះ ប្រជាជនមានមធ្យោបាយផ្សេងទៀតដើម្បីរកចំណូលដូចជាការនេសាទ ឬការប្រមូលផលពីព្រៃឈើជាដើម ។

**ក្រាហ្វិក ២.៣. ភាគរយនៃគ្រួសារដែលគ្មានដីលំនៅដ្ឋាន**




*ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ MRC 1995-96, អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច NIS 1997, និងអង្កេត PET, UNWFP 1998 ។*

មួយចំណែកទៀត រវាងទំហំដីកសិកម្មជាមធ្យមដែលកាន់កាប់ដោយគ្រួសារមានស្ត្រីជាមេគ្រួសារ និង ដោយគ្រួសារមានបុរសជាមេគ្រួសារ គំលាតមានទំហំធំគួរកត់សំគាល់ដែរនៅក្នុងអង្កេត MRC និងអង្កេត NIS ។ ទំហំដ៏តូចនៃដីកសិកម្មកាន់កាប់ដោយគ្រួសារ មានស្ត្រីជាមេគ្រួសារ ប្រហែលបណ្តាលមកពីគ្រួសារទាំងនេះខ្វះខាតពលកម្មមនុស្សពេញវ័យដើម្បីពង្រីកដីកសិកម្មថែមទៀត ឬដើម្បីធ្វើការងារដាំដុះឱ្យបានផលចំណេញ ដូច្នេះហើយក៏មានសំពាធដែលជំរុញឱ្យពួកគេលក់ដីធ្លីច្រើនជាង ។ អង្កេត MRC និង NIS បានរាយការណ៍ថា គ្រួសារមានស្ត្រីជាមេគ្រួសារ មានដីកសិកម្មជាមធ្យមប្រហែលជាង 0,៥ហិកតាបន្តិចក្នុងមួយគ្រួសារ គឺតូចជាងមធ្យមភាគទូទៅនៅក្នុងអង្កេតនានាយ៉ាងច្រើន (ក្រាហ្វិក ២.៤) ។

អង្កេតនានាបានបង្ហាញថា ភាពគ្មានដីធ្លី (សំដៅដល់ប្រជាជនដែលគ្មានដីកសិកម្ម ប៉ុន្តែអាចមានដីផ្សេងទៀត ដូចជា ដីលំនៅដ្ឋាន ឬច្បារដំណាំ) ប្រែប្រួលពី ១១% ដល់ ៣០% ទៅតាមទីតាំងភូមិសាស្ត្រនៃតំបន់ធ្វើអង្កេត និងភាពខុសគ្នារវាងគ្រួសារមានស្ត្រីជាមេគ្រួសារ នឹងគ្រួសារមានបុរសជាមេគ្រួសារ នៅក្នុងចំណោមប្រជាជនដែលគេធ្វើអង្កេត ។ ទាំងការអង្កេត NIS និងអង្កេត Baseline បានបង្ហាញថា ជាង ១០% នៃគ្រួសារឆ្លើយសំភាសន៍គ្មានដីទេ ។ ការអង្កេត NIS មានលក្ខណៈគ្របដណ្តប់សព្វជ្រុងជ្រោយជាងអង្កេត Baseline ពីព្រោះអង្កេត Baseline ផ្តោតតែលើប្រជាជនជាក្រុមមុខសញ្ញានៃ CASD និង WFP ។ ទោះបីអង្កេតទាំងពីរ បានសិក្សាពីក្រុមប្រជាជនខុសគ្នានៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏គេឃើញថា អត្រាប្រជាជនគ្មានដីមានទំហំប្រហាក់ប្រហែលគ្នា ដូច្នេះគេអាចសន្និដ្ឋានថា នៅក្នុងតំបន់ជនបទ អត្រាប្រជាជនគ្មានដីធ្លី មានប្រហែល ១០% ។

**ក្រាហ្វិក ៦.២ ភាគរយប្រជាជនគ្មានដីលំនៅដ្ឋាន**




*កំណត់សំគាល់:* [១] *ដីកសិកម្មត្រូវបានគណនាឡើងនៅក្នុងអង្កេត MRC ចំណែកឯនៅក្នុងអង្កេត Baseline និងអង្កេត PET ដីកសិកម្ម គឺជាផលបូកនៃដីស្រែវស្សា ដីស្រែប្រាំង និងដីចំការ ។ ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ MRC 1995-96, អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច NIS 1997, អង្កេត Baseline UNWFP 1998 និងអង្កេត PET UNWFP 1998 ។*

ចំពោះអង្កេត MRC និងអង្កេត PET ដែលផ្តោតទៅលើក្រុមប្រជាជនដោយឡែក បានបង្ហាញថា អត្រាប្រជាជនគ្មានដីមានកំរិតខ្ពស់ជាងច្រើន គឺ ២៤% ក្នុងអង្កេត MRC និង ១៧% ក្នុងអង្កេត PET ។ អត្រាខ្ពស់ទាំងនេះ អាចបណ្តាលមកពីអង្កេត MRC បានផ្តោតតែលើបណ្តាសហគមន៍ពឹងផ្អែកលើការនេសាទដែលមានប្រភពចំណូលច្រើនមុខ (នេសាទ ព្រៃឈើ ការដាំដុះ) រីឯកសារអង្កេត PET ដែលបានផ្តោតតែលើប្រជាជនដែលបានភៀសខ្លួនចុះឡើង នៅក្នុងប្រទេសតាំងពីឆ្នាំ១៩៨៩ មកដោយសារ ការប្រយុទ្ធគ្នា និងប្រជាជនដែលវិលត្រឡប់មកពីជំរំនានានៅតាមទល់ដែនថៃវិញ ។ ទោះបីយ៉ាងណាក៏ដោយក៏ការអង្កេត ទាំងនេះហាក់បានបង្ហាញថា អត្រាប្រជាជនគ្មានដីធ្លីនៅប្រទេសកម្ពុជាមានជាង ១០% ។

**ក្រាហ្វិក ៦.៣ ភាគរយប្រជាជនគ្មានដីកសិកម្ម**




*ប្រភព: អង្កេតសង្គមកិច្ច-សេដ្ឋកិច្ចគ្រួសារ MRC 1995-96, អង្កេតសង្គមកិច្ច-សេដ្ឋកិច្ច NIS 1997, អង្កេត Baseline UNWFP 1998 និងអង្កេត PET UNWFP 1998 ។*

អត្រាគ្មានដីធ្លីនៃគ្រួសារមានស្ត្រីជាមេគ្រួសារ ជាទូទៅច្រើនមានកំរិតខ្ពស់ជាងអត្រាសំរាប់គ្រួសារមានបុរសជាមេគ្រួ (ក្រាហ្វិក២.៦) ។ រឿងនេះអាចបណ្តាលមកពី គ្រួសារមានស្ត្រីជាមេគ្រួសារច្រើនខ្វះខាតកំលាំងពលកម្មសំរាប់ធ្វើការងារស្រែចំការធ្ងន់ៗដូចជាការរៀបចំ (ភ្ជួររាស់) ដី ឬខ្វះលទ្ធភាពបង់ថ្លៃឈ្នួលដ៏ខ្ពស់នៃការភ្ជួររាស់ដី ។ ដូច្នេះហើយពួកនេះច្រើនធ្វើសកម្មភាពផ្សេងទៀតដើម្បីចិញ្ចឹមជីវិត ហើយលក់ដីរបស់ខ្លួនឱ្យគេ ។

ដោយលទ្ធភាពមានដីកសិកម្មប្រើប្រាស់មានសារៈសំខាន់បំផុតសំរាប់ជីវភាពប្រជាជននៅជនបទ ក្នុងពេលថ្មីៗនេះ មានការជជែកគ្នាមួយអំពីកំរិតនៃភាពគ្មានដីធ្លីនៅក្នុងតំបន់ជនបទ ។ ការសិក្សាក្នុងពេលថ្មីៗដោយអង្គការ WFP និង FAO បានបង្ហាញថា អត្រាប្រជាជនគ្មានដីធ្លីក្នុងតំបន់ជនបទកម្ពុជា មានទំហំប្រហែលជាង ២០% (ក្រសួងកសិកម្ម, ឆ្នាំ១៩៩៩) ។

ទំហំដីកសិកម្មជាមធ្យមក្នុងមួយគ្រួសារ និងអត្រាប្រជាជនគ្មានដីធ្លី មានការប្រែប្រួលយ៉ាងច្រើនពីខេត្តមួយទៅខេត្តមួយ (តារាង២.១១)[១៨] ដោយសារតែអង្កេតទាំងបួនផ្តោតលើក្រុមមុខសញ្ញាខុសៗគ្នា។ តារាង២.១ បង្ហាញថា ខេត្តធំៗដូចជាបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កណ្តាល ច្រើនតែមានអត្រាប្រជាជនគ្មានដីធ្លីខ្ពស់ជាងខេត្តឯទៀត ។ ប៉ុន្តែអង្កេតទាំងនេះមិនបានបង្ហាញនូវចំណងទាក់ទងអ្វីច្រើនទេ រវាងចំនួនដីធ្លីដែលមាននៅក្នុងខេត្ត និងភាពគ្មានដីធ្លី ។ ឧទាហរណ៍ ទោះបីជាខេត្តបាត់ដំបងមានដង់ស៊ីតេប្រជាជនទាបក៏ដោយ ក៏អត្រាប្រជាជនគ្មានដីមានកំរិតខ្ពស់ (ជាង ២៥%) ។ រឿងនេះប្រហែលមកពីតំរូវការដីធ្លីនៅតាមខេត្តទាំងនោះ មានកំរិតខ្ពស់ជាងបណ្តាខេត្តដាច់ស្រយ៉ាល ហើយនៅក្នុងខេត្តទាំងនោះក៏ប្រហែលសំបូណ៌លទ្ធភាពផ្សេងទៀតដើម្បីរកចំណូលជាងនៅខេត្តដាច់ស្រយាលដែរ ។ តាមអង្កេត NIS អត្រាប្រជាជនគ្មានដីនៅខេត្តកោះកុងមានកំរិតខ្ពស់គួរឱ្យភ្ញាក់ផ្អើល (៥០%) ។ រឿងនេះប្រហែលជាមកពីនៅខេត្តកោះកុង ប្រជាជនភាគច្រើនជាអ្នកនេសាទ ហើយពួកគេមានច្រកផ្សេងទៀតជាច្រើនដើម្បីរកចំនូល ដូចជាការជួញដូរជាមួយឈ្មួញថៃ និងសកម្មភាពកាប់ឈើជាដើម ។

បញ្ហាអត្រាដ៏ខ្ពស់នៃប្រជាជនគ្មានដីធ្លី និងទំហំជាមធ្យមដ៏តូចនៃដីកសិកម្មកាន់កាប់ដោយគ្រួសារនីមួយៗ វាចោទឡើងរឹតតែធ្ងន់ធ្ងរថែមទៀត នៅពេលដែលដីធ្លីមានការបែងចែកមិនបានស្មើភាពល្អ ។ ពួកអ្នកមានមួយក្រុមតូចអ្នកកាន់កាប់ដីកសិកម្មមួយចំណែកធំ ចំណែកឯប្រជាជនក្រីក្រដែលជាក្រុមភាគច្រើន មានដីធ្លីតែតិចតួចប៉ុណ្ណោះសំរាប់រស់នៅ និងប្រកបរបរចិញ្ចឹមជីវិត ។ ជាធម្មតា ពួកកសិករមានចំណុចចាប់ផ្តើមខាងធនធានសេដ្ឋកិច្ចមិនដូចគ្នាទេ ។

ទីមួយ កសិករមួយចំនួនអាចបានទទួលមរតកច្រើន។ ទោះបីនៅក្នុងជំនាន់ខ្មែរក្រហម ប្រជាជនមិនអាចមានអ្វីជាឯកជនក៏ដោយ ក៏អ្នកខ្លះគេអាចរក្សាទុករបស់របរមានតំលៃមួយចំនួនដែលក្រោយមក គេអាចយកមកប្រើប្រាស់បាន ។ ក្រោយឆ្នាំ១៩៧៩ គ្រួសារមួយចំនួនអាចបានទទួលធនធានពីបងប្អូននៅបរទេស ។ ដូច្នេះជនទាំងនេះមានលទ្ធភាពច្រើនជាងក្នុងការប្រឈមមុខផ្សេងៗ និងវិបត្តិ ឬការប៉ះទង្គិចធ្ងន់ៗដែលគេមិនបានដឹងជាមុន ។

ទីពីរ ប្រជាជនបានទទួលដីដែលមានគុណភាពដីខុសៗគ្នានៅឆ្នាំ១៩៨៩។ ដូចបានលើកឡើងហើយ អ្នករស់នៅក្នុងបណ្តាខេត្តមានប្រជាជនច្រើន ដូចជា តាកែវ ព្រៃវែង ឬស្វាយរៀងជាដើម ច្រើនតែបានទទួលដីធ្លីតិចជាងពួកអ្នករស់នៅខាងតំបន់ពាយព្យដូចជានៅខេត្តបាត់ដំបង ឬពោធិសាត់ ។ មួយចំណែកទៀត ដីនៅខេត្តបាត់ដំបង និងពោធិសាត់ ច្រើនមានដីជាតិល្អជាងនៅខេត្តតាកែវ ព្រៃវែង ឬស្វាយរៀង ។ ដូច្នេះហើយនៅក្នុងតំបន់នានាដែលអំណោយផល ប្រជាជនអាចបង្កបង្កើនផលបានច្រើនជាង និងមានស្បៀងផ្គត់ផ្គង់ជីវភាពខ្លួនបានគ្រប់គ្រាន់ជាង ។

ចុងបញ្ចប់នោះ គឺគ្រួសារនីមួយៗអាចជួបប្រទះឧបសគ្គផ្សេងៗគ្នាក្នុងការរក្សាដីធ្លីរបស់ពួកគេ។ ជាធម្មតាគ្រួសារខ្លះបានជួបប្រទះបញ្ហាបន្ទាន់នានា ដូចជាគ្រោះផ្សេងៗ ជំងឺ និងមរណៈភាពរបស់សមាជិកគ្រួសារ ដែលអ្នកខ្លះមិនបានជួបប្រទះ។

១៨ របៀបដែលអង្កេតនីមួយៗជ្រើសយកប្រជាជនមុខសញ្ញា មានលក្ខណៈខុសៗគ្នា ទោះបីអង្កេតទាំងនេះជ្រើសរើសយកសំណាក គំរូពីបណ្តាខេត្តដូចគ្នាក៏ដោយ ។

**តារាង២.១១. ទំហំដីជាមធ្យម[១] និងភាពគ្មានដីធ្លី[២] តាមខេត្ត-ក្រុងនានា**

| ខេត្ត-ក្រុង | ដង់ស៊ីតេប្រជាជន[៣] | ១៩៩៥-៩៦ MRC | | ១៩៩៧ SES | | ១៩៩៨ Baseline | |
|---|---|---|---|---|---|---|---|
| | | ដីមធ្យម | គ្មានដី | ដីមធ្យម | គ្មានដី | ដីមធ្យម | គ្មានដី |
| បន្ទាយមានជ័យ | 86 | .. | .. | 2.05 | 13% | .. | .. |
| បាត់ដំបង | 64 | 1.76 | 25% | 1.15 | 27% | 1.32 | 29% |
| កំពង់ចាម | 171 | 0.51 | 20% | 0.63 | 19% | 0.91 | 4% |
| កំពង់ឆ្នាំង | 79 | 0.81 | 25% | 0.43 | 16% | 0.44 | 17% |
| កំពង់ស្ពឺ | 88 | .. | .. | 0.91 | 6% | 0.71 | 7% |
| កំពង់ធំ | 46 | 0.97 | 16% | 1.31 | 9% | 0.91 | 1% |
| កំពត | 113 | .. | .. | 0.77 | 2% | 0.83 | .. |
| កណ្តាល | 301 | 0.45 | 35% | 0.79 | 17% | 0.55 | 13% |
| កោះកុង | 11 | .. | .. | 4.38 | 50% | .. | .. |
| ក្រចេះ | 22 | .. | .. | 1.23 | 23% | 0.48 | 37% |
| ភ្នំពេញ | 2,680 | 0.35 | .. | .. | .. | .. | .. |
| ព្រៃវែង | 196 | .. | .. | 1.09 | 7% | 1.21 | 8% |
| ពោធិសាត់ | 31 | 1.63 | 7% | 1.81 | 13% | .. | .. |
| រតនគីរី | 8 | .. | .. | 0.42 | 3% | .. | .. |
| សៀមរាប | 58 | 1.10 | 12% | 0.97 | 8% | 0.99 | 4% |
| ក្រុងព្រះសីហនុ | 112 | .. | .. | 0.40 | .. | .. | .. |
| ស្ទឹងត្រែង | 7 | .. | .. | 1.87 | .. | 1.04 | 2% |
| ស្វាយរៀង | 167 | .. | .. | 1.28 | 4% | 0.57 | 6% |
| តាកែវ | 226 | .. | .. | 0.83 | 3% | 0.92 | 8% |
| ឧត្តរមានជ័យ | 13 | .. | .. | .. | .. | 0.86 | 6% |

*កំណត់សំគាល់: [១] ទំហំដីជាមធ្យម គឺជាទំហំដីកសិកម្មគិតជាហិកតាក្នុងមួយគ្រួសារ. [២] ភាពគ្មានដីធ្លី គឺជាភាគរយនៃគ្រួសារប្រជាជនដែលគ្មានដីកសិកម្ម. [៣] បានមកពីលទ្ធផលនៃជំរឿនប្រជាជន ។ ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ MRC 1995-96, អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច NIS 1997, អង្កេត Baseline, UNWFP 1998/ ជំរឿនប្រជាជន NIS 1999 ។*

ដោយសារមូលហេតុនេះ ប្រជាជនមួយចំនួនអាចពង្រីកដីកាន់កាប់របស់ខ្លួនដោយទិញដីបន្ថែមទៀត ឯអ្នកខ្លះទៀតបានលក់ដីរបស់ខ្លួន ហើយក៏ក្លាយជាអ្នកគ្មានដី ឬសឹងតែគ្មានដី ។ កំណើនប្រជាជនយ៉ាងលឿន និងប្រព័ន្ធផ្គត់ផ្គង់ដីធ្លីដ៏ទន់ខ្សោយបានធ្វើឱ្យដំណើរការនេះកាន់តែយ៉ាប់យ៉ឺនថែមទៀត ។ ការប្រែប្រួលខុសលំនាំដើម (distortions) នៃទីផ្សារដីធ្លីបច្ចុប្បន្នមិនគ្រាន់តែមិនអាចទប់ស្កាត់ការប្រមូលផ្តុំដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែវាបានពន្លឿន ដំណើរការប្រមូលផ្តុំនេះថែមទៀតនៅតំបន់ជនបទកម្ពុជា ។ ប៉ុន្តែគួរឱ្យស្តាយណាស់ ដែលជាទូទៅគេពុំមានទិន្នន័យសព្វគ្រប់អំពីការប្រមូលផ្តុំដីធ្លីនៅក្នុងប្រទេសកម្ពុជា ។

ផ្អែកលើទិន្នន័យនៃអង្កេត យើងអាចគូរ Lorenz curve[១៩] និងគណនា Gini coefficients[២០] ដើម្បីបង្ហាញពីកំរិតនៃការប្រមូលផ្តុំដីធ្លីក្នុងពេលបច្ចុប្បន្ន ។ អង្កេតទាំងឡាយបានបង្ហាញឱ្យឃើញថា ប្រជាជនដែលមានដីធំជាងមួយហិកតាក្នុងមួយគ្រួសារបានកាន់កាប់ដីដាំដុះយ៉ាងច្រើន ហើយប្រជាជនឯទៀត មានដីតិចតួចពេកសំរាប់បង្កបង្កើនផល ។ តារាង២.១២ និង

---

១៩ វាបង្ហាញឱ្យឃើញពីទំហំនៃវិសមភាពនៃការបែងចែកដីធ្លីនៅក្នុងសង្គមមួយ ។ បើវិសមភាពកាន់តែធំឡើង Lorenz curve ក៏កាន់តែឃ្លាតខ្លាំងចេញពីបន្ទាត់ស្មើភាពឥតខ្ចោះដែរ (បន្ទាត់មានមុំ ៤៥អង្សារ) ។

២០ វាគឺជាស្ថិតិសង្ខេបនៃវិសមភាពដែលដកស្រង់ចេញពី Lorenz curve ដែលឱ្យផ្ទៃមួយនៅចន្លោះ Lerenx curve ដែលបានអង្កេត និងបន្ទាត់សមភាពពិតជាប្រភាគនៃផ្ទៃសរុបនៅក្រោមបន្ទាប់សមភាពពិត ។ ចុះមេគុណនេះ នេះ មានតំលៃអតិបរិមាមួយស្មើ ១ (វិសមភាពពិត) និង តំលៃអតិបរិមាមួយ ស្មើ 0 (សមភាពពិត) ។

ក្រាហ្វិក២.៥ បង្ហាញនូវរូបភាពពីរនៃវិសមភាពក្នុងការបែងចែកដីធ្លីនៅកម្ពុជា ។ Gini coefficient នៃវិសមភាពទូទៅក្នុងការកាន់កាប់ដីធ្លី (ដោយផ្អែកលើទិន្នន័យនៃអង្កេត) ដែលប្រែប្រួលពី 0,៤៧ ដល់ 0,៦៦ បានឆ្លុះបញ្ចាំងពីវិសមភាពកំរិតខ្ពស់ ។ Lorenz curves នៃអង្កេតទាំងបួន បានឆ្លុះបញ្ចាំងពីវិ-សមភាពកំរិតខ្ពស់ក្នុងការបែងចែកដីធ្លី ហើយតារាង២.១២ បានផ្តល់ពត៌មានលំអិតថែមទៀតអំពីវិសមភាពក្នុងការកាន់កាប់ដីធ្លី ដោយបង្ហាញពីសមាសភាគ (ratio) រវាងភាគរយនៃម្ចាស់ដី និងភាគរយនៃដីតាមប្រភេទទំហំនីមួយៗ ។

**តារាង៦.២ ភាគរយនៃគ្រួសារ និងទំហំជាមធ្យមនៃដីកសិកម្មកាន់កាប់**

| ប្រភេទទំហំដី | ភាគរយនៃគ្រួសារ | | | ភាគរយនៃដីកសិកម្មកាន់កាប់ | | |
|---|---|---|---|---|---|---|
| | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] |
| **អង្កេត MRC** (Gini coefficient នៃការប្រមូលផ្តុំដី = 0,៦១) | | | | | | |
| គ្មានដី | 23% | 30% | 24% | - | - | - |
| - មានដី 0,0-0,៥ហិកតា | 34% | 37% | 34% | 12% | 19% | 13% |
| - មានដី 0,៥-១,0ហិកតា | 22% | 20% | 21% | 24% | 32% | 22% |
| - មានដីលើសពី ១ហិកតា | 21% | 13% | 21% | 64% | 49% | 65% |
| អង្កេត SES (ជនបទ) (Gini coefficient នៃការប្រមូលផ្តុំដី = 0.66) | | | | | | |
| គ្មានដី | 11% | 15% | 12% | - | - | - |
| - មានដី 0,0-0,៥ហិកតា | 37% | 48% | 40% | 8% | 18% | 10% |
| - មានដី 0,៥-១,0ហិកតា | 26% | 23% | 25% | 19% | 29% | 20% |
| - មានដីលើសពី ១ហិកតា | 26% | 14% | 23% | 73% | 53% | 70% |
| អង្កេត Baseline (Gini coefficient នៃការប្រមូលផ្តុំដី = 0,៥0) | | | | | | |
| គ្មានដី | 11% | 11% | 11% | - | - | - |
| - មានដី 0,0-0,៥ហិកតា | 34% | 43% | 35% | 14% | 14% | 14% |
| - មានដី 0,៥-១,0ហិកតា | 32% | 23% | 31% | 31% | 18% | 30% |
| - មានដីលើសពី ១ហិកតា | 23% | 23% | 23% | 55% | 68% | 56% |
| អង្កេត PET (Gini coefficient នៃការប្រមូលផ្តុំដី = 0,៤៧) | | | | | | |
| គ្មានដី | 16% | 30% | 17% | - | - | - |
| - មានដី 0,0-0,៥ហិកតា | 19% | 17% | 18% | 7% | 8% | 7% |
| - មានដី 0,៥-១,0ហិកតា | 29% | 23% | 29% | 24% | 24% | 24% |
| - មានដីលើសពី ១ហិកតា | 36% | 30% | 36% | 69% | 68% | 69% |

*កំណត់សំគាល់:* [១] *មធ្យមភាគសមតា ។ ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ, MRC 1995-96; អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច, NIS1997; អង្កេត Baseline, UNWFP 1998; និង អង្កេត PET, UNWFP 1998 ។*

អង្កេតទាំងបី (លើកលែងតែអង្កេត Baseline 1998 ចេញ) បានបង្ហាញថា ប្រជាជនភាគតិច (២0-៣0%នៃប្រជាជនសរុប) ដែលមានដីធំជាង ១ហិកតា/គ្រួសារ គ្រប់គ្រងដីប្រហែល ៧0% នៃផ្ទៃដីកសិកម្មសរុប គឺនៅសល់ដីប្រហែល ១0% ប៉ុណ្ណោះសំរាប់ប្រជាជនភាគច្រើនដែលមានដីតិចជាង 0,៥ហិកតាក្នុងមួយគ្រួសារ ។ តារាងនេះក៏បង្ហាញថា ប្រជាជនដែលមានដី 0,0-0,៥ហិកតាក្នុងមួយគ្រួសារ កាន់កាប់ប្រហែលតែ ១0% នៃដីកសិកម្មសរុបប៉ុណ្ណោះ ហើយប្រហែល ៣0% នៃប្រជាជនសរុបដែលមានដី 0,៥-១,0ហិកតាក្នុងមួយគ្រួសារ បានកាន់កាប់ដី ប្រហែល ២0% នៃដីកសិកម្មសរុប ។

គេជឿថា កាលណាមានតំណាងកាន់តែច្រើន និងឬក៏មានសំណាកគំរូមានទំហំកាន់តែធំឡើង ការវិភាគវិសមភាពក្នុងការបែងចែកដី ក៏កាន់តែបានសុក្រិតជាង ។ នៅក្នុងអង្កេតទាំងបួន Lorenz curves និង Gini coefficients នៃការបែងចែកដីធ្លី

បានបង្ហាញពីកំរិតខុសគ្នាយ៉ាងច្រើនពីអង្កេតមួយទៅអង្កេតមួយនៃវិសមភាពនៅក្នុងការចែងចែកដីធ្លី ។ សំរាប់អង្កេតធំៗដូចជាអង្កេត MRC និងអង្កេត NIS ជាដើម ដែលតំណាងឱ្យប្រទេសទាំងមូលបានល្អជាង គឺមាន Lorenz curves ឃ្លាតយ៉ាងឆ្ងាយទៅខាងស្តាំនៃបន្ទាត់ស្មើភាពឥតខ្ចោះ (line of perfect equality) និងមាន Gini coefficients ធំ (លើសពី 0,៦0) ។ ដូច្នេះគេអាចសន្និដ្ឋានថា ការបែងចែកដីធ្លីនៅកម្ពុជាជាទូទៅ មានការប្រែប្រួលខុសលំនាំដើមខ្លាំងណាស់ (very skewed) ។

**ក្រាហ្វិក២.៦ Lorenz Curve នៃការបែងចែកដីកសិកម្ម**




*កំណត់សំគាល់:* [១] *បន្ទាត់ស្មើភាពឥតខ្ចោះ តំណាងឱ្យ Gini coefficient = ១ ដែលជាការបែងចែកដីធ្លីល្អឥតខ្ចោះ ។ វាបង្ហាញថា ក្រុមម្ចាស់ដីនានា កាន់កាប់ទំហំដីគិតជាភាគរយប៉ុនៗគ្នា ។ ឧទាហរណ៍ ១០% នៃប្រជាជនដែលក្រជាងគេកាន់កាប់ ១០% នៃទំហំដីសរុប ហើយ ១០% នៃប្រជាជន ដែលមានជាងគេ ក៏កាន់កាប់ ១០% នៃទំហំដីសរុបដែរ ។ ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ MRC 1995-96, អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច NIS 1997, អង្កេត Baseline, UNWFP 1998 និងអង្កេត PET, UNWFP 1998 ។*

## ២.៦ ការជួលដីធ្លី

គំលាតរវាងអ្នកមាន និងអ្នកក្រ កាន់តែរីកធំឡើងទៀត ដោយសារលក្ខណៈមិនស្មើភាពនៅក្នុងការបែងចែកដី និងការកាន់កាប់ដី ។ ដំណើរការនេះបានបណ្តាលឱ្យមានកំណើននៃការជួលដី ដែលជាដំណោះស្រាយជាធម្មតាមួយនៅក្នុងករណីមានការ ខ្វះខាតនូវដីកាន់កាប់ ។ ប្រជាជនដែលគ្មានដី ឬមានដីតិចតួច ត្រូវជួលដីពីគេតាមបែបបទ "ជួលដាច់" (បង់ថ្លៃឈ្នួលដែលមាន ចំនួនជាក់លាក់មិនប្រែប្រួល)[២១] ឬតាមការប្រវាស់ (បែងចែកផលគ្នា)[២២] ។ ការជួលដាច់ដោយបង់ថ្លៃឈ្នួលដីជាប្រាក់ ឬវត្ថុ គឺជាបែបបទដែលគេនិយមប្រើជាងគេនៅក្នុងតំបន់ជនបទ ។

**តារាង២.១៣ ការជួលដីធ្លី**

| ភាគរយនៃគ្រួសារដែល | អង្កេត MRC | | | អង្កេត NIS | | |
|---|---|---|---|---|---|---|
| | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] |
| ជួលដីពីគេ | 10.7% | 5.9% | 9.8% | 3.2% | 2.2% | 3.0% |
| ជួលដីឱ្យគេ | 5.1% | 6.5% | 5.4% | .. | .. | .. |

*កំណត់សំគាល់: [១] មធ្យមភាគសមតា ។ ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ MRC 1995-96, អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច NIS 1997 ។*

អង្កេតនានាបានបង្ហាញយ៉ាងច្បាស់ថា ទីផ្សារជួលដីមានសកម្មភាពច្រើននៅក្នុងតំបន់ធ្វើអង្កេត ។ ក្នុងអង្កេត MRC ប្រជាជនប្រហែល ១០% បានរាយការណ៍ថាបានជួលដី ឯក្នុងអង្កេត NIS ប្រជាជនដែលជួលដីមាន ៣% (តារាង២.១៣) ។ គេគួរចាំថា អង្កេត MRC ផ្តោតលើបណ្តាសហគមន៍ពឹងផ្អែកលើការនេសាទ ចំណែកឯអង្កេត NIS វិញមានលក្ខណៈតំណាងឱ្យទូទាំងប្រទេសជាង ដោយគ្របដណ្តប់លើ ២២ខេត្ត ។ គេបានពិនិត្យឃើញថា អត្រានៃការជួលដីមានកំរិតខ្ពស់ជាងនៅក្នុងចំណោមគ្រួសារមានបុរសជាមេគ្រួសារ ។

**តារាង៥.១០ ការជួលដីស្រែ និងដីចំការ**

| ភាគរយនៃគ្រួសារដែល | អង្កេត Baseline | | | អង្កេត PET | | |
|---|---|---|---|---|---|---|
| | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] |
| ជួលស្រែវស្សាពីអ្នកដទៃ | 9.7% | 2.6% | 6.7% | 7.1% | 2.6% | 6.7% |
| ជួលស្រែវស្សាឱ្យអ្នកដទៃ | .. | .. | .. | 2.9% | 1.3% | 2.8% |
| ជួលស្រែប្រាំងពីអ្នកដទៃ | 0.9% | 0% | 0.8% | 0.4% | 0% | 0.4% |
| ជួលស្រែប្រាំងឱ្យអ្នកដទៃ | .. | .. | .. | 0.1% | 0% | 0.1% |
| ជួលដីចំការពីអ្នកដទៃ | 1.2% | 0% | 1.1% | 1.3% | 0% | 1.3% |
| ជួលដីចំការឱ្យអ្នកដទៃ | .. | .. | .. | 0.1% | 0% | 0.1% |
| ជួលដីឱ្យអ្នកដទៃ[២] | 4.5% | 11.0% | 4.9% | 2.5% | 0% | 2.3% |

*កំណត់សំគាល់: [១] មធ្យមភាគសមតា, [២] សំនួរទី១៤៨ នៃអង្កេត Baseline និងសំនួរទី២០០៨ នៃអង្កេត PET មិនបានបញ្ជាក់ថាតើដីប្រភេទណាត្រូវបានជួលទៅឱ្យកសិករឯទៀតដើម្បីដោះស្រាយវិបត្តិ/ការប៉ះទង្គិចធ្ងន់ធ្ងរ និងមិនបានដឹងមុន ក្នុងឆ្នាំ១៩៩៧ និង ១៩៩៨ ។*
*ប្រភព: អង្កេត Baseline, UNWFP 1998 និងអង្កេត PET, UNWFP 1998 ។*

ការជួលដីកសិកម្ម គេឃើញមានជាទូទៅដែរ ប៉ុន្តែមិនមែនភាគច្រើនដូចការដាំដុះដោយម្ចាស់ដីខ្លួនឯងទេ ។ នៅក្នុងតំបន់ធ្វើអង្កេត Baseline និងធ្វើអង្កេត PET អង្កេតទាំងពីរនេះបានរាយការណ៍ថា អត្រាជួលដីស្រែវស្សា មានកំរិតខ្ពស់ច្រើនជាងអត្រាជួលដីស្រែប្រាំង ឬដីចំការ (តារាង២.១៤) ។ ប៉ុន្តែរឿងនេះវាច្បាស់ជាមកពីផ្ទៃដីតូចនៃដីស្រែប្រាំង និងដីចំការនៅ

---

២១ ថ្លៃឈ្នួលជាក់លាក់: អ្នកជួលដីគេ បង់ថ្លៃឈ្នួលជាប្រាក់ ឬជាវត្ថុតាមចំនួនជាក់លាក់មួយ ទៅឱ្យម្ចាស់ដីដើម្បីបានសិទ្ធិធ្វើការដាំដុះលើដីជួល (Ray 1998:419) ។
២២ ការប្រវាស់បែងចែកផលគ្នា: អ្នកជួលដីគេត្រូវផ្តល់ផលដំណាំមួយចំណែកតាមការព្រមព្រៀងគ្នា ទៅឱ្យម្ចាស់ដី (Ray 1998:419) ។

ក្នុងតំបន់ធ្វើអង្កេត ។ អត្រាកសិករជួលដីពីគេ មានកំរិតខ្ពស់ជាងអត្រាអ្នកជួលដីឱ្យគេ គឺឆ្លុះបញ្ចាំងពីភាពមិនស្មើគ្នានៃការបែងចែកដី ។ តារាង២.១៤ ផ្តល់ពតិមានលំអិតថែមទៀតពីអត្រាជួលដីនៃគ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានបុរសជាមេគ្រួ ។

## ២.៧ ធនធានទ្រព្យរួម

ទោះបីក្រឹត្យច្បាប់នានាដែលមានស្រាប់ មិនបានកំណត់អោយបានច្បាស់លាស់អំពីធនធានទ្រព្យរួមក៏ដោយ ក៏ធនធានទាំងនេះត្រូវបានគេយកទៅធ្វើជាទ្រព្យសម្បត្តិឯកជនក្នុងសន្ទុះមួយគួរអោយព្រួយបារម្ភ ។ តំបន់ធំៗ ដែលជាធនធានទ្រព្យរួមដូចជា ព្រៃឈើ ទន្លេ បឹងបួរ និងដីកសិកម្ម (ដែលមិនបែងចែកក្នុងទសវត្សរ៍ឆ្នាំ១៩៨០) ត្រូវធ្លាក់ទៅនៅក្រោមការគ្រប់គ្រងរបស់ឯកជន ។ ព្រៃឈើរាប់លានហិកតា ត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុនឯកជន ក្នុងលក្ខណៈជាព្រៃសម្បទាន, ចំការធំៗជាច្រើនត្រូវបានកសាងឡើង, ឡូត៍នេសាទជាច្រើនត្រូវបានបង្កើតឡើងនៅតាមទន្លេ ស្ទឹង បឹងបួរ ដីកសិកម្មមិនទាន់បែងចែកដ៏ច្រើនសន្ធឹកត្រូវបានគេរំលោភយកដោយខុសច្បាប់ ហើយបានក្លាយជាទ្រព្យឯកជនដោយមានមន្ទិលសង្ស័យ ។ ដូច្នេះ ប្រជាជនកាន់តែមានលទ្ធភាពថយចុះហើយ ក្នុងការប្រើប្រាស់ធនធានទ្រព្យរួមដែលគេបានធ្វើឯកជននីយកម្មបែបនេះ ហើយអត្ថប្រយោជន៍នៃធនធានទ្រព្យរួមចំពោះប្រជាជនភាគច្រើននៅក្នុងសង្គមក៏ត្រូវបានកាត់បន្ថយ ។

ទោះបីគេមានជំនឿថា ការលក់ដូរធនធានទ្រព្យរួមកើតមាននៅក្នុងទីផ្សារក៏ដោយ ក៏ពតិមានដែលគេប្រមូលបានក្នុងរឿងនេះមានតិចតួចណាស់ ។ ការបែងចែកដីក្នុងឆ្នាំ១៩៨៩ និងច្បាប់ភូមិបាលឆ្នាំ១៩៩២ មិនបានកំណត់ទេថា ដីអ្វីខ្លះជាទ្រព្យរួម ។ បន្ថែមលើនេះទៀត ការអង្កេតទាំង៤ ក៏មិនបានផ្តល់ពតិមានអ្វីធំដុំដែរ ពីចំឡងការនានាដែលគេបានធ្វើលើធនធានទ្រព្យរួម ។ ក្នុងនេះគេមានត្រឹមតែតួលេខផ្លូវការ មួយចំនួនស្តីពីដីព្រៃសម្បទាន ដីកសិកម្មសម្បទាន និងឡូត៍នេសាទនានាដែលត្រូវបានប្រគល់ទៅឱ្យឯកជនប្រើប្រាស់តែប៉ុណ្ណោះ ។ យោងតាមក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដីព្រៃឈើ ប្រមាណ ៥លានហិកតា (មានទាំងសម្បទានបី ដែលទើបលុបចោលនាពេលថ្មីៗនេះចំនួន ២៦៤.៩២៨ហិកតា) និងដីកសិកម្ម ប្រមាណជិត ០,៧លានហិកតា ត្រូវបានប្រគល់អោយក្រុមហ៊ុនឯកជនរួចហើយ ដើម្បីធ្វើវិនិយោគរយៈពេលវែង ។ ផ្ទៃទឹក ឬឡូត៍នេសាទ ប្រមាណ ១លានហិកតា ក៏ត្រូវបានដាក់ឱ្យក្រុមហ៊ុន និងបុគ្គលជាឯកជនដេញថ្លៃ ដើម្បីធ្វើអាជីវកម្ម ។

ការថយចុះនៃលទ្ធភាពទាញយកផល ឬអត្ថប្រយោជន៍ពីធនធានទ្រព្យរួម ក៏ត្រូវបានបង្ហាញឱ្យឃើញនៅក្នុងអង្កេតទាំងបី (លើកលែងតែអង្កេត NIS ចេញ) ។ ជាទូទៅ អត្ថប្រយោជន៍ដែលអាចទាញយកបានពីធនធានទ្រព្យរួមបានថយចុះយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ។ អង្កេត MRC បានបែងចែកធនធានទ្រព្យរួមជាប្រាំប្រភេទៈ ព្រៃលិចទឹក ទន្លេ/ស្ទឹង/បឹងបួរធំៗ វាលស្រែលិចទឹក មាត់និងបាតទន្លេ/ស្ទឹង/បឹងបួរ និងប្រឡាយស្រោចស្រព/ទំនប់/ស្ទឹង/អូរតូចៗ ។ អង្កេតបានធ្វើវិភាគពីនិន្នាការនៃលទ្ធភាពទាញយកផលឬអត្ថប្រយោជន៍ពីទ្រព្យរួមនានា និងបានរកឃើញថា លទ្ធភាពនេះបានថយចុះគួរអោយកត់សំគាល់ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ ។ គ្រួសារសំណាកគំរូភាគច្រើន (ជាង៨០%) បានរាយការណ៍ពីការថយចុះនៃអត្ថប្រយោជន៍ ឬផលិតផលដែលអាចទាញយក បានពីព្រៃលិចទឹក ទន្លេស្ទឹង/បឹងបួរធំៗ និងមាត់និងបាត/ទន្លេ/ស្ទឹង/បឹងបួរ (តារាង២.១៥) ។ ទន្ទឹមនឹងនេះក៏មានអ្នកឆ្លើយសំភាសន៍ក្នុងសមាមាត្រទាបជាងនេះបន្តិច បានរាយការណ៍ពីការថយចុះនៃផលិតផលដែលអាចទាញយកបានពីវាលស្រែលិចទឹក និងប្រឡាយស្រោចស្រព/ទំនប់/ស្ទឹងអូរតូចៗ ។

អង្កេត Baseline និងអង្កេត PET ក៏បានបង្ហាញដែរថា លទ្ធភាពទាញយកផល ឬអត្ថប្រយោជន៍ពីធនធានទ្រព្យរួមបានថយចុះ បើធៀបទៅនឹងមួយឆ្នាំមុនឆ្នាំធ្វើអង្កេត ។ ប្រហែលជា ៣៧% នៃអ្នកឆ្លើយសំភាសន៍ក្នុងអង្កេត Baseline និង ៦៥% អ្នកឆ្លើយសំភាសន៍ក្នុងអង្កេត PET បានរាយការណ៍ថា ផលិតផល និងអត្ថប្រយោជន៍ដែលពួកគេទាញយកបានពីព្រៃឈើបានថយចុះ បើធៀបនឹងមួយឆ្នាំមុនឆ្នាំធ្វើអង្កេត ។ តួលេខខុសគ្នានេះប្រហែលជាមកពីលក្ខណៈខុសគ្នានៃបរិស្ថានតំបន់ទាំងពីរ ។

**តារាង២.១៥ ភាគរយគ្រួសារដែលបានរាយការណ៍ពីការប្រែប្រួលលទ្ធភាពទាញយកផល ឬអត្ថប្រយោជន៍ពីធនធានទ្រព្យរួម ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ**

| ធនធានទ្រព្យរួម | កើនឡើង | ថយចុះ | នៅថេរ |
|---|---|---|---|
| ព្រៃលិចទឹក | 1 .7% | 95 .3% | 3 .0% |
| ទន្លេ/ស្ទឹង/បឹងបួរធំៗ | 5 .6% | 83 .2% | 11 .2% |
| វាលស្រែលិចទឹក | 37 .2% | 40 .0% | 22 .8% |
| មាត់និងបាត/ទន្លេ/ស្ទឹង/បឹងបួរ | 8 .6% | 81 .9% | 9 .5% |
| ប្រឡាយស្រោចស្រព/ទំនប់/អូរ | 15 .7% | 62 .3% | 22 .0% |

*ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ, MRC 1995-96 ។*

អង្កេតក៏បានបង្ហាញដែរថា អត្ថប្រយោជន៍ដែលទាញយកបានពីសកម្មភាពនេសាទ បានថយចុះយ៉ាងខ្លាំង បើធៀបនឹងឆ្នាំមុន ។ ប្រហែល ៤៩% នៃអ្នកឆ្លើយសំភាសន៍ក្នុងអង្កេត Baseline និង ៧៧% នៃអ្នកឆ្លើយសំភាសន៍ក្នុងអង្កេត PET បានរាយ ការណ៍ថា ផលដែលពួកខ្លួនបានទទួលពីសកម្មភាពនេសាទ បានថយចុះបើធៀបទៅនឹងឆ្នាំមុន[២៣] (តារាង២.១៦) ។

**តារាង២.១៦ ភាគរយនៃគ្រួសារដែលបានរាយការណ៍ថា មានការប្រែប្រួលនៅក្នុងលទ្ធភាពទាញយកផលពីធនធានទ្រព្យរួម នៅក្នុងរយៈពេលមួយឆ្នាំ**

| ធនធានទ្រព្យរួម | 1998-Baseline[១] | 1998-PET[២] |
|---|---|---|
| ផលរកបានពីសកម្មភាពព្រៃឈើ | | |
| – ថយចុះ | 37% | 65% |
| – កើនឡើង | 19% | 15% |
| – នៅដដែល | 44% | 20% |
| ផលរកបានពីសកម្មភាពនេសាទ | | |
| – ថយចុះ | 49% | 77% |
| – កើនឡើង | 10% | 4% |
| – នៅដដែល | 41% | 19% |

*កំណត់សំគាល់: [១] អង្កេត Baseline ប្រៀបធៀបទិន្នាការទាញយកផល រវាងឆ្នាំ១៩៩៧ ធៀបនឹងឆ្នាំ១៩៩៦, [២] អង្កេត PET ប្រៀបធៀបនិន្នាការទាញយកផលរវាងឆ្នាំ១៩៩៨ ធៀបនឹងឆ្នាំ១៩៩៧ ។ ប្រភព: អង្កេត Baseline និងអង្កេត PET, UNWFP 1998 ។*

ការថយចុះនៃលទ្ធភាពទាញយកផល និងអត្ថប្រយោជន៍ពីធនធានទ្រព្យរួម បណ្តាលមកពីការធ្វើអាជីវកម្មហួសកំរិត ។ តាមអង្កេត MRC ៧៧% នៃអ្នកឆ្លើយសំភាសន៍យល់ឃើញថា ការធ្វើអាជីវកម្មហួសកំរិត គឺជាកត្តាចំបងដែលធ្វើឱ្យមានការថយចុះនៃអត្ថប្រយោជន៍ទាញយកបានធនធានទ្រព្យរួម (តារាង២.១៧) ។ អង្កេត MRC ដែលធ្វើឡើងក្នុងឆ្នាំ១៩៩៥-៩៦ បានរកឃើញដែរថា មានអ្នកឆ្លើយសំភាសន៍តែ ៥% ប៉ុណ្ណោះដែលបានអះអាងថា ការប្រែក្លាយធនធានទ្រព្យរួមទៅជាទ្រព្យឯកជន គឺជាកត្តាដ៏សំខាន់មួយនៃការថយចុះនេះ ។

អង្កេត PET ដែលធ្វើឡើងនៅឆ្នាំ១៩៩៨ បានបង្ហាញថា ជាង ៨២% នៃគ្រួសារឆ្លើយសំភាសន៍បានត្អូញត្អែរពីការថយចុះនៃផលដែលរកបានពីព្រៃឈើ និងការនេសាទ ។ ដូចក្នុងអង្កេត MRC ដែរ អ្នកឆ្លើយសំភាសន៍ភាគច្រើន (ជាង ៨០%) បានរាយការណ៍ថា ពួកគេប្រមូលផលលិតផលអំពីព្រៃឈើ និងសកម្មភាពនេសាទបានតិចជាងមុន ដោយមូលហេតុផលិតផលទាំងនេះ វាក្រជាងមុន ។ មានប្រជាជនជាង ១០% បានត្អូញត្អែរពីការហាមឃាត់ការយកផលពីធនធានព្រៃឈើ និងមាន ១% បានត្អូញ

[២៣] អង្កេត Baseline បានប្រៀបធៀបផលទាញបានពីធនធានទ្រព្យរួមរវាងឆ្នាំ១៩៩៧ ធៀបនឹងឆ្នាំ១៩៩៦ ចំណែកឯអង្កេត PET បានធ្វើការប្រៀបធៀបរវាងឆ្នាំ១៩៩៨ ធៀបនឹងឆ្នាំ១៩៩៧ ។

ផ្អែរពីការហាមឃាត់ផ្សេងៗខាងនេសាទ (តារាង២.១៨) ។ តួលេខនេះស៊ីគ្នានឹងកំណើននៃការផ្ទេរដីទ្រព្យរួមឱ្យទៅនៅក្រោមការគ្រប់គ្រងរបស់ឯកជន ។

**តារាង២.១៧ កត្តាចំបងគេដែលបានកាត់បន្ថយអត្ថប្រយោជន៍ទាញបានពីធនធានទ្រព្យរួម ដែលគ្រួសារសំភាសន៍យល់ឃើញ**

| កត្តាចំបង | ភាគរយគ្រួសារ |
|---|---|
| អាជីវកម្មហួសកំរិត | 77% |
| ការប្រែប្រួលបរិស្ថាន | 7% |
| ការបំផ្លាញជំរកសត្វ (habitat) | 3% |
| កំណើនសំពាធប្រជាជន | 7% |
| ការប្រើប្រាស់សារធាតុគីមីក្នុងស្រែ | 1% |
| ការប្រែក្លាយធនធានទ្រព្យរួមទៅជាទ្រព្យឯកជន | 5% |
| កត្តាផ្សេងទៀត | 0% |

*ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ, MRC 1995-96 ។*

**តារាង២.១៨ មូលហេតុធ្វើឱ្យមានការថយចុះនៃអត្ថប្រយោជន៍ដែលទាញយកបានពីធនធានទ្រព្យរួម**

| មូលហេតុ | PET | |
|---|---|---|
| | ព្រៃឈើ | នេសាទ |
| ការថយចុះធនធានខាងព្រៃឈើ/នេសាទ | 82% | 87% |
| ការធ្លាក់ថ្លៃផលិតផលខាងព្រៃឈើ/នេសាទ | 2% | 0% |
| ពាណិជ្ជករទិញតិចផលិតផលព្រៃឈើ/នេសាទជាងមុន | 1% | 12% |
| មានអ្នកប្រើប្រាស់ផ្សេងទៀតហាមមិនឱ្យធ្វើអាជីវកម្ម | 11% | 1% |
| ព្រៃឈើ/កន្លែងនេសាទកាន់តែខ្វះសុវត្ថិភាព | 4% | .. |

*ប្រភព: អង្កេត PET, UNWFP 1998 ។*

## ៥.១ ការលក់ដីធ្លី

ទោះបីជាមានប្រជាជនតែមួយភាគតូចប៉ុណ្ណោះដែលមានប័ណ្ណកម្មសិទ្ធិ លើដីធ្លីរបស់ខ្លួនជាផ្លូវការក៏ដោយ (ហើយភាគច្រើនពួកគេមានតែដីតូចៗ) ក៏ការលក់ និងការជួញដី (land transactions and speculation) បានកើតមានឡើង និងមានសកម្មភាពយ៉ាងខ្លាំងក្លានៅតាមតំបន់ជាច្រើនក្នុងប្រទេសកម្ពុជា ចាប់តាំងពីមានការអនុញ្ញាតឯកជននីយកម្មឡើងវិញ ។ តួលេខផ្លូវការរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ បានបង្ហាញថា តាំងពីឆ្នាំ១៩៨៩ មក ការលក់ដីធ្លីជាផ្លូវការ (ដែលមានចុះបញ្ជីនៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៅក្នុងប្រទេសកម្ពុជា (លើកលែងតែនៅភ្នំពេញ) មានជាង ១០.០០០ករណី ។ ប៉ុន្តែគេមានជំនឿថា តួលេខពិតប្រាកដនៃការលក់ដីធ្លី មានចំនួនច្រើនជាងនេះឆ្ងាយណាស់ ។ ការលក់ដូរដីធ្លីនេះ គេធ្វើឡើងលើដីគ្រប់ប្រភេទ គឺមានដីលំនៅដ្ឋាន ដីកសិកម្ម និង ដីជាទ្រព្យសម្បត្តិរួម ។

ជាគោលការណ៍ ការលក់ដូរដីធ្លីទាំងអស់ ត្រូវតែមានការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន ។ អ្នកលក់ និងអ្នកទិញ ត្រូវបំពេញបែបបទក្នុង *លិខិតលក់ផ្ដាច់*[២៤] ។ ក្នុងការអនុវត្តន៍ជាក់ស្ដែង ការលក់ដូរដីធ្លីជាច្រើនមិនបានធ្វើតាមនីតិវិធីនេះទេ ។ ដោយឡែកគេមិនបានប្រើប្រាស់ទំរង់លិខិតលក់ផ្ដាច់ឱ្យបានទៀងទាត់ទេ គេគ្រាន់តែធ្វើលិខិតក្រៅផ្លូវការមួយ ដែលបញ្ជាក់ពីការព្រមព្រៀងគ្នារវាងអ្នកទិញ និងអ្នកលក់ ហើយដែលមានការទទួលដឹងឮពីអាជ្ញាធរមូលដ្ឋានតែប៉ុណ្ណោះ ។

២៤ ឯកសារនេះមួយច្បាប់រក្សាទុកនៅនាយកដ្ឋានសុរិយោដីមួយទៀត ប្រគល់ឱ្យអ្នកទិញ និងត្រូវមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានផង ។

## ដីលំនៅដ្ឋាន

គេឃើញមានសកម្មភាពផ្លាស់ប្តូរម្ចាស់ដីលំនៅដ្ឋានរហូតមក ចាប់តាំងពីពេលដែលរដ្ឋាភិបាលប្រកាសអោយមានកម្មសិទ្ធិឯកជនលើដីលំនៅដ្ឋានមក[២៥] ។ ពិសេសការលក់ដូរបែបនេះកើតមាននៅតាមតំបន់ក្រុងដូចជា ភ្នំពេញ កំពង់ចាម បាត់ដំបង ក្រុងព្រះសីហនុ សៀមរាប ។ ដោយសារតែភាពក្រីក្រ និងការកើនឡើងនៃតំលៃដី ប្រជាជនមួយចំនួនដែលរស់នៅកណ្តាលទីក្រុងធំៗ បានលក់ផ្ទះ ឬដីរបស់ខ្លួន ហើយផ្លាស់ទីលំនៅទៅកាន់កន្លែងផ្សេងទៀត ។

ការលក់ដូរដីលំនៅដ្ឋាន ក៏បានកើតឡើងនៅតាមជនបទផងដែរ ជាពិសេសនៅតាមតំបន់ដែលស្រួលទៅមកទាក់ទងទីក្រុងភ្នំពេញ និងទីក្រុងធំៗ ។ ចំពោះដីធ្លីដែលមានជីជាតិ ឬដែលនៅជិតតំបន់លំហែកំសាន្តនានា ក៏កើតមានសកម្មភាពជួញដូរដីដែរ ។ លោក Meijers (1994:10) បានបញ្ជាក់ថា ពួកអ្នកមានៗដែលរស់នៅតាមតំបន់ទីក្រុង ចូលចិត្តទិញដីមានជីជាតិល្អ ហើយដែលពួកគេអាចដាំដំណាំហូបផ្លែ និងទៅលេងកំសាន្តនៅថ្ងៃអាទិត្យ ។ ការទិញដូរនេះ យើងអាចពិនិត្យឃើញនៅតាមតំបន់ជាយក្រុងធំៗ ។

អង្កេត Baseline និងអង្កេត PET បានបង្ហាញថា ការលក់ដូរដីក្នុងរយៈពេល ១២ខែ មានកំរិតខ្ពស់ ។ អង្កេត Baseline បានបង្ហាញថា ប្រហែល ៣% នៃប្រជាជនដែលគេបានធ្វើអង្កេត បានលក់ដីរបស់ខ្លួននៅឆ្នាំ១៩៩៧ ដើម្បីដោះស្រាយកង្វះខាតធ្ងន់ធ្ងរ ដូចជាកង្វះខាតស្បៀង ឬប្រាក់ចំណូលគ្រួសារ ។ អង្កេត PET ក៏បានបង្ហាញថា ប្រហែល ១% នៃអ្នកឆ្លើយសំភាសន៍បានរាយការណ៍ថា បានលក់ដីរបស់ខ្លួននៅក្នុងឆ្នាំ១៩៩៨ ។ តួលេខខុសគ្នានេះ អាចបណ្តាលមកពីលក្ខណៈដែលថា ៩៤% នៃគ្រួសារសំណាកគំរូនៅក្នុងអង្កេត Baseline មិនបានផ្លាស់ប្តូរកន្លែងរស់នៅតាំងពីឆ្នាំ១៩៨៩ មក ដូច្នេះពួក គេមានលទ្ធភាពក្នុងការបានទទួលដីលំនៅដ្ឋានធំជាងនៅពេលដែលការបែងចែកដីឆ្នាំ១៩៨៩ បើធៀបនឹងប្រជាជនភៀសខ្លួនក្នុងស្រុក ឬអ្នកវិលត្រឡប់ពីជំរំតាមព្រំដែន ។ អត្រាដ៏ខ្ពស់ (៧៦%) នៃគ្រួសារជនភៀសខ្លួនក្នុងអង្កេត PET (អត្រាគ្រួសារជនភៀសខ្លួនក្នុងអង្កេត Baseline មានតែ ៣៦% ទេ) អាចជាមូលហេតុនៃការលក់ដូរដីលំនៅដ្ឋានកំរិតទាប (តារាង២.១៩) ។

**តារាង៥.១ ភាគរយនៃគ្រួសារលក់ដូរដីលំនៅដ្ឋាន**

| ភាគរយនៃគ្រួសារ | អង្កេត Baseline | | | អង្កេត PET | | |
|---|---|---|---|---|---|---|
| | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] | បុរសមេគ្រួសារ | ស្ត្រីមេគ្រួសារ | សរុប[១] |
| លក់ផ្ទះនៅឆ្នាំ១៩៩៧ | 2 .6% | 6 .8% | 2 .8% | . . | . . | . . |
| លក់ដីផ្ទះតាំងពីឆ្នាំ១៩៨៩ | . . | . . | . . | 1 .0% | 2 .6% | 1 .2% |
| លក់ដីផ្ទះនៅឆ្នាំ១៩៩៨ | . . | . . | . . | 0 .8% | 1 .3% | 0 .9% |

*កំណត់សំគាល់:[១] មធ្យមភាគសមតា ។ ប្រភព: អង្កេតBaseline និង អង្កេតPET, UNWFP 1998 ។*

នៅក្នុងអង្កេតទាំងពីរ គេពិនិត្យឃើញអត្រាខុសគ្នាគួរឱ្យកត់សំគាល់នៃការលក់ដូរដីលំនៅដ្ឋានរវាងបណ្តាគ្រួសារមានស្ត្រី ជាមេគ្រួសារ និងគ្រួសារមានបុរសជាមេគ្រួសារ ។ ក្នុងអង្កេត Baseline គ្រួសារមានស្ត្រីជាមេគ្រួសារបានរាយការណ៍ថា ពួកខ្លួនងាយទទួលរងគ្រោះដល់ថ្នាក់ត្រូវលក់ដីធ្លីនៅពេលជួបនឹងវិបត្តិ/ការប៉ះទង្គិច ផ្សេងៗនៅក្នុងគ្រួសារ ។ អង្កេតនេះបាន បង្ហាញថា នៅឆ្នាំ១៩៩៧ អត្រានៃការលក់ផ្ទះក្នុងចំណោមគ្រួសារមានស្ត្រីជាមេគ្រួសារ មានកំរិតធំជាងពីរដង ជាងអត្រាសំរាប់គ្រួសារមានបុរសជាមេគ្រួសារ (តារាង២.១៩) ។ អង្កេត PET ក៏បានបង្ហាញអោយឃើញនូវកំរិតខុសគ្នាយ៉ាងដូច្នេះដែរ

២៥ ការជួលផ្ទះ និងដីឡូត៍ក៏មានកំរិតខ្ពស់ដែរនៅក្នុងតំបន់ទីក្រុង ប៉ុន្តែទំហំនៃចលនការនេះពិបាកប៉ាន់ស្មានណាស់ ដោយសារអង្កេតទាំងបួន មិនបានផ្តល់ពត៌មានអ្វីពីចលនការលើដីលំនៅដ្ឋានក្នុងតំបន់ទីក្រុងទេ ។

រវាងគ្រួសារមានស្ត្រីជាមេគ្រួសារ និងគ្រួសារមានបុរសជាមេគ្រួសារ នៅក្នុងការលក់ដូរដីធ្លី ។

# ជំពូក ទី

# លក្ខណៈនៃគ្រួសារគ្មានដី និង គ្រួសារមានដីតូច

ការសិក្សាជាច្រើនបានរាយការណ៍ពីការប៉ាន់ស្មានខុសគ្នានៃគ្រួសារគ្មានដីធ្លីនៅជនបទកម្ពុជា ពីកំរិតទាប ១០% ទៅកំរិតខ្ពស់ ២០% នៃគ្រួសារទាំងអស់ ។ គេជឿជាក់ជាទូទៅថា គ្រួសារគ្មានដី និងគ្រួសារមានដីតូចគឺជា អ្នកដែលយ៉ាប់យឺនជាងគេនៅក្នុងសង្គម ហើយអ្នកដែលមានដីធំតែងមានជីវភាពធូធារ ។ ទោះបីជាយ៉ាងនេះក្តី គ្រួសារគ្មានដីមិនមែនសុទ្ធតែក្រទាំងអស់ទេ ដោយសារពួកគេមានប្រភពចំណូលផ្សេងទៀតក្រៅពីកសិកម្ម គ្រួសារគ្មានដីទាំងនេះមិនមែនសុទ្ធតែបណ្តាលមកពីលទ្ធផលនៃការបាត់បង់ដីដោយមិនស្ម័គ្រចិត្តឡើយ ។

ដើម្បីផ្តល់ការយល់ដឹងឱ្យកាន់តែប្រសើរនូវសុខមាលភាពរបស់គ្រួសារគ្មានដី និងគ្រួសារមានដីតូច គេត្រូវពិនិត្យមើលជាសំខាន់លើភាពខុសគ្នានៃក្រុមផ្សេងៗ ទៅតាមទំហំនៃដីដែលកាន់កាប់ និងលក្ខណៈរបស់ពួកគេ ។ ប្រការដែលល្អ គឺគេត្រូវប្រើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចនៅឆ្នាំ ១៩៩៧ នៃវិទ្យាស្ថានជាតិស្ថិតិ ដើម្បីបង្ហាញពីគំរូមួយចំនួនពាក់ពន្ធ័នឹងដីធ្លី ដោយហេតុថា វាគ្របដណ្តប់ស្ទើរទូទាំងខេត្តនៅក្នុងប្រទេសកម្ពុជា ថែមទាំងមានវិធីសាស្ត្រកាត់ប៉ាន់គំរូសមស្របទៀតផង ។ ផ្នែកសិក្សាជាបន្តទៀតនេះនឹងពិភាក្សាទៅលើលក្ខណៈនៃក្រុមគ្រួសារនីមួយៗតាមទំហំដីដែលគេកាន់កាប់ ។ ក្រុមទាំងនេះរួមមានគ្រួសារគ្មានដី (គ្មានដី កសិកម្មសោះ) គ្រួសារមានដីតូច (មានដីកសិកម្មតិចជាង 0,៥ហត) អ្នកមានដីមធ្យម (មានដីកសិកម្មចាប់ពី ពី 0,៥-១ហត) និងអ្នកមានដីធំ (មានដីកសិកម្មច្រើនជាង ១ហត) ។

## ៣.១ លក្ខណៈប្រជាសាស្ត្រតាមគ្រួសារ

ជាទូទៅ គេអាចសង្កេតឃើញថា ទំហំគ្រួសារជាមធ្យមនៃប្រជាជនកម្ពុជានៅជនបទដែលបានសម្ភាសន៍មានប្រហែលជា ៥នាក់ ដែលមានទំហំប្រហែលទៅនឹងជំរឿន១៩៩៨ ក្នុងទំហំគ្រួសារប្រមាណ ៥,១នាក់ ។ គ្រួសារមានដីធំហាក់ដូចជាមានទំហំ គ្រួសារធំជាងក្រុមផ្សេងៗ ។ តារាង ៣.១ បង្ហាញថា ទំហំគ្រួសារជាមធ្យមនៃគ្រួសារគ្មានដី, គ្រួសារមានដីតូច, គ្រួសារមានដី មធ្យម មានសមាជិកគ្រួសារ ៥នាក់ ឯទំហំគ្រួសារមានដីធំមានសមាជិកច្រើនជាងបន្តិចគឺ ៦នាក់ ។

ទោះជាយ៉ាងនេះក្តី អត្រាអ្នកក្នុងបន្ទុកដែលជាភាគរយប្រជាជនវ័យក្មេង (0-១៤) និងប្រជាជនចាស់ (អាយុខ្ពស់ជាង ៦៥) ធៀបទៅប្រជាជនពេញវ័យ (អាយុ ១៥-៦៤) នៅក្នុងគ្រួសារគ្មានដី និងគ្រួសារមានដីតូច មានសមាមាត្រខ្ពស់ជាងគ្រួសារមានដីធំ ក៏ប៉ុន្តែភាពខុសគ្នានេះមិនមានលក្ខណៈធំដុំនៅក្នុងស្ថិតិឡើយ ។ អត្រាក្នុងបន្ទុកជាមធ្យមនៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ច គឺ ៩២% (ខ្ពស់ជាងបន្តិចធៀបទៅនឹងជំរឿនឆ្នាំ១៩៩៨ នៃប្រជាជនតាមជនបទដែលមានអត្រា ៨៩,៧%) វាមាន

ន័យថា មានអ្នកក្នុងបន្ទុក ៩២នាក់ ធៀបទៅនឹងអ្នកធ្វើការ ១០០នាក់ នៅក្នុងទំហំប៉ាន់គំរូ ។ អត្រាក្នុងបន្ទុកនៃគ្រួសារគ្មានដី និងគ្រួសារមានដីតូច មានសមាមាត្រជាង ១០០% និង ៩០% រៀងគ្នា ហើយអត្រាក្នុងបន្ទុករបស់គ្រួសារមានដីធំមានតែ ៨៩% ប៉ុណ្ណោះ ( តារាង ៣.១ ) ។

សន្ទស្សន៍ខាងលើបញ្ជាក់ថា គ្រួសារគ្មានដី និងគ្រួសារមានដីតូច គឺជាគ្រួសារថ្មី ។ ថ្វីបើអាយុមធ្យម នៃសមាជិកគ្រួសារនៅក្នុងវ័យ ៤៤ឆ្នាំ របាយនៃអាយុមធ្យមនៃអ្នកដែលមានដីកាន់កាប់មានវ័យខុសគ្នាខ្លាំង ។ សមាជិកគ្រួសារវ័យក្មេងតែងមានសមាមាត្រខ្ពស់នៅក្នុងគ្រួសារគ្មានដី និងគ្រួសារមានដីតូច ( តារាង ៣.១ ) ។ តារាង ៣.១ ក៏បង្ហាញដែរពីសមាមាត្រខ្ពស់នៃគ្រួសារគ្មានដី និងគ្រួសារមានដីតូចដែលមេគ្រួសារមានវ័យខ្ពស់ជាង ៦០ឆ្នាំ ។ អត្រានេះឆ្លុះបញ្ចាំងការពិតឱ្យឃើញថា គ្រួសារក្មេងៗហាក់ដូចជាបាត់ឱកាសទទួលយកដីកាន់កាប់នាពេលការបែងចែកដីក្នុងទសវត្សរ៍១៩៨០ ។ សន្ទស្សន៍ទាំងនេះក៏បានបញ្ជាក់ថា គ្រួសារដែលមេគ្រួសារមានអាយុច្រើនជាង ៦០ឆ្នាំ ប្រហែលជាបានផ្ទេរដីកម្មសិទ្ធិរបស់ខ្លួនឱ្យទៅអ្នកស្នងមរតករួចហើយ ជាលទ្ធផលពួកគេគ្មានសល់ដីសោះឡើយ ។ វាក៏អាចកើតមានដែរដែលថា គ្រួសារថ្មីដែលរៀបការក្រោយការបែងចែកដីនៅឆ្នាំ ១៩៨០ ហើយឪពុកម្តាយរបស់គេពុំមានដីគ្រប់គ្រាន់សំរាប់ចែកឱ្យកាន់កាប់ ។ ការអង្កេតនេះ ស៊ីគ្នាសង្វាក់គ្នាទៅនឹងការសិក្សាមួយរបស់ LADIT របស់ Oxfam GB ដែលសំភាសគ្រួសារគ្មានដី [១] ចំនួន ៤.០០០ នៅតាមភូមិ ។ របាយការណ៍នេះបញ្ជាក់ថា ជាង ៥០% នៃគ្រួសារគ្មានដី គឺជាគ្រួសារថ្មីដែលមិនធ្លាប់មានដីទាល់តែសោះ [២] ។

**តារាង ៣.១ លក្ខណៈប្រជាសាស្ត្រគ្រួសារតាមទំហំដី**

| | គ្មានដី | >0-0.5 | >0.5-1.0 | >1.0 | មធ្យម |
|---|---|---|---|---|---|
| ទំហំគ្រួសារ | 5 | 5 | 5 | 6 | 5 |
| អត្រាក្នុងបន្ទុក | 106 | 90 | 92 | 89 | 92 |
| របាយអាយុនៃមេគ្រួសារ | | | | | |
| - ក្រោម 21 | 1% | 1% | 0% | 0% | 0.4% |
| - 21 – 30 | 22% | 23% | 20% | 14% | 20% |
| - 31 – 40 | 31% | 26% | 30% | 28% | 28% |
| - 41 – 50 | 21% | 17% | 21% | 24% | 20% |
| - 51 – 60 | 10% | 16% | 15% | 21% | 16% |
| - លើសពី 60 | 15% | 17% | 14% | 13% | 15% |
| អាយុមធ្យមនៃមេគ្រួសារ | 42 | 44 | 43 | 45 | 44 |
| ភេទនៃមេគ្រួសារ | | | | | |
| - ប្រុស | 73% | 72% | 79% | 86% | 77% |
| - ស្រី | 27% | 28% | 21% | 14% | 23% |

*Source: Socio-Economic Survey, NIS 1997.*

## ៣.២ ការអប់រំ និង អក្ខរកម្ម

កំរិតនៃការអប់រំរបស់សមាជិកគ្រួសារ គឺជាសន្ទស្សន៍ដ៏សំខាន់នៃធនធានមនុស្សនៅក្នុងគ្រួសារ ជាពិសេស មេគ្រួសារ និងសហព័ទ្ធរបស់ពួកគេដែលតែងតែធ្វើសេចក្តីសំរេចចិត្តនៅក្នុងគ្រួសារ ។ កំរិតនៃការអប់រំអាចនឹងមានផលប៉ះពាល់ដល់ទំហំ

១ គ្រួសារដែលគ្មានដី ត្រូវបានកំនត់ដោយគំរោងសិក្សារបស់ Oxfam ថា មិនមានដីកសិកម្ម និងគ្មានមធ្យោបាយទិញដី ។
២ Biddulph (2000:11)

សមត្ថភាពដែលគ្រួសារត្រូវបំពេញសេចក្តីត្រូវការ និងគ្រប់គ្រងការលំបាកនានា ។ របាយការណ៍ខ្លះក៏បានបញ្ជាក់ថា កំរិតអប់រំរបស់មេគ្រួសារ ឬសហពទ្ធ័អាចកំណត់នូវលទ្ធភាពរបស់គ្រួសារក្នុងការរក្សាដី ។ ឧទាហរណ៍នៅក្នុងករណីសិក្សាលើភាព ក្រីក្រ និងភាពគ្មានដីនៅកំពង់រាប ខេត្តតាកែវ (Kato 1999b) រាយការណ៍ថា:

> *ចំណុចមួយដែលអ្នកភូមិរាយការណ៍ដដែលៗថា ការការពារដីពីការបាត់បង់ គឺកំរិតនៃការអប់រំ ។ សេចក្តីអះអាងរបស់ពួកគេគឺថា អ្នកដែលលក់ដីដូច្នេះ ព្រោះពួកគេមិនបានអប់រំ ហើយមិនមានទំលាប់គិតកិច្ចការ ឬធ្វើផែនការ ចំណែកឯការអប់រំវិញមិនអាចដោះស្រាយបញ្ហាបានភ្លាមៗ ក៏ពិតមែន ក៏ប៉ុន្តែយ៉ាងហោចណាស់ក៏ផ្តល់ឱកាសឱ្យកូនចៅនូវជំរើស ជាងការខ្លួនដែលគ្រាន់តែមានដី ។*

លទ្ធផលនៃការអង្កេត SES ១៩៩៧ ដែលស្របទៅនឹងការអះអាងនេះ គឺមិនសូវប្រាកដទេ ។ មួយភាគបីនៃមេគ្រួសារនៅជនបទមិនអាចអាន និងសរសេរ ទោះជាឃ្លាធម្មតានៃភាសាណាក៏ដោយ ។ ទោះជាយ៉ាងនេះក្តី គេឃើញមានអត្រាអក្ខរជនខ្ពស់នៅក្នុងចំណោមអ្នកគ្មានដី និងអ្នកមានដីច្រើនជាងមួយហិកតា (តារាង ៣.២) ។ អត្រាអក្ខរជនខ្ពស់នៅក្នុងចំណោមអ្នកគ្មានដីអាចឆ្លុះបញ្ចាំងពីការបូកបញ្ចូលនៃជំនាញជាអាជីព និងចំណេះដឹងផ្សេងទៀតរបស់ពួកគេ ។ ទោះជាយ៉ាងនេះក្តី ដោយសារការអប់រំមានសហសម្ពន្ធ័ស្របទៅនឹងអាយុ, រចនាសម្ពន្ធ័អាយុនៃក្រុមទាំងបួនអាចពន្យល់ពីភាពផ្សេងគ្នានៅក្នុងកំរិតអប់រំ ។

**តារាង ៣.២ អក្ខរកម្ម និងការអប់រំរបស់មេគ្រួសារ និងសហពទ្ធ័ តាមទំហំដី គិតជា ភាគរយ**

| មានសមត្ថភាពអាន និងសរសេរធម្មតា | គ្មានដី | >0-0.5 | >0.5-1.0 | >1.0 | មធ្យម |
|---|---|---|---|---|---|
| - មេគ្រួសារ | 68 | 63 | 62 | 69 | 65 |
| - សហពទ្ធ័ | 54 | 49 | 49 | 48 | 51 |
| ការអប់រំខ្ពស់បំផុតនៃមេគ្រួសារ | 6 | 5 | 5 | 5 | 5 |

*Source: Socio-economic Survey, NIS 1997.*

## ៣.៣ ប្រាក់ចំណូលគ្រួសារ

ប្រាក់ចំណូលគ្រួសារនៅជនបទ គឺជាតំលៃម្ហូបអាហារ និងសេវាកម្មដែលទទួលបានមកពីសកម្មភាពកសិកម្ម និងមិនមែនកសិកម្ម ថែមទាំងមានប្រភពផ្សេងៗទៀត ដូចជាប្រាក់កំរៃ ឬប្រាក់ខែ និងការធ្វើជំនួញ ។ ចំណូលផ្នែកកសិកម្មទទួលបានមកផលិតកម្មដំណាំ និងរបរផ្សេងទៀត ដូចជា ចិញ្ចឹមសត្វ រកត្រី និងប្រមែប្រមូលភោគផលពីព្រៃ ។ ការអង្កេត SES 1997 បំបែកខ្ទង់ចំណូលទាំងនេះទៅជា របរដាំដុះ និង របរកសិកម្ម (ដូចជា ការចិញ្ចឹមសត្វ រកត្រី និងភោគផលពីព្រៃ)[៣] ។ ចំណូលមិនមែនកសិកម្ម គឺជាចំណូល ដូចជា ប្រាក់កំរៃ ការធ្វើជំនួញ និងរបរមិនមែនកសិកម្មផ្សេងទៀត ។

ជាទូទៅ របរកសិកម្មត្រូវចាត់ជាប្រភពដ៏សំខាន់នៃប្រាក់ចំណូលជនបទ ។ ជាង ៨0% នៃគ្រួសារនៅជនបទមានចំណូលភាគច្រើនពីរបរនេះ រួមទាំងរកត្រី និងភោគផលពីព្រៃ ។ ៧៤% នៃមេគ្រួសារ ទទួលចំណូល ជាចំបងពីការដាំដុះ ចំណែកឯ ៧% ទទួលចំណូលជាចំបងពីរបរកសិកម្ម ដូចជា ការចិញ្ចឹមសត្វ រកត្រី និងប្រមែប្រមូលភោគផលពីព្រៃ (តារាង ៣.៣) ។

---

៣ ផលិតផលត្រី និងអនុផលព្រៃឈើ សំដៅទៅលើផលិតផលប្រមូលបានពីតំបន់ព្រៃ និងបឹងសាធារណៈ ។

**តារាង ៣.៣ ប្រភពចំណូលសំខាន់ៗនៃមេគ្រួសារ នៅក្នុង១២ខែកន្លងមក តាមទំហំដី គិតជាភាគរយ**

| ប្រភពចំណូល | គ្មានដី | >0-0.5 | >0.5-1.0 | >1.0 | មធ្យម |
|---|---|---|---|---|---|
| សកម្មភាពកសិកម្ម (ការដាំដុះ) | 20 | 81 | 82 | 84 | 74 |
| ការចិញ្ចឹមសត្វ ត្រី និង ព្រៃឈើ | 9 | 6 | 7 | 7 | 7 |
| សកម្មភាពមិនមែនកសិកម្ម | 38 | 7 | 5 | 4 | 10 |
| ប្រាក់ខែ/ប្រាក់ឧបត្ថម្ភ | 33 | 6 | 6 | 5 | 9 |

*Source: Socio-economic Survey, NIS 1997.*

គេឃើញមានភាពខុសគ្នារវាងប្រភពចំណូលរបស់អ្នកគ្មានដី ធៀបនឹងអ្នកមានដីមិនគិតពីទំហំធំឬតូចឡើយ (តារាង ៣.៣) ។ ក្នុងចំណោមកសិករ ការដាំដុះកសិកម្មផ្តល់ជាប្រភពចំណូលដ៏ធំដល់គ្រួសារប្រហែល ២០% ធៀបទៅនឹងអ្នកមានដីប្រហែល ៨០-៨៤% ។ ភាគច្រើននៃអ្នកគ្មានដីរកចំណូលពីរបរមិនមែនកសិកម្ម (៣៨%) ចំណូលបានពីប្រាក់កំរៃឬប្រាក់ខែ (៣៣%) ។ របរមិនត្រូវការដី ដូចជា ការចិញ្ចឹមសត្វ រកត្រី បេះភោគផលពីព្រៃ គឺជាប្រភពចំណូលដ៏សំខាន់សំរាប់មេគ្រួសារពី ៦-៩% ដោយមិនគិតពីទំហំដីធំឬតូច ។

សេចក្តីសន្និដ្ឋានពីរអាចទាញចេញពីតារាង ៣.៣ ។ ទីមួយ លទ្ធភាពអាចចាប់យកឱកាសការងារមិនមែនរបរកសិកម្ម និងការងារមានប្រាក់កំរៃ គឺជាកត្តាដ៏ចាំបាច់សំរាប់អ្នកគ្មានដី ។ ចំណាត់ថ្នាក់នេះ ភាពផ្សេងពីគេខ្លាំងណាស់ ។ ម្យ៉ាងវិញទៀត ពួកគេក៏មានគ្រួសាររុងរឿនមួយចំនួនដោយសារមានជំនាញខ្លះ និងអ្នកជំនួញជោគជ័យ ។ លើសពីនេះទៀត គេឃើញមានគ្រួសារ យ៉ាងច្រើនត្រូវបង្ខំចិត្តធ្វើការដែលមានកំរៃទាប ពីព្រោះពួកគេគ្មានដី ។ ទីពីរ ការពឹងពាក់ដ៏ធ្ងន់ធ្ងរទៅលើកសិកម្មរបស់គ្រួសារ អ្នកស្ទើរគ្មានដី បញ្ជាក់ថា ក្រុមនេះជាក្រុមដែលងាយរងគ្រោះបំផុត ។ ទោះជានៅក្នុងកាលទេសដ៏ប្រសើរយ៉ាងណាក៏ដោយ ក៏ដីកន្លះហិកតារមិនអាចផ្តល់ឱ្យការរស់នៅគ្រប់គ្រាន់ដែរ ។ ការពឹងពាក់លើចំណូលបានពីដីរបស់ក្រុមនេះ ក៏បង្ហាញនូវការសំលាប់ នូវឱកាសរកចំណូល និងការងារមានប្រាក់កំរៃមិនមែនកសិកម្ម ។ សេចក្តីសន្និដ្ឋានដែលអាចជាក់ច្បាស់គឺថា ចំណូលពីធនធាន សាធារណៈ គឺសំខាន់ណាស់សំរាប់គ្រួសារដែលមានដីតិច ឬគ្មានដីសោះ ។

## ៣.៤ លក្ខណៈសាងសង់ផ្ទះ និង កម្មសិទ្ធិទ្រព្យមានតំលៃ

លក្ខណៈសាងសង់ផ្ទះ និងកម្មសិទ្ធិលើទ្រព្យមានតំលៃ គឺជាសន្ទស្សន៍ដ៏សំខាន់ដែលឆ្លុះបញ្ចាំងពីទ្រព្យសម្បត្តិ និងលក្ខណៈសេដ្ឋកិច្ចសង្គមកិច្ចរបស់គ្រួសារជនបទ ។ ក្នុងនាមជាកសិករជីវព្រឹត្ត ប្រជាជនកម្ពុជាតែងតែបំពេញសេចក្តីត្រូវការប្រចាំឆ្នាំរបស់ខ្លួនសិនមុនពេលបំពេញសេចក្តីត្រូវការអ្នកដទៃ ពិសេសស្បៀងអាហារ។ នៅជនបទ ជាទូទៅពេលដែលពួកគេមានស្បៀងលើស ពួកគេតែងលក់ហើយសន្សំជាមាសសំរាប់ប្រើប្រាស់ទៅអនាគត ។ ពេលណាពួកគេសន្សំបានច្រើន ពួកគេចំណាយលើទ្រព្យផ្សេងទៀតដែលសំខាន់ និងគង់វង្សបានយូរ រួមទាំងធ្វើផ្ទះផងដែរ ។

គ្រួសារដែលធូធារតែងមានផ្ទះល្អ សង់ពីគ្រឿងដែលជាប់បានយូរជាងផ្ទះរបស់គ្រួសារក្រីក្រ ។ ប៉ុន្តែ ទំហំផ្ទះមិនជាធំណាស់ណាទេ ។ ផ្ទះគ្រួសារដែលបានអង្កេតជាទូទៅមានទំហំតូច (ប្រហែល ៣៤ម²) ហើយរវាងផ្ទះអ្នកមាន និងអ្នកក្រមានទំហំខុសគ្នាតែ ៤ម² (តារាង ៣.៤) ។

**តារាង ៣.៤ លក្ខណៈសំណង់ផ្ទះ**

| | គ្មានដី | >0-0.5 | >0.5-1.0 | >1.0 | មធ្យម |
|---|---|---|---|---|---|
| ទំហំផ្ទះគិតជា ម² | 32 | 33 | 33 | 36 | 34 |
| សំណង់ជញ្ជាំង | | | | | |
| - ប្រភេទស្បូវ ស្លឹក | 49% | 64% | 59% | 56% | 59% |
| - ក្តារ | 23% | 22% | 23% | 28% | 24% |
| - ផ្សេងៗ | 9% | 9% | 11% | 7% | 9% |
| - ឈើ | 9% | 4% | 6% | 8% | 6% |
| - ស៊ីម៉ង់ ឥដ្ឋ ថ្ម | 10% | 1% | 1% | 1% | 2% |
| សំណង់ដំបូល | | | | | |
| - ប្រភេទស្បូវ ស្លឹក | 51% | 56% | 55% | 47% | 53% |
| - ក្បឿង | 16% | 30% | 31% | 34% | 29% |
| - សង្ក័សី អាលុយមីនីញ៉ូម | 24% | 12% | 12% | 17% | 15% |
| - ហ្វិប្រូស៊ីម៉ង់ | 6% | 1% | 1% | 1% | 2% |
| - ផ្សេងៗ | 3% | 1% | 1% | 1% | 1% |
| សំណាងផ្ទៃផ្ទះ | | | | | |
| - ឈើ រនាបឬស្សី | 57% | 76% | 74% | 76% | 73% |
| - ដី | 22% | 17% | 17% | 11% | 16% |
| - parquet, ក្រាលក្តារ | 10% | 6% | 8% | 12% | 8% |
| - ស៊ីម៉ង់ | 10% | 1% | 1% | 1% | 2% |
| - ផ្សេងៗ | 1% | 0% | 0% | 0% | 1% |

*Source: Socio-economic Survey, NIS 1997.*

ស្ទើរតែបីភាគប្រាំនៃផ្ទះនៅតាមជនបទ សង់ពីឬស្សី ឬស្បូវ ឯមួយភាគប្រាំទៀតប្រើក្តារធ្វើជញ្ជាំង ។ សមាមាត្រនៃខ្ទងផ្ទះដែលសង់ពីឬស្សីជាមួយស្បូវធៀបទៅនឹងក្តារបន្ទះមិនសូវខុសគ្នារវាងក្រុមផ្សេងទៀតដែលមានដីឡើយ ។ គេអាចសំគាល់បានថា សមាមាត្រនៃគ្រួសារគ្មានដីដែលមានផ្ទះសង់ពីបេតុងហាក់ដូចជាខ្ពស់ជាងក្រុមផ្សេងទៀតយ៉ាងខ្លាំង ។ តារាង ៣.៤ បង្ហាញថា ១០% នៃគ្រួសារគ្មានដីមានផ្ទះល្អដែលសង់ពីបេតុង ឥដ្ឋ ឬថ្ម ចំណែកឯ ១% នៃក្រុមបីផ្សេងទៀតក៏មានផ្ទះដូច្នេះដែរ ។ ប្រការនេះទ្រទ្រង់បន្ថែមទៀតនូវសេចក្តីសន្និដ្ឋានដែលថា អ្នកគ្មានដីគឺរស់នៅមានលក្ខខណ្ឌផ្ទុយពីនេះ ។

សំភារៈសំណង់ដំបូលសំខាន់ៗដែលប្រើនៅជនបទ គឺស្បូវ ក្បឿង និងដែកស័ង្កសី ឬ អាលុយមីនីញ៉ូម ។ ជាងពាក់កណ្តាលនៃលំនៅដ្ឋានជនបទមានដំបូលស្បូវ ចំណែកឯបីភាគទៀតមានដំបូលក្បឿង ។ ការប្រើដំបូលក្បឿងឃើញមានជាទូទៅចំពោះសំណង់ផ្ទះអ្នកមានដីធំ ចំណែកឯដំបូលផ្ទះអ្នកគ្មានដីភាគច្រើនប្រក់ដែកសង្ក័សី ឬហ្វិប្រូស៊ីម៉ង់ (តារាង ៣.៤) ។

កម្មសិទ្ធិបច្ចុប្បន្នលើទ្រព្យសម្បត្តិគ្រួសារ ក៏មានសារៈសំខាន់សំរាប់សំគាល់ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់គ្រួសារនៅជនបទដែរ ។ ជាទូទៅ អត្រាកម្មសិទ្ធិទ្រព្យគ្រួសារមានកំរិតទាបនៅជនបទ ។ ទិន្នន័យនៅក្នុង តារាង ៣.៥ បង្ហាញថាប្រមាណ ៦០%នៃគ្រួសារនៅជនបទមានកង់ ៣៦% មានវិទ្យុ/ម៉ាញេ និង ៣៤% មានរទេះគោ ដែលធ្វើដោយខ្លួនឯងឬក្នុងភូមិ ។

**តារាង ៣.៥ កម្មសិទ្ធិទ្រព្យសម្បត្តិគ្រួសារ តាមទំហំដី គិតជាភាគរយ**

| | គ្មានដី | >0-0.5 | >0.5-1.0 | >1.0 | មធ្យម |
|---|---|---|---|---|---|
| កង់ | 53 | 55 | 63 | 70 | 60 |
| វិទ្យុ ម៉ាញេ | 32 | 30 | 38 | 47 | 36 |
| រទេះគោ | 4 | 29 | 41 | 54 | 34 |
| ម៉ូតូ | 19 | 12 | 14 | 17 | 15 |
| ទូរទស្សន៍ | 17 | 12 | 12 | 16 | 13 |
| ទូក | 10 | 7 | 9 | 13 | 9 |
| ត្រាក់ទ័រ គ្រឿងយន្តកសិកម្ម | 0 | 3 | 4 | 3 | 3 |

*Source: Socio-economic Survey, NIS 1997.*

កម្មសិទ្ធិទ្រព្យសម្បត្តិកើនតាមទំហំដីដែលបានកាន់កាប់ (តារាង ៣.៥) ។ សមាមាត្រដ៏តូចនៃគ្រួសារគ្មានដី និងគ្រួសារមានដីតូច មានកង់ វិទ្យុ/ម៉ាញេ ច្រើនជាងអ្នកមានដីធំ ។ ៤% នៃគ្រួសារគ្មានដី មានរទេះគោ ដែលត្រូវបានប្រើនៅក្នុងរបរកសិកម្ម ។ កំលាំងអូសទាញឃើញមាននៅក្នុងចំណោមគ្រួសារគ្មានដី តិចជាងគ្រួសារមានដី ចំណែកឯកគ្រួសារមួយចំនួនតូចនៅគ្រប់ចំណាត់ថ្នាក់មានត្រាក់ទ័រ ឬគ្រឿងយន្តកសិកម្មផ្សេងៗទៀត ។ ដូចដែលគេរំពឹងទុកថា ការកាន់កាប់ទ្រព្យដែលមានតំលៃខ្ពស់ ដូចជា ម៉ូតូ ទូរទស្សន៍ មានចំនួនកាន់តែកើនឡើងនៅក្នុងគ្រួសារមានដី ។ ទោះជាយ៉ាងនេះក្តី ទ្រព្យមានតំលៃទាំងនេះ ក៏ឃើញមាននៅតាមក្រុមគ្រួសារដែលគ្មានដីខ្លះៗ ដែលបញ្ជាក់ថា ពួកគេមិនមែនសុទ្ធតែអ្នកក្រទាំងអស់ទេ ។ ក្នុងករណី ខ្លះដែលពួកគេមានម៉ូតូ ឬរ៉ឺម៉ក ពួគេប្រើប្រាស់ដើម្បីរកចំណូល ដូចជារត់ម៉ូតូឌុប ដែលជារបរទូទៅនៅជនបទ ។ ហេតុផល ប្រហាក់ប្រហែលគ្នានេះដែរ ចំពោះអ្នកមានទូក ១០% ត្រូវបានប្រើប្រាស់ដើម្បីរកត្រីដែលជាប្រភពចំណូលមួយដែរ ។

## ៣.៥ ការកាន់កាប់សត្វពាហនៈ

ការចិញ្ចឹមសត្វ គឺជាផ្នែកមួយនៃប្រព័ន្ធកសិកម្មចំរុះ ហើយសត្វស្រុក គឺជាទ្រព្យសំខាន់សំរាប់គ្រួសារនៅជនបទ ។ សត្វផ្សេងគ្នាតែងមានប្រយោជន៍ផ្សេងគ្នាសំរាប់ជីវភាពរស់នៅតាមជនបទ ។ ជាទូទៅ គោក្របីត្រូវប្រើប្រាស់ជាកំលាំងអូសទាញសំរាប់រៀបចំដី ឬដឹកជញ្ជូន ។ យូរៗម្តងពួកវាត្រូវគេលក់យកប្រាក់មកដោះស្រាយបញ្ហា និងធ្វើម្ហូបពេលពួកវាលែងប្រើការបាននៅក្នុងរបរកសិកម្ម ។ ការចិញ្ចឹមជ្រូកមាន់ទានៅតាមផ្ទះ ក៏ជាប្រភពប្រាក់ចំណូលមួយរបស់គ្រួសារភាគច្រើននៅតាមជនបទ ។ ជ្រូកជាសត្វដែលចិញ្ចឹមសំរាប់យកកូនលក់ហើយមិនសូវប្រើប្រាស់ធ្វើជាម្ហូបទេ ចំណែកឯមាន់ទាត្រូវគេចិញ្ចឹមយកសាច់ និងស៊ុត ហើយក៏មានលក់ដើម្បីយកចំណូលដែរ ។

ទោះជាយ៉ាងនេះក្តី ៨៦% នៃទំហំប៉ាន់គំរូរាយការណ៍ថា មានចិញ្ចឹមសត្វ ។ ក៏រិតនៃកម្មសិទ្ធិគោក្របី ដែលជាកំលាំងអូសទាញប្រែប្រួលជាដុំកំភួនទៅតាមក្រុមអ្នកមានដី ។ អត្រាកម្មសិទ្ធិកើនទៅតាមទំហំដីកាន់កាប់ ។ អត្រាកម្មសិទ្ធិគោកើនពី ១១% នៅក្នុងគ្រួសារគ្មានដីទៅ ៦៦% នៅក្នុងគ្រួសារអ្នកមានដីច្រើន ។ អត្រាគ្រួសារកាន់កាប់ក្របីមានប្រហាក់ប្រហែលគ្នាចំពោះគ្រួសារគ្មានដី និងគ្រួសារមានដីតាមសមាមាត្រ ២% និង ២២% រៀងគ្នា (តារាង ៣.៦) ។ គំរូនេះបញ្ជាក់ថា គ្រួសារគ្មានដី និងគ្រួសារមានដីតូចមានជីវភាពក្រពេកមិនអាចចិញ្ចឹមក្របី ដោយពួកគេគិតថា សត្វទាំងនេះមិនសំខាន់ចំពោះជីវិតប្រចាំថ្ងៃរបស់ពួកគេ ។

មិនត្រឹមតែមានអត្រាកម្មសិទ្ធិគោក្របីទាបចំពោះគ្រួសារគ្មានដី និងគ្រួសារមានដីតូចប៉ុណ្ណោះទេ ចំនួនមធ្យមនៃសត្វទាំងនោះក៏ទាបដែរ ។ តារាង ៣.៦ បញ្ជាក់ថា គ្រួសារគ្មានដីមានគោមួយក្បាលជាមធ្យម ចំណែកគ្រួសារមានដីមានគោ ២-៣ក្បាល ។ គ្រួសារគ្មានដី និងគ្រួសារមានដី ចិញ្ចឹមក្របី ជាមធ្យមសូន្យ និង ១-២ ក្បាលរៀងគ្នា ។

ការចិញ្ចឹមជ្រូក និងសត្វស្លាប គឺមានលក្ខណៈទូលំទូលាយជាង ។ ជាមធ្យម ៥៨% នៃគ្រួសារដែលបានសំភាសន៍មានជ្រូក និង ៦៧% មានមាន់ ។ អត្រាគ្រួសារមានជ្រូកកើនពី ៣១% ក្នុងចំណោមគ្រួសារគ្មានដីទៅ ៦៥% និង ៤១% ក្នុងចំណោមគ្រួសារមានដីមធ្យម និងធំរៀងគ្នា ។ ការចិញ្ចឹមសត្វស្លាបមាន ៤១%នៃគ្រួសារគ្មានដីទៅ ៧៦%នៃគ្រួសារមានដីធំ ។

**តារាង ៣.៦ ការចិញ្ចឹមសត្វពាហនៈ តាមទំហំដី**

| | គ្មានដី | >0-0.5 | >0.5-1.0 | >1.0 | មធ្យម |
|---|---|---|---|---|---|
| សត្វចិញ្ចឹមដោយខ្លួនឯង | 55% | 88% | 92% | 96% | 86% |
| - សត្វពាហនៈចិញ្ចឹមដោយខ្លួនឯង | 11% | 54% | 65% | 66% | 54% |
| - ចំនួនមធ្យមនៃសត្វពាហនៈក្នុងមួយគ្រួសារ | 1 | 2 | 2 | 3 | 2 |
| - ក្របីចិញ្ចឹមដោយខ្លួនឯង | 2% | 10% | 14% | 22% | 13% |
| - ចំនួនមធ្យមនៃក្របីក្នុងមួយគ្រួសារ | 0 | 1 | 1 | 2 | 1 |
| - ជ្រូកចិញ្ចឹមដោយខ្លួនឯង | 31% | 55% | 65% | 41% | 58% |
| - ចំនួនមធ្យមនៃជ្រូកក្នុងមួយគ្រួសារ | 1 | 1 | 2 | 2 | 2 |
| - មាន់ចិញ្ចឹមដោយខ្លួនឯង | 41% | 67% | 74% | 76% | 67% |
| - ចំនួនមធ្យមនៃមាន់ក្នុងមួយគ្រួសារ | 5 | 7 | 9 | 10 | 8 |

*Source: Socio-economic Survey, NIS 1997.*

ចំនួនមធ្យមនៃជ្រូក និងសត្វស្លាបដែលគ្រួសារមានដីចិញ្ចឹមមានបរិមាណខុសគ្នាយ៉ាងខ្លាំង ។ គ្រួសារគ្មានដី និងគ្រួសារមានដីតូចមានជ្រូកជាមធ្យមតែមួយ និងក្រុមគ្រួសារមានដីមានជ្រូកដល់ទៅពីរ ។ ប្រហាក់ប្រហែលគ្នានេះដែរ ចំនួនមធ្យមនៃសត្វស្លាបចិញ្ចឹមដោយគ្រួសារគ្មានដី និងគ្រួសារមានដីតូច តិចជាងគ្រួសារមានដីច្រើន ។ សហសម្ពន្ធ៍វិជ្ជាមានរវាងការកាន់កាប់ដី និងការចិញ្ចឹមសត្វ បង្ហាញថា ការចិញ្ចឹមសត្វ មិនមែនជាចំលើយទៅនឹងភាពខ្វះខាតដីទេ ។

## ៣.៦ ឥណទាន

ការខ្ចីប្រាក់ ឬជាឥវ៉ាន់ គឺមានការអនុវត្តន៍ជាទូទៅក្នុងកំឡុងពេលខ្វះខាតនៅតាមជនបទ ។ ការអង្កេតបានរាយការណ៍ថា ពីរភាគប្រាំនៃគ្រួសារនៅតាមជនបទ មានកំចីយ៉ាងហោចណាស់មួយលើក ជាសាច់ប្រាក់ ឬឥវ៉ាន់ ។ តារាង ៣.៧ បង្ហាញថា ឧប្បត្តិហេតុនៃការខ្ចីប្រាក់ក្នុងចំណោមគ្រួសារគ្មានដី និងគ្រួសារមានដីតូច គឺខ្ពស់ជាងគ្រួសារមានដី ។ ប្រហែល ៤០%នៃគ្រួសារគ្មានដី និងគ្រួសារមានដីតូចមានកំចី ហើយត្រឹមតែ ៣៥% នៃគ្រួសារមានដីរាយការណ៍ថា ក៏ធ្លាប់បានខ្ចីប្រាក់គេដែរ ។

ចំនួនមធ្យមនៃប្រាក់ខ្ចីគេប្រែប្រួលទៅតាមក្រុមគ្រួសារមានដីចាប់ពី ០,៣លានរៀល ទៅជាង ០,៥លានរៀល ក្នុងមួយកំចី ។ ចំនួនមធ្យមនៃកំចីរបស់គ្រួសារនីមួយៗ ប្រហែល ០,៤លានរៀល ក្នុងកំចីលើកទីមួយ និងក្រោម ០,៣លានរៀល សំរាប់កំចីលើកទីពីរ ។ ប្រាក់ដែលខ្ចីដោយគ្រួសារគ្មានដី និងគ្រួសារមានដីតូច មានចំនួនមធ្យមច្រើនជាងប្រាក់កំចីដោយគ្រួសារមានដីច្រើន ។ កំចីមធ្យមរបស់គ្រួសារគ្មានដីមានជិត ០,៥លានរៀល ចំណែកឯកំចីមធ្យមដោយគ្រួសារមានដីច្រើនមានត្រឹមតែ

០,៣លានរៀល ។

NGOs ឧបត្ថម្ភជំនួយដោយទាយកអន្តរជាតិ បានដាក់ឱ្យប្រើប្រាស់សេវាមីក្រូឥណទានក្នុងកំរិតគ្រួសារនៅឆ្នាំ១៩៨៩ ដើម្បីជួយអ្នកក្រ ។ ដើម្បីពង្រីកសេវានេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឱ្យមានមីក្រូហិរញ្ញវត្ថុ ដោយបង្កើតឱ្យមានគណកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទនៅក្នុងឆ្នាំ១៩៩៥ ដែលនាំឱ្យបង្កើតធនាគារអភិវឌ្ឍន៍ជជនបទនៅក្នុងឆ្នាំ១៩៩៨ ។ ទោះជាយ៉ាងនេះក្តី សេវាកម្មនេះមិនឈានដល់ក្រុមគោលដៅនៅឡើយទេ ហើយប្រពន្ធ័ឥណទានជាផ្លូវការនៅតែដំណើរការនៅក្នុងជនបទដដែល ។ ការអង្កេតរបស់ NIS រាយការណ៍ថា ភាគច្រើននៃអ្នកក្រមិនដែលលឺ ឬអាចប្រើប្រាស់ឥណទានផ្លូវការឡើយ ។ នៅគ្រប់ក្រុមទាំងអស់ប្រហែលជា ៩០% ខ្ចីប្រាក់ពីប្រភពមិនផ្លូវការណ៍ (ញាតិ មិត្តភក្រ័ អ្នកចងការប្រាក់ និងអ្នកជំនួញ) ឯសេវាឥណទានផ្លូវការណ៍ (NGOs) មាន ១០% នៃអ្នកខ្ចីនៅជនបទ (តារាង ៣.៧) ។

**តារាង ៣.៧ កំចីតាមទំហំដី**

| | ភាពគ្មានដី | >0-0.5 | >0.5-1.0 | >1.0 | មធ្យម |
|---|---|---|---|---|---|
| - គ្រួសារមានកំចី | 41% | 42% | 36% | 36% | 39% |
| - កំចី មួយដង | 39% | 41% | 34% | 35% | 38% |
| - កំចី ពីរដង | 2% | 1% | 1% | 1% | 1% |
| បរិមាណមធ្យមដែលខ្ចីម្តងៗ | | | | | |
| - កំចីលើកទី ១ ជា រៀល | 466,000 | 381,000 | 324,000 | 321,000 | 367,000 |
| - កំចីលើកទី ២ ជា រៀល | 324,000 | 284,000 | 259,000 | 183,000 | 270,000 |
| ប្រភពនៃកំចីលើកទី ១ | | | | | |
| - មិត្តភក្រ័ | 54% | 62% | 65% | 57% | 61% |
| - អ្នកចងការប្រាក់ | 30% | 20% | 17% | 18% | 20% |
| - អ្នកជំនួញ | 9% | 5% | 5% | 5% | 6% |
| - NGOs | 5% | 11% | 11% | 17% | 11% |
| - ប្រភពផ្សេងទៀតរួមទាំងធនាគារ | 2% | 2% | 2% | 3% | 2% |
| គោលបំណងដំបូងនៃកំចីលើកទីមួយ | | | | | |
| - ប្រើប្រាស់ក្នុងគ្រួសារធម្មតា | 32% | 28% | 28% | 20% | 27% |
| - ផលិតកម្មកសិកម្ម | 7% | 26% | 27% | 38% | 26% |
| - សេចក្តីត្រូវការបន្ទាន់ (មរណភាព និងជំងឺ) | 21% | 18% | 20% | 17% | 18% |
| - វិនិយោគក្នុងជំនួញ | 18% | 6% | 7% | 5% | 8% |
| - ទិញ ឬកែលំអផ្ទះ | 5% | 10% | 10% | 7% | 8% |
| - ទិញរបស់មានតំលៃ ឬជាប់បានយូរ | 4% | 4% | 3% | 4% | 4% |
| - អាពាហពិពាហណ៍ ឬពិធីផ្សេងៗ | 1% | 2% | 1% | 4% | 2% |
| - ផ្សេងៗ | 13% | 7% | 5% | 7% | 7% |

*Source: Socio-economic Survey, NIS 1997.*

ការពិនិត្យឱ្យល្អិតល្អន់ទៅលើប្រភពឥណទានបង្ហាញថា ប្រភពឥណទានសំខាន់នៃកំចីនៅជនបទគឺ ញាតិ/មិត្ត ។ យោលទៅតាមអង្កេត NIS ជាង ៦០% នៃគ្រួសារនៅជនបទខ្ចីប្រាក់ពីញាតិ ឬមិត្ត ប្រហែលនៅក្នុងកំរិតការប្រាក់ទាប ។ ការសិក្សាពីសន្តិសុខស្បៀងមួយរបស់ Murshid ទៅលើភូមិបីនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៦-៩៧ រាយការណ៍ថា "មានការខ្ចីគ្នា

ដោយគ្មានការប្រាក់ពីញាតិដែលជិតបំផុត " (Murshid 1998:46) ។ ប្រភពកំចីដ៏សំខាន់ផ្សេងទៀតគឺ អ្នករកស៊ីចងការប្រាក់ និងអ្នកជំនួញ ដែលផ្តល់កំចីមានការប្រាក់ខ្ពស់ ។ Murshid គណនាឃើញថា អត្រាការប្រាក់ប្រចាំឆ្នាំនៃកំចីនៅជនបទពីអ្នករកស៊ីចងការប្រាក់ និងអ្នកជំនួញនៅក្នុងភូមិទាំងបី គឺ ១០០% ។ ប្រភពកំចីផ្សេងទៀតគឺធនាគាររដ្ឋាភិបាល និយោជក និងប្រភពផ្សេងទៀត ។ ពួកគេផ្តល់កំចី ដល់ ២% នៃអ្នកខ្ចីនៅជនបទ ។

អត្រាការប្រាក់មានកំរិតខុសគ្នាពីក្រុមមួយទៅក្រុមមួយ ។ វាមានអត្រាខ្ពស់ចំពោះគ្រួសារគ្មានដី និងគ្រួសារមានដីតូចជាងគ្រួសារមានដី ។ ការពិតទៅ នេះប្រហែលជាគ្រួសារគ្មានដី និងគ្រួសារមានដីតូច ត្រូវបានដកចេញពីប្រពន្ធ័ឥណទានផ្លូវការ ផ្តល់ដោយ NGOs ដែលផ្តល់កំចីតូចៗ ក្នុងកំរិតការប្រាក់ ៤-៥% ក្នុងមួយខែ ដល់អ្នកខ្ចីមួយចំនួនធំនៅជនបទ ។ ទោះបីជា NGOs ផ្តល់កំចី ១១% ដល់អ្នកខ្ចីនៅជនបទគ្រួសារគ្មានដីតែ ៥% ប៉ុណ្ណោះរាយការណ៍ថា អាចទទួលបានកំចីនេះ ។ អត្រាលទ្ធភាពប្រើប្រាស់កំចី NGOs កើនឡើងពី ៥% ក្នុងចំណោមគ្រួសារគ្មានដីទៅ ១០% ក្នុងចំណោមគ្រួសារមានដីតិចជាង ១ហត និងកើនរហូតដល់ ១៧% ក្នុងចំណោមគ្រួសារមានដីជាង ១ហត ។

គោលបំណងសំខាន់ចំពោះកំចី គឺដើម្បីបំពេញសេចក្តីត្រូវការប្រើប្រាស់ធម្មតា គឺទិញស្រូវអង្ករ និងដើម្បីវិនិយោគលើទុនកសិកម្ម ។ ជាមធ្យម អត្រាប្រហែល ៣០% នៃអ្នកខ្ចីបានយកកំចីទៅបំពេញសេចក្តីប្រើប្រាស់ធម្មតាក្នុងគ្រួសារ ។ ដោយហេតុថា ផលិតផលកសិកម្មត្រូវបានកំណត់ដោយលក្ខខណ្ឌអាកាសធាតុ វាប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយ ឬពីតំបន់មួយទៅតំបន់ មួយ ។ ជាលទ្ធផល អសន្តិសុខស្បៀងកើតឡើងនៅភាគខ្លះនៃប្រទេសជារៀងរាល់ឆ្នាំ ទោះជាគេរាយការណ៍ថា មានផលស្រូវ អង្ករលើសនៅកំរិតជាតិក្តី ។ ដើម្បីទបទល់នឹងការខ្វះខាតស្បៀងគ្រួសារជនបទខ្ចីគេជាប្រាក់ ឬជាស្រូវ/អង្ករ នៅពេលខ្វះខាត ហើយសងកំចីវិញនៅពេលច្រូតកាត់ ។ ស្ថានការណ៍នេះកាន់តែយ៉ាប់ជាងនេះទៅទៀត ចំពោះគ្រួសារគ្មានដីដើម្បីផលិតស្បៀង ឬក៏មានដីតិចពេកមិនអាចផលិតឱ្យគ្រប់គ្រាន់សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ។ តារាង ៣.៧ បង្ហាញថា ប្រហែល ៣០% នៃអ្នកខ្ចីដែលជាគ្រួសារគ្មានដី និងគ្រួសារមានដីតូច ខ្ចីប្រាក់ដើម្បីទប់ទល់ការប្រើប្រាស់ជាប្រចាំ ធៀបទៅនឹង ២០% ចំពោះអ្នកដែលមានដីមធ្យម និងដីច្រើន ។

ប្រហែល ២៦% នៃអ្នកខ្ចីនៅជនបទរាយការណ៍ថា កំចីរបស់ខ្លួនត្រូវបានប្រើប្រាស់ក្នុងការវិនិយោគទុនកសិកម្មដើម្បីបង្កើនផលិតភាព ។ ប្រភេទនៃកំចីនេះប្រែប្រួលពីក្រុមមួយទៅក្រុមមួយ ។ ភាគរយនៃការខ្ចីសំរាប់របរកសិកម្មមានអត្រាខ្ពស់រហូតដល់ ៣៨% ក្នុងចំណោមអ្នកខ្ចីដែលលជាគ្រួសារមានដីច្រើន និងថយទៅ ៧% ចំពោះគ្រួសារគ្មានដី (តារាង ៣.៧) ។ ទោះជាយ៉ាងនេះក្តីគ្រួសារគ្មានដី ហាក់ដូចជាខ្ចីប្រាក់ដើម្បីវិនិយោគក្នុងជំនួញ ដោយហេតុថាពួកគេគ្មានដីសំរាប់ដាំដុះ ។ ប្រហែល ២០% នៃកំចីទទួលដោយគ្រួសារគ្មានដីត្រូវបានប្រើប្រាស់ដើម្បីជំនួញ ចំណែកគ្រួសារអ្នកមានដី ៥% ទៀតក៏ប្រើប្រាស់កំចីដើម្បី វិនិយោគលើជំនួញដែរ ។

ការខ្ចីប្រាក់ដើម្បីទប់ទល់នឹងវិបត្តិធ្ងន់ៗ និងមិនបានរំពឹងជាមុនដូចជា មរណភាពនៃសមាជិកក្នុងគ្រួសារ និងជំងឺ ក៏កើតមានជាទូទៅនៅជនបទដែរ ។ កំចី ២០% ត្រូវបានប្រើនៅក្នុងគោលបំណងនេះ ហើយឧប្បត្តិហេតុនៃការខ្ចីប្រភេទនេះមានភាពខុសគ្នាតិចតួចពីក្រុមមួយទៅក្រុមមួយនៅក្នុងក្រុមមានដី ។

## ៣.៧ មូលហេតុនៃភាពគ្មានដី

ទិន្នន័យពីភាពគ្មានដីថ្នាក់ជាតិនៅកម្ពុជាមិនទាន់មានល្អិតល្អន់ទេ ។ ទោះជាយ៉ាងនេះក្តី ការសិក្សាជាច្រើនបានបញ្ជាក់ថា ភាពគ្មានដីបានកើនយ៉ាងលឿននៅទសវត្សន៍ចុងក្រោយនេះ ហើយវាមានផលប៉ះពាល់យ៉ាងធំធេងទៅលើសុខមាលភាពសង្គម ក៏ដូចជាស្ថានភាពនយោបាយ និងសេដ្ឋកិច្ចនៅក្នុងប្រទេសដែរ ។ ថ្វីបើការសិក្សាផ្សេងគ្នាបញ្ជាក់ពីមូលហេតុផ្សេងគ្នានៃភាពគ្មានដី ក៏មានមូលហេតុទូទៅមួយចំនួនដែលបណ្តាលឱ្យមានភាពគ្មានដីនៅក្នុងចំណោមគ្រួសារជនបទ ។

បន្សំគ្នារវាងកំណើនប្រជាជនដ៏ឆាប់រហ័ស និងកង្វះប្រព័ន្ធបែងចែកដីដែលសមស្រប គឺជាមូលហេតុមួយ ក្នុងចំណោមមូលហេតុដ៏ធំធេងនានាដែលបណ្តាលឱ្យមានភាពគ្មានដីនៅកម្ពុជា ។ ដូចបានជំរាបពីខាងដើម គឺការបែងចែកដីឡើងវិញមានកើតឡើងនៅក្នុងក្នុងទសវត្សន៍ឆ្នាំ ១៩៨០ ។ គ្រួសារភាគច្រើននៅពេលនោះទទួលបានដីតាមចំណែក ថ្វីបើបរិមាណមានការប្រែប្រួលពីគ្រួសារមួយទៅគ្រួសារមួយក្តី ។ នៅភាគខ្លះនៃប្រទេសដែលមានដីច្រើន និងរបាយប្រជាជនតិចគ្រួសារខ្លះបានទទួលដីរហូតដល់ទៅ ២-៣ហត ឯកន្លែងខ្លះទៀតទទួល បានត្រឹមតែ ១ហត ប៉ុណ្ណោះ ។ ការបែងចែកធនធានដីដែលមានកំរិតដើម្បីជួយគ្រួសារដែលទើបរៀបការថ្មី ក៏នាំឱ្យមានការកាត់ចំណែក ដីដែលមានឱ្យទៅជាឡូដ៍តូចៗ ដែលមិនអាចផ្គត់ផ្គង់គ្រួសារថ្មីៗ នេះបានទៀតផង ។ ចាប់តាំងពីពេលនោះមក ជំហាននៃភាពគ្មានដីបានចាប់ផ្តើមឡើង ។ ធនាគារពិភពលោក (២០០០:២៣) លើកជាឧទាហរណ៍នៃដំណើរការនេះនៅក្នុងការពណ៌នាមួយស្តីពីរបៀបដែលស្ត្រីឈ្មោះ ឈឺន សុភា អាយុ ៦១ឆ្នាំ ក្លាយជាអ្នកគ្មានដី ដូចតទៅ:

> *នៅចុងឆ្នាំ១៩៨២ គាត់មានដី ៦ហត ពីមេឃុំ សំរាប់គ្រួសារគាត់ដែលមានកូន ៦នាក់ ។ ចាប់ផ្តើមនៅឆ្នាំ១៩៨៨ កូនគាត់រៀបការ និងរស់នៅផ្ទះដោយឡែក ។ គាត់បានចែកដីជាចុងក្រោយ ទៅឱ្យកូនប្រុសស្រី ដែលរៀបការនៅឆ្នាំ១៩៩៦ ។ គាត់បានចែកដីគាត់អស់ឱ្យទៅកូន ។ គាត់មានប្រសាសន៍ថែមទៀតថា ដោយគ្មានដីបន្ថែមពីលើចំណែក គាត់បានចែកកូនរបស់គាត់ទាំងអស់រំពឹងតែលើបំណែកដី ដ៏តូចទាំងនោះដើម្បីចិញ្ចឹមជីវិតដែលលំបាកខ្លាំងណាស់សំរាប់ពួកគេ ។*

Kato (1999b:13) បង្ហាញថា ៨គ្រួសារ ក្នុងចំណោម ២៦គ្រួសារ នៅភូមិកំពង់រាប គឺជាគ្រួសារគ្មានដី ពីព្រោះពួកគេទើបរៀបការថ្មីៗ ហើយឪពុកម្តាយរបស់គេមិនមានដីគ្រប់គ្រាន់សំរាប់ចែកឱ្យ ។ ការសិក្សារបស់ Oxfam GB LADIT បញ្ជាក់ថា ៥០% នៃគ្រួសារគ្មានដី គឺជាអ្នកដែលមិនធ្លាប់មានដីពីមុន ដោយសារតែពួកគេទើបរៀបការថ្មី ហើយឪពុកម្តាយមិនមានដីគ្រប់គ្រាន់សំរាប់ចែកឱ្យ ។

ការមិនមានជំរកនៅក្នុងប្រទេសដោយសារអសន្តិសុខ គឺជាមូលហេតុមួយនៃភាពគ្មានដី ។ ដោយសារប្រទេសកម្ពុជាឆ្លង កាត់សង្គ្រាមស៊ីវិលជាងពីរទសវត្សន៍ និងការកាត់ផ្តាច់ពីអន្តរជាតិចាប់ពីឆ្នាំ១៩៧០ រហូតដល់ ១៩៨៩ ប្រជាជនភាគច្រើនមិនមានជំរកយ៉ាងហោចណាស់ម្តងដែរ ។ តាំងពីរបបខ្មែរក្រហមដួលរលំនៅក្នុងឆ្នាំ១៩៧៩ ប្រជាជនភាគច្រើនត្រឡប់ទៅភូមិឋានជួបជុំគ្រួសារវិញ ចំណែកឯអ្នកខ្លះធ្វើដំណើរទៅព្រំដែនខ្មែរថៃស្វែងរកជំរកនៅប្រទេសផ្សេងទៀត ។ អ្នកដែលបានទៅដល់ប្រទេសទីបី មានតែមួយចំនួនតូចប៉ុណ្ណោះ ចំណែកអ្នកនៅសល់ត្រូវរស់នៅក្នុងជំរុំរហូតដល់ការធ្វើមាតុភូមិនិវត្តន៍ នៅឆ្នាំ

១៩៩៣ ។ តាមប្រមើលទៅ ជនភាសន៍ខ្លួននៅឆ្នាំ ១៩៩៣ ត្រូវបាត់បង់ឱកាសទទួលយកដីក្នុងពេលបែងចែកជាថ្មីនៅឆ្នាំ ១៩៨០ ទោះបីជាអ្នកដែលមានដីច្រើនមុនឆ្នាំ ១៩៧០ ក៏ដោយ ។

ជនមាតុភូមិនិវត្តន៍មួយចំនួន ដែលរដ្ឋបានចែកដីឱ្យកាលពីពេលមកដល់ក្នុងឆ្នាំ១៩៩៣ ក៏ងាយនឹងបាត់បង់ដី ហើយក្លាយជាអ្នកគ្មានដីក្នុងមូលហេតុពីរយ៉ាង ។ ទីមួយ មនុស្សមួយចំនួនដែលគេចោទថា ចូលដៃជាមួយរដ្ឋអំណាចមូលដ្ឋាន បានមកយកដីពីពួកជនមាតុភូមិនិវត្តដែលគេបានទទួល ។ ទីពីរ ពួកគេត្រូវបានផ្តល់ដីដែលគ្មានអ្នកណាត្រូវការដោយសារកន្លែងមិនល្អ គ្មានហេដ្ឋារចនាសម្ពន្ធ័ បរិដ្ឋានមិនល្អ ឬក៏ផលិតភាពទាប ។

អ្នកដែលគ្មានជំរកក្នុងប្រទេស ក៏ជាអ្នកដែលងាយរងគ្រោះនៃការបាត់បង់ដីដែរ ។ ការវាយប្រហារគ្នា នៅឆ្នាំ១៩៩៧ បានបង្ខំឱ្យប្រជាជនភាគច្រើននៅតំបន់ខ្លះនៃខេត្តភាគពាយព្យបាត់ដំបង ឧត្តរមានជ័យ បន្ទាយមានជ័យ សៀមរាប និងពោធិសាត់ បានចាកចោលផ្ទះ និងស្រែចំការ ។

អ្នកគ្មានជំរកនៅក្នុងប្រទេស ជាអ្នកងាយរងគ្រោះ ដោយសារការគ្មានលិខិតស្នាមកម្មសិទ្ធិស្របច្បាប់នៅជនបទ ។ នៅពេលពួកគេត្រឡប់មកវិញបន្ទាប់ពីការបង្កើតរដ្ឋាភិបាលចំរុះនៅក្នុងឆ្នាំ១៩៩៨ ពួកគេមិនអាចទាមទារដីវិញបានទេ ដោយសារមានអ្នកផ្សេងមកកាន់កាប់ ។ ជំលោះដីធ្លីទាំងនោះមិនទាន់ដោះស្រាយចេញនៅឡើយ ។ ការគៀបសង្កត់យកដីក៏ជាហេតុផលទូទៅមួយនៅពីក្រោយការបាត់បង់ដីក្នុងចំណោមគ្រួសារគ្មានអំណាច និងគ្រួសារជនបទកម្ពុជា ។ ដោយសារតែគ្រួសារមួយចំនួនតូចមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ បញ្ហានេះបានកើនចំនួននៅទសវត្សន៍ចុងក្រោយនេះ ។ ការរំលោភយកដី គឺតែងតែធ្វើឡើងដោយអ្នកមានអំណាចតាមសកម្មភាពស្របច្បាប់ ។ ការរំលោភយកដីបានឈានទៅរកជំលោះ ដែលជាបញ្ហាមួយនៅក្នុងអភិបាលកិច្ចនៅកម្ពុជា ។ មនុស្សភាគច្រើន និងរដ្ឋាភិបាលទទួលស្គាល់ថា ការគៀបយកដីបានរីកសាយ ហើយកើតឡើងទូទាំងខេត្តនៅកម្ពុជា ចាប់តាំងពីការរៀបចំឱ្យមានឡើងវិញនូវកម្មសិទ្ធិដីឯកជន និងការកកើតឡើងនូវទីផ្សារដីធ្លី ។ នាយករដ្ឋមន្ត្រីក៏បានទទួលស្គាល់បញ្ហារំលោភយកដីនៅចំពោះមុខសាធារណៈដែរ ហើយកាលពីខែកញ្ញា ១៩៩៩ សម្តេចបានចេញបទបញ្ជាបញ្ឈប់ការចាប់យកដីអនាធិបតេយ្យ ។ សម្តេចក៏បានចេញអនុក្រិត្យលប់ចោលសិទ្ធិលក់ដីរដ្ឋដោយមន្ត្រីខេត្ត ។ ទោះជាយ៉ាងនេះក្តី បញ្ហានេះនៅតែកើតឡើងហើយអ្នកក្រីក្រនៅតែបន្តបាត់បង់ដី ។ គេរំពឹងថា ច្បាប់កែសំរួលថ្មីលើច្បាប់ដីធ្លី ដែលកំពុងពិនិត្យមើលដោយគណកម្មាធិការអន្តរក្រសួងនឹងអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រីនៅដើមខែឧសភា ឆ្នាំ ២០០០ ។ គេសង្ឃឹមថា នឹងអាចជួយការពារដីដែលជាកម្មសិទ្ធិរបស់អ្នកក្រ ។

ការលក់ដោយបង្ខំចិត្តកើតមានឡើងនៅពេលដែលគ្រួសារត្រូវការលក់ទ្រព្យសម្បត្តិក្នុងពេលមានវិបត្តិធ្ងន់ធ្ងរ គឺជាបញ្ហាជាទូទៅដែលនាំឱ្យបាត់បង់ដី ។ ការបង្ខំចិត្តលក់កើតមានដោយសារកត្តាជាច្រើនដូចជា ជំងឺ គ្រោះថ្នាក់ចរាចរ គ្រោះធម្មជាតិ ខ្វះស្បៀង និងខ្វះប្រពន្ធ័ឥណទាន ។ អ្នកក្រនៅជនបទងាយឆ្លងជំងឺ ដោយសារតែរស់នៅក្នុងលក្ខខណ្ឌអនាមយមិនល្អ ហើយមានលទ្ធភាពប្រើប្រាស់សេវាសាធារណៈតិចតួច ។ Murshid (1998) សង្កេតឃើញថា ៤០-៥០% នៃគ្រួសារនៅក្នុងប៉ាន់គំរូនៃការអង្កេតសន្តិសុខស្បៀងតាមភូមិបី នៅឆ្នាំ១៩៩៦-៩៧ បានរាយការណ៍ថា មានអ្នកឈឺពេញមួយឆ្នាំកាលពីឆ្នាំកន្លងទៅ ។ ទោះបីជាចំណាយសុខភាព និងជំងឺរបស់អ្នកក្រមិនអាចប៉ាន់ស្មានបាននៅក្នុងចំណាយគ្រួសារក៏ដោយ ក៏វាជាលទ្ធផលនៃការចំណាយមិនបានរំពឹងទុកលើសុខភាព និងការបាត់បង់ចំណូលដែលបានសន្សំទុក ។

សមត្ថភាពដើម្បីឆ្លើយតបទៅនឹងវិបត្តិទាំងនេះ រំពឹងតែទៅលើធនធានរបស់គ្រួសារ ដោយមិនគិតពីទីកន្លែងដែលគេចាប់ផ្តើម ។ គ្រួសារដែលមានជីវភាពធូធារអាចប្រើប្រាក់សន្សំរបស់ពួកគេ ឬពឹងពាក់មិត្តភ័ក្រ្ត ឬញាតិសណ្តានរបស់ពួកគេ ។ គ្រួសារក្រីក្រដែលគ្មានប្រាក់សន្សំ និងមានចំណូលតិចតែងតែខ្ចីបុលគេក្នុងកំរិតការប្រាក់ខ្ពស់ ហើយតែងតែដាក់របស់មានតំលៃធានា ។ ពួកគេតែងតែសងបំណុលវិញ នៅកំឡុងរដូវប្រមូលផលចំពេលដែលផលិតផលកសិកម្មរបស់ពួកគេលក់បានថោក ។ ដោយពួកគេមានដីតិចជានិច្ចកាលពួកគេ មិនអាចផលិតគ្រប់ដើម្បីសងបំណុលគេម្តងឡើយ ហើយតែងតែលក់ផលិតផលស្ទើរតែទាំងអស់ ហើយក្រោយមកពួកគេក៏ខ្ចីបុលគេក្នុងកំរិតការប្រាក់ខ្ពស់ដោយសារគេខ្វះស្បៀងដដែល ។ ដូច្នេះពួកគេរស់នៅក្នុងរង្វង់បំណុលដែលកើនកាន់តែធ្ងន់ធ្ងរ ។ បន្ទាប់មកពួកគេត្រូវតែលក់ដីដែលជាទ្រព្យមានផលិតភាពដើម្បីសងបំណុល ដែលពួកគេបានជំពាក់ជាបន្តបន្ទាប់មក ។

ផលិតផលកសិកម្មពឹងផ្អែកទាំងស្រុងលើភ្លៀង ។ ជាលទ្ធផល ការចិញ្ចឹមជីវិតនៅជនបទនឹងត្រូវប៉ះពាល់ដោយការផ្លាស់ប្តូរលក្ខខណ្ឌអាកាសធាតុ ដូចជា ភាពរាំងស្ងួត និងទឹកជំនន់ ។ ប្រទេសកម្ពុជាមានគ្រោះ ទឹកជំនន់បីឆ្នាំបន្តគ្នា គឺឆ្នាំ១៩៩២ ១៩៩៣ និង ១៩៩៦ ហើយឆ្នាំ១៩៩៣ និង ១៩៩៦ ក៏មានគ្រោះរាំងស្ងួតផងដែរ ។ បាតុភូតធម្មជាតិនេះ ប្រហែលជាមិនមានផលប៉ះពាល់ដោយផ្ទាល់លើការលក់ដីដោយសារប្រពន្ធ័ ផលិតផលជីវព្រឹត្តិដែលអ្នកក្រត្រូវតែខ្ចីបុលគេក្នុងកំរិតការប្រាក់ខ្ពស់ដើម្បីទប់ស្កាត់នឹងការខ្វះស្បៀងនៅក្នុងគ្រួសារឡើយ ។ ពួកគេត្រូវតែសងវិញជាផលិតផលពេលប្រមូលផលដែលតែងតែមានតំលៃទាប ។ បញ្ហាផលិតផលទាបដដែលនេះ បានធ្វើឱ្យគេសងបំណុលហើយមានសល់ផលិតផលតិចតួចសំរាប់ហូប ហើយពួកគេត្រូវខ្ចីម្តងទៀតនៅពេលក្រោយដែលធ្វើឱ្យលំដាប់នេះចេះតែបន្តរហូត ។ ការប្រមូលផលមិនបានច្រើនជាប់គ្នា ពីរបីឆ្នាំអាចធ្វើឱ្យបំណុលកើនខ្ពស់រហូតដល់កំរិតមួយដែលការលក់ដីដោយបង្ខំ គឺជាជំរើសតែមួយ ។

ការពន្យល់បកស្រាយខាងលើ មិនមែនមានបំណងបង្ហាញពីមូលហេតុនៃភាពគ្មានដីនៅកម្ពុជាទេ ។ ការសិក្សាពីភាពគ្មានដីធ្លីនៅកំពង់រាប ខេត្តតាកែវ ដោយ Kato (1996b) បានគូសបញ្ជាក់ពីមូលហេតុជាច្រើននៃភាពគ្មានដីនៅជនបទ ព្រមទាំងភាពខ្វះខាតជំនាញ និងគំនិតភាពខុសគ្នារវាងបុរស-ស្ត្រី តំលៃដី ក៏ដូចជា កត្តាសហគមន៍ផ្សេងទៀតដូចជា ខ្វះការសាមគ្គីគ្នា និងការដឹកនាំថ្នាក់មូលដ្ឋានជាដើម [៤] ។ កត្តានីមួយៗ តែឯកឯងទាំងនេះមិនអាចបង្កឱ្យមានភាពគ្មានដីកើតមានទេ ប៉ុន្តែបើវារួមបញ្ចូលគ្នាវានឹងនាំគ្រួសារឈានទៅរកភាពគ្មានដី ។

៤ ការពិភាក្សាលំអិតសូមអាន Kato (1999b:14-19) ។

# ឧបសម្ព័ន្ធ

តារាង ១. ចលនានៃអត្រាប្តូរប្រាក់រៀល និងប្រាក់ដទៃទៀតធៀបនឹងប្រាក់ដុល្លារ។ ការប្រែប្រួលជា % ក្នុងមួយឯកតានៃប្រាក់ដុល្លារ ដោយធៀបនឹងឆ្នាំមុន។

| | ប្រាក់ | 1996 | 1997 | 1998 | 1999 |
|---|---|---|---|---|---|
| កម្ពុជា | Riel | 45,9 | 13,6 | 26,7 | 1,3 |
| អាស៊ាន | | | | | |
| សឹង្ហបុរី | Sing. $ | 69,8 | 4,9 | 12,8 | -1,2 |
| ថៃ | Baht | 99,2 | 24,1 | 31,8 | -10,3 |
| ម៉ាឡេ | Ringgitt | 90,9 | 11,5 | 39,5 | -3,1 |
| ឥណ្ឌូនេស៊ី | Rupiah | 132,6 | 24,2 | 244,2 | -14,1 |
| ភូមា | Kyat | 91,6 | 5,4 | 1,6 | 4789,5 |
| ភីលីភីន | Peso | 1000,0 | 12,6 | 38,6 | -5,1 |
| ឡាវ | Kip | 158,7 | 36,8 | 161,7 | 66,8 |
| វៀតណាម | Dong | n.a. | 5.9 | 13,8 | 1,8 |

*ប្រភព: Table 10 in Sok et al (2000).*

**តារាង ២. សេចក្ដីសង្ខេបនៃថវិការដ្ឋឆ្នាំ ១៩៩៥-២០០០ (កោដរៀល)**

| | 1995 | 1996 | 1997 | 1998 | 1999[E] | 2000[P] |
|---|---|---|---|---|---|---|
| ចំណូល | 643 | 749 | 881 | 939 | 1,318 | 1,505 |
| ចំណូលចរន្ត | 635 | 710 | 869 | 905 | 1,304 | 1,485 |
| ចំណូលពន្ធដា | 446 | 534 | 597 | 679 | 956 | 1,065 |
| ចំណូលមិនមែនពន្ធ | 190 | 176 | 271 | 226 | 348 | 420 |
| ចំណូលជាមូលធន | 8 | 39 | 12 | 33 | 14 | 20 |
| ចំណាយ | 1,201 | 1,441 | 1,260 | 1,553 | 1,933 | 2,385 |
| ចំណាយចរន្ត | 690 | 813 | 808 | 930 | 1,113 | 1,315 |
| ចំណាយជាមូលធន | 511 | 629 | 452 | 623 | 820 | 1,070 |
| ឱនភាពចរន្ត | -54 | -103 | 61 | -24 | 192 | 170 |
| ឱនភាពទូទៅ | -558 | -692 | -379 | -614 | -615 | -880 |
| ហិរញ្ញប្បទាន | 558 | 692 | 379 | 614 | 615 | 880 |
| ហិរញ្ញប្បទានបរទេស | 559 | 680 | 446 | 508 | 611 | 895 |
| ហិរញ្ញប្បទានក្នុងស្រុក | -2 | 13 | -67 | 106 | 4 | -15 |
| ក្នុងនោះ ហិរញ្ញប្បទានធនាគារ | 6 | -17 | -75 | 125 | -70 | 0 |
| ផ.ស.ស | 7,200 | 8,250 | 9,100 | 10,900 | 11,800 | 12,700 |
| ចំណូល | 8.9 | 9.1 | 9.7 | 8.6 | 11.2 | 11.9 |
| ចំណូលពន្ធ | 6.2 | 6.5 | 6.6 | 6.2 | 8.1 | 8.4 |
| ចំណូលមិនមែនពន្ធ | 2.6 | 2.1 | 3.0 | 2.1 | 2.9 | 3.3 |
| ចំណាយ | 16.7 | 17.5 | 13.8 | 14.2 | 16.4 | 18.8 |
| ចំណាយចរន្ត | 9.6 | 9.9 | 8.9 | 8.5 | 9.4 | 10.4 |
| ចំណាយជាមូលធន | 7.1 | 7.6 | 5.0 | 5.7 | 7.0 | 8.4 |
| ឱនភាពចរន្ត | -0.8 | -1.2 | 0.7 | -0.2 | 1.6 | 1.3 |
| ឱនភាពទូទៅ | -7.7 | -8.4 | -4.2 | -5.6 | -5.2 | -6.9 |
| ហិរញ្ញប្បទាន | 7.7 | 8.4 | 4.2 | 5.6 | 5.2 | 6.9 |
| ហិរញ្ញប្បទានបរទេស | 7.8 | 8.2 | 4.9 | 4.7 | 5.2 | 7.0 |
| ហិរញ្ញបទានក្នុងស្រុក | -0.0 | 0.2 | -0.7 | 1.0 | 0.0 | -0.1 |

*E Estimated. P Planned. Source: CDRI.*

## តារាង ៣. ចំណូល និងចំណាយរដ្ឋតាមប្រភព និងផ្នែក

| | 1995 | 1996 | 1997 | 1998 | 1999 |
|---|---|---|---|---|---|
| ចំណូលសរុប | 643 | 749 | 881 | 939 | 1,318 |
| ចំណូលពន្ធ | 446 | 534 | 597 | 679 | 956 |
| ពន្ធផ្ទាល់ | 21 | 27 | 46 | 59 | 79 |
| ពន្ធលើប្រាក់បៀវត្សរ៍ | 1 | 3 | 6 | 9 | 11 |
| ពន្ធលើប្រាក់ចំណេញ | 19 | 19 | 35 | 42 | 58 |
| ដីធ្លី និងទ្រព្យសម្បត្តិ | 1 | 5 | 5 | 8 | 11 |
| ពន្ធប្រយោល | 104 | 164 | 204 | 244 | 444 |
| អាករពិសេស | 9 | 57 | 74 | 76 | 92 |
| អាករលើតំលៃបន្ថែម | 77 | 98 | 122 | 156 | 350 |
| ពន្ធលើពាណិជ្ជកម្មអន្តរជាតិ | 321 | 344 | 347 | 376 | 433 |
| ពន្ធនាំចូល | 299 | 331 | 336 | 373 | 415 |
| ពន្ធនាំចេញ | 17 | 8 | 10 | 3 | 17 |
| ចំណូលមិនមែនពន្ធ | 190 | 176 | 271 | 226 | 348 |
| ចំណូលជាមូលធន | 8 | 39 | 12 | 33 | 14 |
| ចំណាយ | 1248 | 1419 | 1268 | 1557 | 1795 |
| ចំណាយចរន្ត | 737 | 790 | 816 | 934 | 1125 |
| ការពារជាតិ | 430 | 406 | 419 | 453 | 470 |
| សង្គម | 148 | 179 | 189 | 203 | 316 |
| អប់រំ | 74 | 80 | 83 | 102 | 150 |
| សុខាភិបាល | 26 | 42 | 45 | 43 | 80 |
| ចំណាយជាមូលធន | 511 | 629 | 452 | 623 | 670 |

*ប្រភព:* CDRI

# បញ្ជីឯកសារពិភាក្សារបស់ វបសអ


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ខ្មែរ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ច្បាប់ដែលបានបោះពុម្ព ហើយផ្សព្វផ្សាយអស់ ។

៣. Kannan, K. P. (មករា ១៩៩៧) *ការកែទំរង់សេដ្ឋកិច្ច ការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិចូ សូ-សុវណ្ណរិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឹលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.០០០រៀល ។

៥. Toshiyasu Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរ:អាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin Godfrey, Toshiyasu Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina Orlova, Per Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.០០០រៀល ។

៩. តេង-យូតឹ ប៉ុន-ដូរីណា សូ-សុវណ្ណរិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ។

១៦. ស៊ិក ប៊ូរ៉ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល, សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ, ទេព-សាវ៉ារី, ប៊ុន-ដូរីណា, Claude Katz, Sarthi Acharya, ស៊ីសុវត្ថិ ឌូង ចាន់តូ, និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាព ក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សាវ៉ារី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២០០១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២០. សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វត្ថមុនី Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២០០២) *ការវាយតំលៃសង្គមពាក់ពន្ធ័នឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។